មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា
# ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍

## ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣






ខែតុលា ឆ្នាំ២០២៤

ស្កេនដើម្បីអាន

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

របាយការណ៍ស្ដីពី “សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា” (“របាយការណ៍”) ជាការបោះពុម្ពផ្សាយរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (“គម្រោង”) អនុវត្តដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”)។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល (“អង្គការ”) ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”)។

ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាព ដែលប្រជាពលរដ្ឋទាំងអស់អាចទទួលបានសិទ្ធិមនុស្សមូលដ្ឋាន ទទួលបាននីតិរដ្ឋដែលគ្មាននិទណ្ឌភាព ទទួលបានការគោរពដោយស្មើភាពគ្នា គ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហាន ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាប្រកបដោយចីរភាព។

ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌សកំពុងហើរចេញពីរង្វង់មូលពណ៌ផ្ទៃមេឃ ដែលមានន័យថាជាការទាមទារសេរីភាពនៅកម្ពុជា។

## គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក

គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានគោលបំណងចម្បងចំនួនពីរ៖ ទីមួយ បង្កើនការអនុលោមតាមបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការ និងទីពីរ ផ្សព្វផ្សាយគោលគំនិតអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងចំណោមសាធារណជន។ គម្រោងធ្វើការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ហើយលទ្ធផលត្រូវបានបោះពុម្ពផ្សាយដោយផ្អែកលើភស្តុតាង សំដៅជំរុញការបង្កើននូវការគោរពតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិនៅក្នុងតុលាការ និងវិស័យយុត្តិធម៌នៅកម្ពុជា។ គម្រោងបាននឹងកំពុងសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ ចាប់តាំងពីឆ្នាំ ២០១៣ មកម្ល៉េះ ហើយនៅសាលាឧទ្ធរណ៍បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ចាប់តាំងពីខែមិថុនា/កក្កដា ឆ្នាំ២០២២។ នេះគឺជារបាយការណ៍ប្រចាំឆ្នាំលើកទីប្រាំបីដែលគម្រោងបានផលិតឡើង និងជារបាយការណ៍ទី២ដែលបានបញ្ចូលទិន្នន័យពីការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ទាំងអស់។




គម្រោងនេះក៏បានផលិតកម្រងមេរៀនដែលមានសេចក្ដីពន្យល់ពេញលេញ វីដេអូ ខិត្តប័ណ្ណព័ត៌មាន និងសំណួរអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ។ កម្រងមេរៀននេះអាចស្វែងរកបាននៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា (www.sithi.org)។

## សំណួរ និងមតិចូលរួម

លោកអ្នកអាចស្វែងរករបាយការណ៍នេះ និងរបាយការណ៍មុនៗស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅកម្ពុជា" នៅលើគេហទំព័ររបស់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ www.cchrcambodia.org និង នៅលើគេហទំព័រសិទ្ធិមនុស្ស https://www.sithi.org/tmp/publication?type=report ។

ប្រសិនបើលោកអ្នកមានចម្ងល់ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖
ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

# មាតិកា

**មាតិកា** ........ 3
**បញ្ជីអក្សរកាត់** ........ 5
**ខ្លឹមសារសង្ខេប** ........ 7
**១. សេចក្តីផ្តើម** ........ 9
១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........ 9
១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ ........ *9*
១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា ........ *10*
១.២. វិសាលភាព និងវិធីសាស្ត្រ ........ 13
**២.និន្នាការទូទៅ** ........ 17
**៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព** ........ 20
**ដោយតុលាការទាំងអស់** ........ 20
៣.១.សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ........ 20
៣.២.សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ ........ 21
**៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដោយ** ........ 23
**តុលាការមួយចំនួន** ........ 23
៤.១. សិទ្ធិមានមេធាវី ........ 23
៤.២. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ 32
៤.៣.សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃចោទប្រកាន់ ........ 38
៤.៤. សិទ្ធិមានវត្តមានពេលសវនាការ ........ 43
៤.៥. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ........ 47
៤.៦ .សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........ 49
**៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនទាន់ត្រូវបានគោរពពេញលេញ** ........ 60
៥.១ .សិទ្ធិមានសេរីភាព ........ 60
៥.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ........ 63
៥.៣.សិទ្ធិបង្ហាញភស្តុតាង ........ 68
៥.៤. សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ........ 71
៥.៥. ការប្រតិបត្តិរបស់ចៅក្រម ........ 75
៥.៦. សិទ្ធិកុមារទំនាស់នឹងច្បាប់ ........ 80
**៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 91

៦.១. អនុសាសន៍រួម 91
៦.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះ ដោយគ្មានការពន្យារពេល 92
៦.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព 92
៦.៤. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ 92
៦.៥. អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ 92
៦.៦. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិមានមេធាវី 93
៦.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស 93
៦.៨. អនុសាសន៍ទាក់ទងនឹងការប្រតិបត្តិរបស់ចៅក្រម 94
៦.៩. អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង 94
៦.១០. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ 94
៦.១១. អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ 95

# បញ្ជីអក្សរកាត់

| | |
|---|---|
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍ប្រើដោយអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការនៅពេលសង្កេត |
| ការណែនាំអំពីតារាងសង្កេតការណ៍ | ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ឱ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍ |
| ក្រមសីលធម៌ | ជាឯកសារដែលកំណត់អំពីកាតព្វកិច្ចនានារបស់អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក គឺមិនជ្រៀតជ្រែក មិនលម្អៀង និងរក្សានូវការសម្ងាត់លើកិច្ចការងាររបស់ខ្លួន |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| អ.ស.ក | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍ |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| មិនដឹង | ព័ត៌មានដែលមិនទទួលបាន ឬមិនបានតាមដានបន្ត |
| ច្បាប់រៀបចំអង្គការតុលាការ | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ |
| ច្បាប់ឧត្តមប្រឹក្សានៃអង្គចៅក្រម | ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម |
| ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា | ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា |
| ក្រសួងមហាផ្ទៃ | ក្រសួងមហាផ្ទៃ |
| ក.យ | ក្រសួងយុត្តិធម៌ |
| មិនពាក់ព័ន្ធ | អវត្តមានជនជាប់ចោទ ឬមិនជាប់ពាក់ព័ន្ធ ។ល។ |
| ផ.យ.អ.ជ | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ |
| អង្គការមិនមែនរដ្ឋាភិបាល | អង្គការមិនមែនរដ្ឋាភិបាល |
| ការិយាល័យឧត្តមស្នងការ | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ |
| អ.ស.ស.អ | អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប |

| | |
|---|---|
| គម្រោង | គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក |
| អំឡុងពេលធ្វើរបាយការណ៍ | ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ |
| រដ្ឋាភិបាល | រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| ស.ស.ស.ម | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| យូនីសេហ្វ | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ។ |

# ខ្លឹមសារសង្ខេប

នៅចន្លោះថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ របស់ ម.ស.ម.ក បានសង្កេតសវនាការសំណុំរឿងព្រហ្មទណ្ឌចំនួន ៧៧២ នៅសាលាឧទ្ធរណ៍**ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ** និង**ព្រះសីហនុ**[1] ដើម្បីវាយតម្លៃការប្រកាន់ខ្ជាប់នូវសិទ្ធិសំខាន់ៗក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ របាយការណ៍នេះបង្ហាញ និងវិភាគទិន្នន័យដែលប្រមូលបាន ក្នុងគោលបំណងដើម្បីរួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជា។ របាយការណ៍ក៏បានប្រៀបធៀបទិន្នន័យអំឡុងឆ្នាំនេះជាមួយនឹងទិន្នន័យនៃអំឡុងពេលធ្វើរបាយការណ៍មុនៗ ដើម្បីកំណត់និន្នាការ និងវិភាគការវិវឌ្ឍនៃការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅតាមតុលាការគោលដៅ។

របាយការណ៍បានរកឃើញថា សម្រាប់ឆ្នាំទីពីរនៃឆ្នាំ២០២៣នេះ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវបានធានានៅចំពោះមុខតុលាការគោលដៅទាំងអស់ ពោលគឺមានសិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ គួរឱ្យសាទរ សិទ្ធិជាមូលដ្ឋានក្នុងការមានវត្តមាននៅពេលសវនាការត្រូវបានគោរពដោយតុលាការគោលដៅចំនួនបី (**ភ្នំពេញ បាត់ដំបង** និង**ព្រះសីហនុ**)។ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលក៏ត្រូវបានគោរពដោយតុលាការចំនួនបីផងដែរ (**បាត់ដំបង ត្បូងឃ្មុំ** និង**ព្រះសីហនុ**) ហើយសម្រាប់សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈក៏ត្រូវគោរពដូច្នោះដែរដោយតុលាការចំនួនពីរ (**ភ្នំពេញ** និង**ត្បូងឃ្មុំ**)។

សាលាឧទ្ធរណ៍**ព្រះសីហនុ** បានបង្ហាញពីវឌ្ឍនភាពល្អប្រសើរដោយគោរពបាននូវសិទ្ធិសំខាន់ៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន ៦ ក្នុងចំណោមសិទ្ធិទទួលបានជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានសង្កេតចំនួន ១៤ ហើយបើធៀបនឹងឆ្នាំ២០២២ មានត្រឹមតែសិទ្ធិចំនួន ៤ ប៉ុណ្ណោះ។ តុលាការព្រះសីហនុបានគោរពសិទ្ធិមានមេធាវី សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះជាលើកដំបូងចាប់តាំងពី ម.ស.ម.ក បានចាប់ផ្តើមសង្កេតសវនាការសំណុំរឿងព្រហ្មទណ្ឌនៅតុលាការនេះ។ ខុសពីឆ្នាំមុន សាលាឧទ្ធរណ៍**ភ្នំពេញ** បានគោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈយ៉ាងខ្ជាប់ខ្ជួននៅឆ្នាំ ២០២៣។ ទោះជាសាលាឧទ្ធរណ៍ភ្នំពេញបានគោរពនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចំនួន ៤ ក្នុងចំណោមចំនួន ១៤ យ៉ាងណាក្តី នេះក៏ជាការខិតខំ និងបង្ហាញឱ្យឃើញពីការកែលម្អបើប្រៀបធៀបនឹងឆ្នាំ២០២២ ដែលតួលេខនេះមានតែចំនួន ៣ ប៉ុណ្ណោះ។

ផ្ទុយទៅវិញ សាលាឧទ្ធរណ៍**បាត់ដំបង** បានគោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈមិនទាន់បានពេញលេញទេ បន្ទាប់ពីសិទ្ធិនេះត្រូវបានគោរពនៅឆ្នាំ២០២២ ដូច្នេះហើយឃើញថាតួលេខនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមានការថយចុះបន្តិចពីចំនួន ៥ មកនៅត្រឹម ៤ ក្នុងចំណោមចំនួន ១៤។ រីឯសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**ក៏ត្រូវបានសង្កេតឃើញថាការគោរពសិទ្ធិមានវត្តមាននៅពេលសវនាការមិនទាន់បានពេញលេញ

[1] គម្រោងនេះបានចាប់ផ្តើមសង្កេតសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបង នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២២ និងនៅសាលាឧទ្ធរណ៍ព្រះសីហនុ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២។

នៅឡើយទេ។ ជាលទ្ធផល មានសិទ្ធិចំនួន ៤ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗត្រូវបានគោរពក្នុងចំណោមសិទ្ធិចំនួន ១១ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣ គឺមានការធ្លាក់ចុះបន្តិចបើធៀបនឹងឆ្នាំ២០២២ មានសិទ្ធិចំនួន ៥ ត្រូវបានគោរព។

តាមរយៈការសង្កេត បានរកឃើញនូវកង្វះខាតគួរឱ្យកត់សម្គាល់មួយចំនួន ចំពោះការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗ។ *ទីមួយ* សិទ្ធិមានសេរីភាពនៅតែត្រូវបានបន្តមិនទាន់គោរពបានពេញលេញ ដោយទិន្នន័យបង្ហាញថាមានការប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្នច្រើន រួមទាំងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ផងដែរ។ ម.ស.ម.ក កត់សម្គាល់ថា មានជនជាប់ចោទប្រមាណ ៣ នាក់ក្នុងចំណោម ៤ នាក់បានទទួលរងនូវការប្រើប្រាស់វិធានការនៃការឃុំខ្លួនក្នុងឆ្នាំ២០២៣ ដែលមិនស្របទៅនឹងគោលការណ៍ថាការឃុំខ្លួនគឺសម្រាប់តែករណីពិសេសប៉ុណ្ណោះ។ *ទីពីរ* សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ក៏ត្រូវបានចាត់ទុកថាមិនត្រូវបានគោរពពេញលេញដែរ។ បញ្ហានេះបណ្ដាលមកពីមិនមានការស៊ើបអង្កេតឡើងវិញឱ្យបានហ្មត់ចត់ ក្នុងករណីដែលមានការលើកឡើងថាមានការប្រើហិង្សាក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្ខំឱ្យជនជាប់ចោទសារភាព។ *ទីបី* តុលាការទាំងនោះខកខានមិនបានផ្ដល់ហេតុផលលម្អិត និងច្បាស់លាស់ក្នុងពេលប្រកាសនូវសេចក្ដីសម្រេចរបស់ខ្លួនក្នុងសំណុំរឿងចំនួន ៤ ក្នុងចំណោម ៥ ដែលបានសង្កេត។ ដោយហេតុថាមានសវនាការចំនួន ៧ ក្នុងចំណោម ១០ មានរយៈពេល ៣០ នាទី ឬតិចជាងនេះ ទើបធ្វើឱ្យមានចម្ងល់ថាតើចៅក្រមអាចពិនិត្យមើលសំណុំរឿងទាំងនោះឱ្យបានហ្មត់ចត់កម្រិតណា។

ចុងបញ្ចប់នៃរបាយការណ៍នេះបានផ្ដល់នូវអនុសាសន៍សំខាន់ៗ ដើម្បីឱ្យតុលាការ និងស្ថាប័នពាក់ព័ន្ធដោះស្រាយចំណុចខ្វះខាតដែលបានបង្ហាញក្នុងរបាយករណ៍នេះ។ ម.ស.ម.ក សង្ឃឹមថា ទិន្នន័យ ការវិភាគ និងអនុសាសន៍ដែលមានក្នុងរបាយការណ៍នេះនឹងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតុលាការ និងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រមទាំងគាំទ្រដល់អ្នកដែលបំពេញកិច្ចការនេះ ធានាបាននូវប្រព័ន្ធតុលាការនៅកម្ពុជាមានភាពយុត្តិធម៌ និងស្មើភាពសម្រាប់មនុស្សគ្រប់រូប។

# ១. សេចក្តីផ្តើម

## ១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសសរស្តម្ភស្នូលនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងជាធាតុផ្សំដ៏សំខាន់មួយនៃការគោរពនីតិរដ្ឋ។ សិទ្ធិនេះផ្តល់ឱ្យជនម្នាក់ៗ និងគ្រប់រូបដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ នូវសិទ្ធិទទួលបានការប្រព្រឹត្តដោយយុត្តិធម៌ និងស្មើភាពគ្នាចំពោះពួកគេ ខណៈពេលដែលរដ្ឋធ្វើការកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ពួកគេ។ នៅពេលដែលអនុវត្តសិទ្ធិបានត្រឹមត្រូវ សិទ្ធិនេះការពារទាំងសិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធិរបស់ជនរងគ្រោះ ហើយក៏ជានានូវការគ្រប់គ្រងវិស័យយុត្តិធម៌បានត្រឹមត្រូវផងដែរ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមមានសិទ្ធិផ្សេងៗមួយចំនួនរបស់បុគ្គល និងរួមបញ្ចូលក្នុងដំណើរការនៃនីតិវិធីច្បាប់ព្រហ្មទណ្ឌទាំងមូល រាប់ចាប់ពីពេលចាប់ផ្តើមការឃាត់ខ្លួនជនសង្ស័យ រហូតដល់បណ្តឹងតវ៉ាជាស្ថាពរត្រូវបានបញ្ចប់។[2]

### ១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ

សិទ្ធិនេះត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងត្រូវបានការពារដោយច្បាប់អន្តរជាតិ រួមមានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (“ស.ស.ស.ម”)[3] និងកតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”)[4] ក្នុងចំណោមលិខិតុបករណ៍ផ្សេងៗទៀត។[5] មាត្រា ១០ នៃ ស.ស.ស.ម និងមាត្រា ១៤ (១)នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង។ ក.អ.ស.ព.ន ពន្យល់បន្ថែមអំពីធាតុផ្សំផ្សេងៗនៃការជំនុំជម្រះដោយយុត្តិធម៌ដែលមានជាអាទិ៍ ប៉ុន្តែមិនកម្រិតត្រឹមនេះ ដូចជា សិទ្ធិ និងគោលការណ៍ដូចតទៅ (សំដៅដល់«សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌»)៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិក្នុងការនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិមានមេធាវី សិទ្ធិទទួលបានការការពារប្រឆាំងនឹងឆ្លើយការដាក់បន្ទុកលើខ្លួនឯង និងសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។

ប្រទេសកម្ពុជាបានចូលជាសមាជិកនៃ ក.អ.ស.ព.ន ក្នុងឆ្នាំ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានបញ្ចូលដោយផ្ទាល់នូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់កម្ពុជា។ [6] បទប្បញ្ញត្តិនេះមានន័យថាបទដ្ឋានសិទ្ធិ

---

[2] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក «តើអ្វីជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌?» (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/tmp/publication?type=materials

[3] ស.ស.ស.ម (១៩៤៨), https://tinyurl.com/4mkrtd8c

[4] ក.អ.ស.ព.ន (១៩៦៦) https://tinyurl.com/3bkm3t8t

[5] មាត្រា ៨ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៦៩) មាត្រា ៧ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន (ឆ្នាំ១៩៨១) មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៥០) មាត្រា ៤៧-៥០ នៃធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិជាមូលដ្ឋានរបស់សហភាពអឺរ៉ុប (ឆ្នាំ២០០០)។

[6] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា(ឆ្នាំ១៩៩៣)https://www.sithi.org/km/laws/2008-02-19-constitution-of-the-kingdom-of-cambodia

មនុស្សអន្តរជាតិ រួមទាំងបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន អាចត្រូវអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា ដូចបានបញ្ជាក់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅឆ្នាំ២០០៧។[7]

### ១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា

ក្របខ័ណ្ឌមូលដ្ឋានសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌ មានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះផ្តល់ឱ្យមានការបែងចែកអំណាច និងប្រព័ន្ធតុលាការឯករាជ្យ ដែលធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរដូចខាងក្រោម៖

- គ្មានការរំលោភបំពានលើរូបរាងកាយបុគ្គលណាម្នាក់ឡើយ។
- គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោស ចាប់ខ្លួន ឬឃុំខ្លួនឡើយ លើកលែងតែធ្វើឡើងស្របតាមច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយ ឬការធ្វើទុក្ខទោសផ្សេងៗដែលដាក់ទណ្ឌកម្មបន្ថែមលើជននៅក្នុងឃុំ ឬជនជាប់ឃុំត្រូវបានហាមឃាត់។
- ចម្លើយសារភាពដែលទទួលបានតាមរយៈការបង្ខំលើរាងកាយ ឬផ្លូវចិត្ត មិនត្រូវបានទទួលស្គាល់ជាភស្តុតាងនៃពិរុទ្ធភាពឡើយ។
- រាល់វិមតិសង្ស័យដែលកើតឡើងនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទត្រូវចាត់ទុកថាគ្មានទោស រហូតទាល់តែតុលាការសម្រេចជាស្ថាពរលើសំណុំរឿងនោះ
- ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិការពារខ្លួនតាមរយៈបណ្តឹងឧបាស្រ័យទៅតុលាការ។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា («ក្រមព្រហ្មទណ្ឌ») ចែងអំពីប្រភេទបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។[8] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា («ក្រមនីតិវិធីព្រហ្មទណ្ឌ»)[9] ចែងលម្អិតអំពីការប្រព្រឹត្តចំពោះជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ។ ក្រមនេះចែងអំពីតួនាទី និងទំនួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្តី ចាប់តាំងពីការចាប់ផ្តើមការស៊ើបអង្កេតដំបូងរហូតដល់ពេលឃាត់ខ្លួន និងក្នុងអំឡុងពេលនៃដំណើរការរឿងក្តីព្រហ្មទណ្ឌទាំងមូល រហូតដល់បណ្តឹងតវ៉ាបញ្ចប់ជាស្ថាពរ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦[10] ចែងអំពីបទដ្ឋាន និងនីតិវិធីសម្រាប់ដោះស្រាយជាមួយកុមារដែលមានទំនាស់នឹងច្បាប់ និងការពារសិទ្ធិរបស់ពួកគេក្នុងអំឡុងពេលដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ។[11]

---

[7] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ ២ https://ccc.gov.kh/detail_info_kh.php?_txtID=214

[8] ក្រមព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០១៤)https://www.sithi.org/km/laws/2014-01-31-criminal-code-2014

[9] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ('CCPC')(ឆ្នាំ២០១៧)https://tinyurl.com/3tk7sk6chttps://sithi.org/km/tmp/publication/view/2007-09-03-criminal-procedure-code-of-the-kingdom-of-cambodia-2007

[10] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦)https://sithi.org/km/laws/2016-06-29-law-on-juvenile-justice

[11] យូនីសេហ្វ 'សំណួរ-ចម្លើយអំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅកម្ពុជា' (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦) https://tinyurl.com/46ftzbjk

បន្ថែមលើនេះ ច្បាប់គ្រឹះចំនួនបីទាក់ទងនឹងតុលាការ ពោលគឺច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[12] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[13] និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[14] ដែលបានអនុម័តក្នុងឆ្នាំ២០១៤ ក្នុងគោលបំណងធានានូវឯករាជ្យនៃអំណាចតុលាការ និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ យ៉ាងណាក្តី ច្បាប់ទាំងនេះទទួលរងនូវការរិះគន់។[15]

នៅខែមិថុនា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការមួយដែល[16] ផ្តោតសំខាន់លើគោលការណ៍ចំនួនបួនរួមមាន៖ សិទ្ធិបុគ្គល គោលការណ៍ប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ ២០១៩-២០២៣ បានគូសបញ្ជាក់ពីអាទិភាពសំខាន់ៗ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះរួមមាន៖ ការធ្វើឱ្យប្រសិទ្ធភាពការងាររបស់មន្ត្រីអនុវត្តច្បាប់មានភាពប្រសើរឡើង ការពង្រឹងទំនុកចិត្តរបស់សាធារណជនចំពោះវិស័យតុលាការ និងការប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌។[17] នៅខែសីហា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ «*យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១*» ដែលចាត់ទុក «*ការធ្វើឱ្យមានភាពប្រសើរឡើង និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌*» ជាអាទិភាពមួយ។ ក្នុងចំណោមកិច្ចការផ្សេងទៀត រាជរដ្ឋាភិបាលបានប្តេជ្ញាថានឹងផ្តោតសំខាន់លើការបង្កើនសមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការផ្តល់មេធាវីការពារដល់ជនក្រីក្រ និងជនងាយរងគ្រោះ ក៏ដូចជាការពង្រឹងប្រសិទ្ធភាពនៃដំណើរការរបស់តុលាការ ការធ្វើទំនើបកម្មរដ្ឋបាលតុលាការ ដើម្បីកែលម្អការផ្តល់យុត្តិធម៌ និងការជំរុញឱ្យមានការអភិវឌ្ឍយន្តការដោះស្រាយវិវាទ។[18]

ការអភិវិឌ្ឍមួយចំនួនដែលអាចនាំឱ្យមានការកែលម្អគួរឱ្យកត់សម្គាល់លើកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការក៏បានកើតមានឡើង ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះដែរ៖

- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីផ្តល់សេវាការពារផ្លូវច្បាប់ដល់ស្ត្រីក្រីក្រ និងកុមារីរងគ្រោះដោយអំពើហិង្សា និងដើម្បីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់អំពីច្បាប់ផ្សេងៗដែលពាក់ព័ន្ធ។ នៅ

[12] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ (ឆ្នាំ២០១៤) http://national-assembly.org.kh/ViewLawFile.aspx?LawDID=454

[13] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា (ឆ្នាំ២០១៤) http://national-assembly.org.kh/ViewLawFile.aspx?LawDID=455

[14] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ឆ្នាំ២០១៤) http://national-assembly.org.kh/ViewLawFile.aspx?LawDID=456

[15] ម.ស.ម.ក គោលដៅយុត្តិធម៌ API អាដហុក តម្លាភាពកម្ពុជា និង IFEX 'របាយការណ៍រួមស្តីពីសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា' (ថ្ងៃទី១២ ខែកក្កដាឆ្នាំ២០១៨) https://www.sithi.org/km/tmp/publication/view/2018-07-12-3rd-cycle-of-upr-report-on-the-access-to-justice; ម.ស.ម.ក, 'ការវិភាគផ្នែកច្បាប់ សេចក្តីព្រាងច្បាប់ចំនួនបី ទាក់ទងនឹងប្រព័ន្ធតុលាការ' (២០១៤), https://tinyurl.com/jzmpp4un *សូមមើលផងដែរ* មតិយោបល់របស់ ការិយាល័យឧត្តមស្នងការ ប្រចាំកម្ពុជា លើសេចក្តីព្រាងច្បាប់គ្រឹះចំនួនបីទាក់ទងនឹងប្រព័ន្ធតុលាការ (ខែឧសភា ឆ្នាំ២០១៤): https://tinyurl.com/ys4jypw5 ; https://tinyurl.com/yt3ud573 ; https://tinyurl.com/yufd4442

[16] ក្រុមប្រឹក្សាស្តារនិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា 'ការអនុវត្តគោលនយោបាយរដ្ឋាភិបាល' (ឆ្នាំ២០០៤) វាក្យខណ្ឌ ១៦, https://tinyurl.com/bddka8a

[17] ក្រសួងផែនការ 'ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣' ទំព័រ ២០៥-២០៦ វាក្យខណ្ឌ ៤.២១(៧) https://tinyurl.com/yep765sfa

[18] រាជរដ្ឋាភិបាលកម្ពុជា «យុទ្ធសាស្ត្របច្ចកោណ-ដំណាក់កាលទី១» (សីហា ២០២៣), ទំព័រ ៣១, https://asset.cambodia.gov.kh/mptc/media/KH-PENTAGONAL-STRATEGY-PHASE-I.pdf

ក្រោមអនុស្សារណៈយោគយល់នេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នឹងផ្តល់តំណាងផ្លូវច្បាប់ដល់អ្នកដែលរងផលប៉ះពាល់ពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ និងការរំលោភសិទ្ធិផ្សេងៗទៀត ខណៈដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនឹងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់សេវាកម្មផ្លូវច្បាប់ផ្សេងៗ។ [19] នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤ អនុស្សារណៈនៃការយោគយល់គ្នានេះត្រូវបានបន្តរហូតដល់ឆ្នាំ២០២៨ ។[20]

- នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៣ ព្រះមហាក្សត្របានចេញព្រះរាជក្រឹត្យអនុញ្ញាតឱ្យចៅក្រម និងព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ចូលនិវត្តន៍នៅអាយុ ៦៥ ឆ្នាំជំនួសឱ្យ ៦០ ឆ្នាំវិញ ដើម្បីដោះស្រាយបញ្ហាកង្វះចៅក្រម និងព្រះរាជអាជ្ញានាពេលបច្ចុប្បន្ននេះ។[21] នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជាក៏បានបើកទទួលសិស្សចៅក្រម និងព្រះរាជអាជ្ញាចំនួន ៥០ នាក់ សិស្សក្រឡាបញ្ជីចំនួន ១០០ នាក់ អាជ្ញាសាលាចំនួន ៥០ នាក់ និងសារការីចំនួន ៥០ នាក់ផងដែរ។[22]

- នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានអនុម័តលើសេចក្តីព្រាងព្រះរាជក្រឹត្យបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាជម្រើសមួយសម្រាប់ដោះស្រាយសំណុំរឿងរដ្ឋប្បវេណីនិងវិវាទពាណិជ្ជកម្ម ក្នុងគោលបំណងកាត់បន្ថយភាពយឺតយ៉ាវនៃដំណើរសំណុំរឿងនៅក្នុងប្រព័ន្ធច្បាប់។[23] នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌ បានប្រកាសថា អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនឹងចាប់ផ្តើមបើកទទួលពាក្យបណ្តឹងនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤។[24]

- នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (គ.ក.ប.យ) ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យ ដើម្បី«*ណែនាំ សម្របសម្រួល និងជំរុញការអនុវត្តការកែទម្រង់ប្រព័ន្ធយុត្តិធម៌*»។ គណៈកម្មាធិការដឹកនាំកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានទំនួលខុសត្រូវក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ និងបង្ហាញរបាយការណ៍វឌ្ឍនភាពការងារ និងស្នើវិធានការសំខាន់ៗដើម្បីដោះស្រាយបញ្ហាប្រឈមដែលកំពុងមាន។ គណៈកម្មាធិការនេះ

---

[19] វួន ដារ៉ា «គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាសម្រាប់ជនរងគ្រោះជាស្ត្រី» (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១) https://tinyurl.com/4697y34b

[20] ប៉ែន ស្រីនាថ «ស្ត្រី និងកុមារី ដែលបានរងនូវអំពើហិង្សា ឬភាពអយុត្តិធម៌ សូមស្វែងរកមេធាវីនៅគណៈមេធាវី ដើម្បីជួយការពារក្តីដោយឥតគិតថ្លៃ ដោយផ្អែកលើអនុស្សារណៈនៃយោគយល់គ្នាដែលមានរួចមកហើយ» [ជាភាសាខ្មែរ] (*Cambodia Express News* ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤) https://tinyurl.com/487zeyw6

[21] ឡុង គីមម៉ារីតា «មន្ត្រីសាលាឧទ្ធរណ៍ឥឡូវអាចចូលនិវត្តន៍នៅអាយុ៦៥ ឆ្នាំ ស្របតាមព្រះរាជក្រឹត្យ» (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣) https://tinyurl.com/mr6ytksp

[22] ឡុង គីមម៉ារីតា «ក្រសួងយុត្តិធម៌កំពុងជ្រើសរើសចៅក្រម និងមន្ត្រីថ្មីៗ» (*ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣), https://tinyurl.com/2537ya7e

[23] សុខ វក្សា «គណៈរដ្ឋមន្ត្រីអនុម័តសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីស្ថាប័នសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ» (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៣) https://tinyurl.com/yc456snf

[24] សំបាន ចាន់ដារ៉ា «ការការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានចូលជាធរមាននៅថ្ងៃទី១ ខែមីនា»(*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៩ ខែមករា ២០២៤) https://tinyurl.com/p8jnpxvy

ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូលជាសហប្រធាន និងតំណាងមកពីក្រសួង និងស្ថាប័នយុត្តិធម៌នានាផងដែរ។[25]

- នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានប្រកាសថា ក្រសួងនឹងដាក់ចេញនូវយុទ្ធនាការចំនួនពីរ ដើម្បីពន្លឿនការជំនុំជម្រះរបស់តុលាការ និងដោះស្រាយរាល់ភាពមិនប្រក្រតីទាំងអស់ដែលបានរកឃើញនៅក្នុងប្រព័ន្ធយុត្តិធម៌ ដើម្បីបង្កើនតម្លាភាព។ ឯកឧត្តមមានប្រសាសន៍ថា យុទ្ធនាការទីមួយនឹងផ្តោតលើការដោះស្រាយសំណុំរឿងនៅក្នុងវិស័យធំៗចំនួនបី គឺសំណុំរឿងគ្រឿងញៀន សំណុំរឿងចរាចរណ៍ និងសំណុំរឿងរដ្ឋប្បវេណី។ ចំណែកឯយុទ្ធនាការទី២ នឹងផ្តោតលើការពិនិត្យលើភាពមិនប្រក្រតីនៃសំណុំរឿងដែលកើតចេញពីមន្ត្រីតុលាការ។[26] នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌បានប្រកាសថា ក្រសួងបានដោះស្រាយសំណុំរឿងអត្រានុកូលដ្ឋាន ដែលជាប់គាំងបានចំនួន ៩៩%។[27]
- នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌បានចេញផ្សាយបញ្ជីឈ្មោះមេធាវីស្ម័គ្រចិត្តចំនួន ២០៩ រូប ដែលនឹងផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃដល់សាធារណជនទូទាំងប្រទេស។ បញ្ជីនេះត្រូវបានផ្សព្វផ្សាយនៅលើគណនីបណ្តាញសង្គមរបស់ក្រសួងយុត្តិធម៌។[28]

ទាំងនេះគឺជាគំនិតផ្តួចផ្តើមគួរឱ្យស្វាគមន៍ដែលបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តអនុសាសន៍ស្តីពីការទទួលបានយុត្តិធម៌ដែលរាជរដ្ឋាភិបាលបានទទួលស្គាល់ នៅក្នុងអំឡុងពេលនៃការពិនិត្យជាសកលតាមពេលកំណត់ (យូភីអរ)លើកទីបីរបស់ខ្លួនកាលពីខែមករា ឆ្នាំ២០១៩។[29]

## ១.២. វិសាលភាព និងវិធីសាស្ត្រ

កំឡុងពេលធ្វើរបាយការណ៍នេះ អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក បានចូលរួមសង្កេតសវនាការនៃសំណុំរឿងព្រហ្មទណ្ឌនៅតុលាការគោលដៅទាំងបួនជាប្រចាំ។ អ្នកសង្កេតសវនាការបានប្រើតារាងសង្កេតការណ៍សវនាការដែលបានរៀបចំឡើងជាពិសេស («តារាងសង្កេតការណ៍សវនាការ») ដែលរួមមានសំណួរជាង ៨០ ដែលផ្តោតសំខាន់លើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួន រួមមានសិទ្ធិដូចខាងក្រោមនេះ៖[30]

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

---

[25] សុខ វក្សា «ព្រះរាជក្រឹត្យបញ្ជាក់អំពីតួនាទីរបស់គណៈកម្មការក្នុងកំណែទម្រង់ច្បាប់» (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤), https://tinyurl.com/j6ubsa2n / https://www.bakc.org.kh/index.php/km/4371-2024-01-08-08-24-49

[26] យួន ណារីម «ក្រសួងយុត្តិធម៌ដាក់ចេញយុទ្ធនាការដើម្បីពន្លឿនការជំនុំជម្រះរបស់តុលាការ និងពិនិត្យភាពមិនប្រក្រតីផ្សេងៗ» (*CamboJA News* ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤) https://tinyurl.com/4rj5cxfk

[27] សំបាន ចាន់ដារ៉ា «តុលាការដោះស្រាយសំណុំរឿងអត្រានុកូលដ្ឋាន ៩៩%» (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤) https://tinyurl.com/bdd5wvn4

[28] ក្រសួងយុត្តិធម៌កម្ពុជា ផ្សព្វផ្សាយតាមរយៈបណ្តាញសង្គមហ្វេសប៊ុក នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ (មើលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤) https://tinyurl.com/mr2dfh9e

[29] ម.ស.ម.ក, គោលដៅយុត្តិធម៌, API, អាដហុក, តម្លាភាពកម្ពុជា និង IFEX «របាយការណ៍រួមស្តីពីសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា» (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) https://www.sithi.org/km/tmp/publication/view/2018-07-12-3rd-cycle-of-upr-report-on-the-access-to-justice ម.ស.ម.ក «ការអនុវត្តនៃការពិនិត្យជាសកលតាមពេលកំណត់៖ "ក្នុងអំឡុងពីរឆ្នាំ» (ខែមករា ឆ្នាំ២០២១), https://tinyurl.com/yjbunsnz

[30] ម.ស.ម.ក «តារាងសង្កេតការណ៍សវនាការនៃបណ្តឹងឧទ្ធរណ៍» https://sithi.org/km/tmp/publication/view/2021-01-01-appeal-hearing-monitoring-checklist

- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិមានមេធាវី និងសិទ្ធិមានវត្តមាននៅពេលសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិមិនត្រូវបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង
- សិទ្ធិបង្ហាញភស្តុតាង (រួមមានសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ
- សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់

ក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមទ្រទ្រង់ក្នុងន័យស្ថាបនា ម.ស.ម.ក បានណែនាំ និងពន្យល់អំពីតារាងសង្កេតការណ៍សវនាការ និងសកម្មភាពសង្កេតសវនាការរបស់ខ្លួនដល់តំណាងតុលាការ ព្រមទាំងក្រសួងយុត្តិធម៌។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធមួយទំព័រភ្ជាប់ជាមួយតារាងសង្កេតការណ៍សវនាការ សម្រាប់ប្រើនៅក្នុងសវនាការពាក់ព័ន្ធនឹងកុមារ។ ផ្អែកលើការពិចារណាអំពីលក្ខណៈសង្ខេបរបស់តារាងសង្កេតការណ៍សវនាការ ម.ស.ម.ក បានចងក្រងគោលការណ៍ណែនាំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ(«គោលការណ៍ណែនាំស្តីអំពីតារាងសង្កេតការណ៍សវនាការ» [31] ដើម្បីផ្តល់នូវការយល់ដឹងអំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរនីមួយៗ ដើម្បីធានាឱ្យមានការបកស្រាយដូចគ្នាទាំងអស់។ អ្នកសង្កេតសវនាការក៏បានទទួលនូវឯកសារក្របខ័ណ្ឌច្បាប់ដែលរៀបរាប់អំពីច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនានាទុកជាមូលដ្ឋានសម្រាប់បញ្ជាក់ពីសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការ។

ម.ស.ម.ក បានយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិប្តឹងឧទ្ធរណ៍[32] រួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលបានការសង្កេតលើការពិនិត្យសំណុំរឿងឡើងវិញផងដែរ។ ម្យ៉ាងវិញទៀត ការពិនិត្យឡើងវិញនៃបណ្តឹងឧទ្ធរណ៍ត្រូវតែពាក់ព័ន្ធទាំងទិដ្ឋភាពផ្នែកច្បាប់ ភស្តុតាងនៃការផ្តន្ទាទោសទោស និងការកាត់ទោសបុគ្គលនោះ។[33] ពោលគឺត្រូវផ្តល់នូវ «ការវាយតម្លៃពេញលេញលើភស្តុតាង និងកិច្ចដំណើរការជំនុំជម្រះ។[34] ជាចុងក្រោយ ម.ស.ម.ក ប្តេជ្ញាចិត្តអនុវត្តតាមគោលការណ៍អន្តរជាតិក្នុងការសង្កេតសវនាការ[35] និងបានបង្កើតក្រមសីលធម៌ឡើង («ក្រមសីលធម៌») សម្រាប់អ្នកសង្កេត

---

[31] ម.ស.ម.ក «គោលការណ៍ណែនាំស្តីពីតារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍របស់ ម.ស.ម.ក» https://tinyurl.com/ywr3twde

[32] ក.អ.ស.ព.ន មាត្រា ១៤ (៥) និ ក្រមនិតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥។

[33] គណៈកម្មាធិការសិទ្ធិមនុស្ស «សេចក្តីពន្យល់ទូទៅលេខ ៣២ – មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌» (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧), CCPR/C/GC/៣២ វាក្យខណ្ឌ ៤៨ https://tinyurl.com/ymw9vvcs

[34] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥ *VP Domukovsky et al. និងប្រទេសហ្សកហ្ស៊ី* (ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៨) *GAOR*, A/៥៣/៤០ (លេខ II), ទំព័រ ១១១ វាក្យខណ្ឌ។ ១៨.១១ https://tinyurl.com/mvntuakv

[35] អង្គការលើកលែងទោសអន្តរជាតិ « សៀវភៅណែនាំស្តីអំពីការជំនុំជម្រះដោយយុត្តិធម៌ បោះពុម្ពលើកទីពីរ» (ឆ្នាំ២០១៤) https://tinyurl.com/nnhppm6b ; គណៈកម្មាធិការមេធាវីសិទ្ធិមនុស្ស « តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌៖ មគ្គុទ្ទេសក៍ជាមូលដ្ឋានស្តីពីបទដ្ឋាន និងការអនុវត្តច្បាប់» (ឆ្នាំ២០០០) https://tinyurl.com/y9ymx3z7 អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) «

សវនាការរបស់ខ្លួន។[36] ក្រមសីលធម៌គូសបញ្ជាក់អំពីកាតព្វកិច្ចនៃការមិនជ្រៀតជ្រែក ផ្អែកលើមូលដ្ឋាននៃការពិត និង រក្សាការសម្ងាត់ដែលអ្នកសង្កេតសវនាការត្រូវគោរពតាម។

ការសង្កេតសវនាការរបស់ ម.ស.ម.ក នៅតុលាការមិនបានកំណត់លើសវនាការជាក់លាក់ណាមួយឡើយ។ សវនាការដែលត្រូវសង្កេតត្រូវបានជ្រើសរើសដោយឥតព្រាងទុក ផ្អែកលើកាលវិភាគរបស់តុលាការជាមូលដ្ឋានដើម្បី ធានាថាដំណើរការប្រមូលទិន្នន័យគឺមិនលំអៀង និងមានភាពត្រឹមត្រូវ។ នៅពេលអ្នកសង្កេតសវនាការ សង្កេតសវនាការ គឺថារាល់ព័ត៌មានត្រូវបានកត់ត្រាដោយផ្ទាល់ទៅក្នុងតារាងសង្កេតការណ៍សវនាការ។ ទិន្នន័យដែលប្រមូលបាន កម្រិតត្រឹមព័ត៌មានដែលដែលទទួលបាននៅក្នុងដំណើរការសវនាការតែប៉ុណ្ណោះ គ្មានការសម្ភាសបន្ថែម ឬការពិភាក្សា បន្ថែមណាមួយត្រូវបានធ្វើឡើងនោះទេ លើកលែងតែនៅពេលអ្នកសង្កេតសវនាការត្រូវស្វែងរកព័ត៌មានទាក់ទងនឹង សាលក្រមដែលមិនបានប្រកាសនៅថ្ងៃសវនាការ ដោយលើកពេលប្រកាសទៅថ្ងៃក្រោយជំនួសវិញ។ ក្រោយបញ្ចប់ សវនាការនីមួយៗ ទិន្នន័យដែលប្រមូលបានត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យសង្កេតសវនាការរបស់ ម.ស.ម.ក («ប្រព័ន្ធផ្ទុកទិន្នន័យ»)។[37]

ម.ស.ម.ក បានវិភាគទិន្នន័យសវនាការដែលបានកត់ត្រានៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ និងបានកំណត់ចំណុច វិជ្ជមាន ក៏ដូចជាចំណុចដែលត្រូវធ្វើឱ្យប្រសើរក្នុងសវនាការនីមួយៗ។ ក្នុងពេលអនុវត្តសកម្មភាពសង្កេតសវនាការ ប្រព័ន្ធផ្ទុកទិន្នន័យនឹងត្រូវបានប្រើប្រាស់ដើម្បីធ្វើការវិភាគប្រៀបធៀប និងដើម្បីកំណត់និន្នាការនៃការអនុវត្តរបស់ តុលាការ កែលម្អចំណុចដែលមិនទាន់ប្រសើរ និងកំណត់អនុសាសន៍បន្ថែម។

សម្រាប់គោលបំណងនៃការវិភាគនេះ ម.ស.ម.ក នឹងចាត់ទុកថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានគោរព ប្រសិនបើសិទ្ធិនេះទទួលបានការគោរពយ៉ាងហោចណាស់ចំនួន ៨០% នៃសវនាការដែលបានសង្កេត ក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ ទោះបីយ៉ាងនេះក្តី ក្នុងករណីដែលមានការបំពានទៅលើសិទ្ធិដែលមិនអាច ធ្វើបដិប្បញ្ញត្តិបាន និងសិទ្ធិដាច់ខាត (សូមមើលទំព័រទី៦៦) ម.ស.ម.ក នឹងកំណត់ថាសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌មិនត្រូវបានគោរពដោយមិនផ្អែកលើចំនួននៃភាគរយនោះឡើយ។ ខុសពីអំឡុងពេលនៃការធ្វើរបាយ ការណ៍មុនៗ សម្រាប់របាយការណ៍នេះ ម.ស.ម.ក មិនបញ្ចូលទិន្នន័យដែលពាក់ព័ន្ធនឹងការពន្យល់ប្រាប់សិទ្ធិមាន មេធាវី និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសនោះទេ ដើម្បីវាយតម្លៃថាតើសិទ្ធិទាំងនោះត្រូវបានគោរព ដោយតុលាការគោលដៅ។ នេះដោយសារតែនៅក្នុងច្បាប់កម្ពុជា ការទទួលខុសត្រូវក្នុងការពន្យល់ប្រាប់សិទ្ធិទាំងនេះ មិនមែនជាទំនួលខុសត្រូវរបស់ចៅក្រមសាលាឧទ្ធរណ៍ឡើយ។

ម.ស.ម.ក ធានាជានិច្ចថា សាលាឧទ្ធរណ៍ទាំងអស់មានឱកាសក្នុងការផ្តល់ជាតុចូលរបស់ខ្លួនលើរបកគំហើញ ពីការសង្កេតសវនាការរបស់ ម.ស.ម.ក មុនពេលរបាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយ។ នៅចុងឆ្នាំ២០២២ ម.ស. ម.ក បានចាប់ផ្តើមកិច្ចប្រជុំប្រចាំត្រីមាសជាមួយតុលាការគោលដៅ ដើម្បីបង្ហាញលទ្ធផលដែលបានរកឃើញពីសកម្ម ភាពសង្កេតសវនាការរបស់ខ្លួន និងសុំការបំភ្លឺផ្សេងៗ ប្រសិនបើចាំបាច់។ ក្នុងអំឡុងពេលធ្វើកិច្ចប្រជុំទាំងនេះ តុលាការ

---

ការសង្កេតសវនាការជំនុំជម្រះ៖ សៀវភៅណែនាំយោងសម្រាប់អ្នកប្រតិបត្តិ» (ឆ្នាំ២០០៨) https://tinyurl.com/2p88e64s ; គណៈកម្មាធិការ អ្នកច្បាប់អន្តរជាតិ « ការសង្កេតការណ៍ការជំនុំជម្រះ (ឆ្នាំ២០០២) https://tinyurl.com/3a3b3u9r

[36] ម.ស.ម.ក «ក្រមសីលធម៌អ្នកសង្កេតសវនាការ» https://tinyurl.com/3fxvhxz6

[37] ម.ស.ម.ក «ប្រព័ន្ធផ្ទុកទិន្នន័យសង្កេតសវនាការ របស់ម.ស.ម.ក» https://tinyurl.com/5549dd44

បានស្វាគមន៍ចំពោះការរួមចំណែក និងការខិតខំប្រឹងប្រែងរបស់ ម.ស.ម.ក ក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ម.ស.ម.ក  ក៏សូមថ្លែងអំណរគុណដល់តុលាការទាំងអស់ នូវរាល់កិច្ចសហការនានា និងការបន្តកិច្ចសន្ទនាដ៏មានសារៈសំខាន់នេះ។

សេចក្ដីព្រាងរបាយការណ៍ចុងក្រោយនេះក៏ត្រូវបញ្ជូនទៅប្រធានតុលាការ និងអគ្គព្រះរាជអាជ្ញាអមតុលាការគោលដៅទាំងអស់ ដើម្បីពិនិត្យ ផ្ដល់យោបល់ និងអនុសាសន៍។ ម.ស.ម.ក បានទទួលធាតុចូលពីតុលាការក្នុងអំឡុងពេលធ្វើកិច្ចប្រជុំពិគ្រោះយោបល់នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ (សាលាឧទ្ធរណ៍បាត់ដំបង), ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ (សាលាឧទ្ធរណ៍ត្បូងឃ្មុំ), ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ (សាលាឧទ្ធរណ៍ព្រះសីហនុ) និងសាលាឧទ្ធរណ៍រាជធានីភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក តាមរយៈលិខិតលេខ ៧០៦ របឧ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤។ ធាតុចូលរបស់តុលាការទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ ដើម្បីរំលេចបញ្ហាប្រឈមដែលអ្នកជំនាញផ្នែកយុត្តិធម៌កំពុងចួបប្រទះ។ ម.ស.ម.ក ក៏បានផ្ញើរបាយការណ៍ព្រាងនេះទៅកាន់ក្រសួងយុត្តិធម៌នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៤ ផងដែរ។

## ២.និន្នាការទូទៅ

ផ្នែកនៃរបាយការណ៍នេះ កំណត់ពីទិន្នន័យដើមដែលបានកត់ត្រាក្នុងតារាងសង្កេតការណ៍សវនាការចំនួន ៧៧២ ដែលបានសង្កេតនៅតុលាការចំនួន ៤ នៅចន្លោះថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ ទិន្នន័យនេះនឹងត្រូវបានវិភាគនៅក្នុងរបាយការណ៍ទាំងមូល។

*តួលេខទី១៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតក្នុងឆ្នាំ២០២៣*

| សាលាឧទ្ធរណ៍ | ភ្នំពេញ | បាត់ដំបង | ព្រះសីហនុ | ត្បូងឃ្មុំ | សរុប |
|---|---|---|---|---|---|
| ចំនួនសំណុំរឿង | ៣៣៦ | ២៤១ | ៧៥ | ១២០ | ៧៧២ |
| ចំនួនបទឧក្រិដ្ឋ[38] | ១៤៥ | ៧៩ | ៣២ | ៣៦ | ២៩២ |
| ចំនួនបទមជ្ឈិម[39] | ១៨៦ | ១៥៨ | ៤២ | ៨២ | ៤៦៨ |
| ចំនួនបទលហុ[40] | ៥ | ៤ | ១ | ២ | ១២ |
| ចំនួនជនជាប់ចោទ | ៤៦០ | ៣៤៦ | ១៣៦ | ១៧៦ | ១,១១៨ |
| ចំនួនកុមារទំនាស់នឹងច្បាប់ | ៧ | ១៧ | ២ | ០ | ២៦ |
| ចំនួនជនជាប់ចោទជាស្ត្រី | ៦៩ | ៦៤ | ១៥ | ៣៣ | ១៨១ |

ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន (មេធាវីការពារ) និងដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី (ទាំងពីរភាគីទាក់ទងនឹងបញ្ហារដ្ឋប្បវេណី) អាចប្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលចេញដោយសាលាដំបូង។[41] តួលេខទី២ បង្ហាញថាបណ្តឹងឧទ្ធរណ៍ភាគច្រើន (៨៥,៩%) ត្រូវបានប្តឹងដោយភាគីជនជាប់ចោទ។

---

[38] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពីប្រាំឆ្នាំ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៦)។

[39] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៦ ថ្ងៃ និងរហូតដល់ប្រាំឆ្នាំ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៧)។

[40] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារតិចជាង ឬស្មើប្រាំមួយថ្ងៃ ឬពិន័យជាប្រាក់ប៉ុណ្ណោះ (ក្រមព្រហ្មទណ្ឌ, មាត្រា ៤៨)។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥។

*តួលេខទី២៖ ភាគីដែលបានប្ដឹងឧទ្ធរណ៍នៅក្នុងសវនាការដែលបានសង្កេត នៅឆ្នាំ២០២៣*[42]




តារាងខាងក្រោមនេះ គូសបញ្ជាក់នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព (ពណ៌បៃតង) និងសិទ្ធិដែលមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ (ពណ៌ទឹកក្រូច)។ ចំពោះសញ្ញាព្រួញចង្អុលឡើងលើ (↑) សំដៅលើសិទ្ធិដែលត្រូវបានគោរពលើកដំបូងក្នុងឆ្នាំ២០២៣ ដែលបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់បើធៀបនឹងរយៈពេលនៃរបាយការណ៍មុន។ រីឯសញ្ញាព្រួញចង្អុលចុះក្រោម (↓) បង្ហាញពីសិទ្ធិដែលត្រូវបានគោរពក្នុងឆ្នាំ២០២២ ប៉ុន្តែមិនបានគោរពពេញលេញនៅឆ្នាំ២០២៣ ទេ ដែលនេះបង្ហាញពីការខកខាននូវការគោរពតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ដូចឆ្នាំកន្លងមក។ ដោយឡែក សម្រាប់ពណ៌ប្រផេះបង្ហាញថា ម.ស.ម.ក មិនអាចប្រមូលទិន្នន័យគ្រប់គ្រាន់ ដើម្បីវាយតម្លៃថាតើសិទ្ធិជាក់លាក់ណាមួយត្រូវបានគោរព ឬយ៉ាងណា។

*តួលេខទី៣៖ការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗក្នុងឆ្នាំ២០២៣ដោយតុលាការទាំងបួន*

| សាលាឧទ្ធរណ៍ / សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ | ភ្នំពេញ | បាត់ដំបង | ព្រះសីហនុ | ត្បូងឃ្មុំ |
|---|---|---|---|---|
| សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី | | | | |
| សិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈ | | | | |
| សិទ្ធិមានមេធាវី | | | ↑ | |
| សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ | ↑ | ↓ | | |

42 ទិន្នន័យនេះគឺផ្អែកលើចំនួនសំណុំរឿងសរុបដែលត្រូវបានសង្កេតយក្នុងឆ្នាំ២០២៣ (៧៧២)។

| | | | | |
|---|---|---|---|---|
| សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ | | | ↓ | |
| សិទ្ធិមានវត្តមាននៅពេលសវនាការ | | | ↑ | ↓ |
| សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល | | | | |
| សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស | | | ↑ | |
| សិទ្ធិមានសេរីភាព | | | | |
| សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង | | | | |
| សិទ្ធិបង្ហាញភស្តុតាង | | | | |
| សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ | | | | |
| វិជ្ជាជីវៈរបស់ចៅក្រម | | | | |
| សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ | | | | |

ផ្នែកខាងក្រោមនេះ វិភាគលើការអនុវត្តរបស់តុលាការនូវជាតុផ្សំពាក់ព័ន្ធផ្សេងៗគ្នានៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ សម្រាប់គោលបំណងនៃការវិភាគ ជាដំបូង របាយការណ៍នឹងបង្ហាញអំពីទិដ្ឋភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព ហើយបន្ទាប់មកបង្ហាញពីការអនុវត្តដែលមិនទាន់គោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## ៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព ដោយតុលាការទាំងអស់

### ៣.១.សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ខ) | មាត្រា ៤៨, ៩៨, ១៤៥, ២៥៩ និង ៣១៩ | មាត្រា ២៩ |

ជនណាដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ គួរត្រូវបានផ្តល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។ រយៈពេលដែល "គ្រប់គ្រាន់" គឺអាស្រ័យលើកាលៈទេសៈជាក់ស្តែងនៃសំណុំរឿងនីមួយៗ។[43] ទោះជាយ៉ាងនេះក្តី គោលការណ៍ណែនាំបានកំណត់ថា ជនជាប់ចោទត្រូវតែមានលទ្ធភាពរៀបចំឱ្យបានត្រឹមត្រូវ ដើម្បីតតាំងនឹងភស្តុតាងរបស់អយ្យការ ធ្វើការស៊ើបអង្កេត និងបង្ហាញសាក្សីការពារក្តី។ នេះជាតួនាទីរបស់មេធាវីការពារក្តីក្នុងការស្នើសុំពន្យារពេលសវនាការជំនុំជម្រះ ប្រសិនបើខ្លួនយល់ឃើញថា ពេលវេលាសម្រាប់ការរៀបចំមេធាវីការពារក្តីមិនគ្រប់គ្រាន់។[44]

មធ្យោបាយចាំបាច់សម្រាប់រៀបចំការពារក្តី រួមមានការទទួលបានឯកសារសំណុំរឿង និងភស្តុតាងដើម្បីឱ្យជនជាប់ចោទដឹងច្បាស់អំពីបទចោទប្រកាន់លើពួកគេ ហើយដើម្បីឱ្យពួកគេអាចផ្តល់ការណែនាំគ្រប់ជ្រុងជ្រោយដល់មេធាវីរបស់ខ្លួន។[45] ជាពិសេស រាប់បញ្ចូលទាំងការទទួលបានភស្តុតាងទាំងឡាយដែលព្រះរាជអាជ្ញាគ្រោងនឹងបង្ហាញនៅក្នុងតុលាការ និងភស្តុតាងដោះបន្ទុក។ នៅដំណាក់កាលនៃបណ្តឹងឧទ្ធរណ៍នេះ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេនៅក្នុងការប្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាព ជនជាប់ចោទមានសិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់សាលាដំបូង ដែលមានសំអាងហេតុត្រឹមត្រូវ និងកំណត់ហេតុនៃការជំនុំជម្រះ ដើម្បីរៀបចំសំណុំរឿងរបស់ខ្លួន។[46] លើសពីនេះ ជនជាប់ចោទត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីទំនាក់ទំនងជាមួយមេធាវីដែលខ្លួនជ្រើសរើសដោយផ្ទាល់។ បទប្បញ្ញត្តិនេះធានានូវការគោរពចំពោះគោលការណ៍ស្មើភាពគ្នា និងតម្រូវឱ្យជនជាប់ចោទមានសិទ្ធិទទួលបាន

[43] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

[44] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

[45] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៣។

[46] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៩ *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១៧៩៧/២០០៨, *វ៉ាង Mennen និងប្រទេសហូឡង់* (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០), CCPR/C/៩៩/D/១៧៩៧/២០០៨, វាក្យខណ្ឌ ៨.២.-៨.៤, https://tinyurl.com/z2x7tu9e

មេធាវីភ្លាមៗ។ លើសពីនេះ ត្រូវតែមានមធ្យោបាយដែលអាចអនុញ្ញាតឱ្យមានទំនាក់ទំនងដោយសម្ងាត់រវាងជនជាប់ចោទ និងមេធាវីរបស់ពួកគេ។[47]

ទោះបីជា ម.ស.ម.ក មិនទទួលបាននូវព័ត៌មានចាំបាច់ទាំងអស់ដែលពាក់ព័ន្ធនឹងការសង្កេតសវនាការលើបណ្តឹងឧទ្ធរណ៍ ដើម្បីវាយតម្លៃថាតើជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តី និងទំនាក់ទំនងជាមួយមេធាវីក៏ដោយ ក៏មានព័ត៌មានដែលបង្ហាញថាសិទ្ធិទាំងនេះត្រូវបានគោរពដោយតុលាការគោលដៅទាំងបួនដែរ។ បន្ថែមពីនេះ គ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោម ៦៥៦ នាក់ ដែលមេធាវីការពាររបស់ពួកគេត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះឡើយ។ ជនជាប់ចោទទាំងនេះទទួលបានមេធាវីនៅមុនដំណើរការនីតិវិធី ហើយមិនមានសំណុំរឿងណាមួយដែលមេធាវីរបស់ជនជាប់ចោទ បានលើកឡើងពីបញ្ហាកង្វះខាតពេលវេលាក្នុងការរៀបចំការពារក្តីនោះទេ។ ម.ស.ម.ក ស្វាគមន៍សាលាឧទ្ធរណ៍ទាំងនោះដែលបានគោរពយ៉ាងខ្ជាប់ខ្ជួននូវសិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីតាំងពីឆ្នាំ២០១៤។

គ្មានជនជាប់ចោទណាម្នាក់ដែលមេធាវីរបស់ខ្លួនត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះឡើយ។

មិនមានមេធាវីការពារឱ្យជនជាប់ចោទណាមួយក្នុងចំណោម ៦៥៦ នាក់ បានលើកពីបញ្ហាកង្វះពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តីនោះទេ។

## ៣.២.សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ |
| មាត្រា ១៤(១) | មាត្រា ៣១៧ | មាត្រា ៧ |

[47] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៤ សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវី" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-adequate-time-and-facilities-to-prepare-a-defense-and-the-right-to-speak-with-a-lawyer

សិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈមានន័យថា សេចក្តីសម្រេចដែលបានបំពេញតាមនិតិវិធីច្បាប់ត្រូវតែធ្វើឡើងជាសាធារណៈ។ សិទ្ធិនេះគឺជាគន្លឹះក្នុងការធានានូវតម្លាភាព និងគណនេយ្យភាព។[48] យោងតាមមាត្រា ១៤(១) នៃ ក.អ.ស.ព.ន ទោះបីជានៅពេលដែលសាធារណៈជនមិនត្រូវបានឱ្យចូលរួមក្នុងសវនាការក៏ដោយ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុផ្លូវច្បាប់ ត្រូវតែបង្ហាញជាសាធារណៈ។[49] សេចក្តីសម្រេចជាសាធារណៈ ជំរុញឱ្យមានតម្លាភាព និងគណនេយ្យភាព ដែលនាំឱ្យចៅក្រមធ្វើសកម្មភាពដោយភាពហ្មត់ចត់បំផុត និងធានាឱ្យមានការផ្តល់យុត្តិធម៌ដោយស្មើភាព។[50] វិធាននេះមានការលើកលែងតែមួយចំនួនប៉ុណ្ណោះ ដូចជានៅពេលសេចក្តីសម្រេចមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈដើម្បីផលប្រយោជន៍របស់កុមារ។[51]

ក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ សិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈត្រូវបានគោរពដោយតុលាការចំនួនបីក្នុងចំណោមតុលាការទាំងបួន នៅគ្រប់សំណុំរឿងទាំងអស់ សម្រាប់ព័ត៌មានដែលទទួលបាន (២២៤ ក្នុងចំណោម ៧៧២ សំណុំរឿង)។ ម.ស.ម.ក ស្វាគមន៍ចំពោះសាលាឧទ្ធរណ៍ទាំងនោះបានគោរពយ៉ាងជាប់ជាប្រចាំចំពោះសិទ្ធិនេះ ចាប់តាំងពីឆ្នាំ ២០១៤ មកសម្រាប់សាលាឧទ្ធរណ៍ភ្នំពេញ។ ម.ស.ម.ក អាចស្តាប់សាលដីកាដែលបានប្រកាសតែចំនួនបីប៉ុណ្ណោះនៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**។ ទោះបីជាសាលដីកាទាំងនេះត្រូវបានប្រកាសជាសាធារណៈក៏ដោយ ក៏ម.ស.ម.ក មិនអាចវាយតម្លៃថាតើតុលាការបានគោរពសិទ្ធិនេះជាប់ជាប្រចាំដែរឬទេ ក្នុងឆ្នាំ២០២៣ ដោយសារខ្វះទិន្នន័យលើសំណុំរឿងចំនួន ១១៧ ដែលមិនបានស្ដាប់នោះ។

នៅក្នុងសំណុំរឿងដែលបានសង្កេតទាំងអស់ចំនួន ២២៤ ដែលសាលដីកាត្រូវបាន ប្រកាសជាសាធារណៈ និងមានវត្តមានអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ។

[48] សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក “សិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈ និងមានសំអាងហេតុ” (ខែកញ្ញា ឆ្នាំ២០២២)https://sithi.org/km/fair-trial-rights/the-right-to-a-public-judgment-and-the-right-to-a-reasoned-judgment

[49] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

[50] សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ"។

[51] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

## ៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដោយតុលាការមួយចំនួន

### ៤.១. សិទ្ធិមានមេធាវី[52]

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | |
|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ឃ) | មាត្រា ៣៨ | មាត្រា ១៤៣, ៣០០, ៣០១ & ៣៨៩ | មាត្រា ៦, ៥០ និង ៥១ |

ការរងការចោទប្រកាន់ពីបទល្មើស តម្រូវឱ្យមានដំណើរការធ្វើតាមនីតិវិធីច្បាប់ទៅតាមប្រភេទនៃសំណុំរឿងនីមួយៗ ដែលសំណុំរឿងខ្លះមានភាពងាយស្រួល និងខ្លះទៀតមានភាពស្មុគស្មាញអាស្រ័យលើអង្គហេតុនៃសំណុំរឿងទាំងនោះ។ ដើម្បីធានាថាសិទ្ធិរបស់ជនជាប់ចោទត្រូវបានការពារយ៉ាងពេញលេញក្នុងអំឡុងពេលដំណើរការនីតិវិធីព្រហ្មទណ្ឌ ពួកគេគួរតែត្រូវទទួលបានមេធាវីការពារសិទ្ធិដែលមានជំនាញវិជ្ជាជីវៈ មានសមត្ថភាពពន្យល់អំពីសិទ្ធិរបស់ពួកគេ និងបទចោទប្រកាន់មកលើខ្លួន ណែនាំពួកគេតាមរយៈដំណើរការកាត់ក្ដី និងតំណាងឱ្យផលប្រយោជន៍របស់ពួកគេនៅក្នុងតុលាការ។ ប្រសិនបើជនជាប់ចោទមិនមានលទ្ធភាពស្វែងរកមេធាវីដោយខ្លួនឯងបានទេ អាជ្ញាធរពាក់ព័ន្ធគួរគប្បីផ្ដល់មេធាវីដោយមិនគិតថ្លៃ ប្រសិនបើមានការតម្រូវដោយសារផលប្រយោជន៍យុត្តិធម៌ (ឧទាហរណ៍ ស្ថានទម្ងន់នៃបទល្មើស លទ្ធភាពជាក់ស្ដែងដែលមានឱកាសឈ្នះបណ្ដឹងឧទ្ធរណ៍)។[53] នៅក្នុងប្រទេសកម្ពុជា ជាការចាំបាច់សម្រាប់ជនជាប់ចោទដែលត្រូវតែមានមេធាវីការពារ ប្រសិនបើជនជាប់ចោទពីបទឧក្រិដ្ឋ ឬប្រសិនបើពួកគេជាអនីតិជន តែមិនមែនជាកាតព្វកិច្ចត្រូវតែមានមេធាវីការពារនោះទេ ប្រសិនបើជនជាប់ចោទពីបទមជ្ឈិម (លុះត្រាតែពួកគេជាអនីតិជន ឬកុមារទំនាស់នឹងច្បាប់)។ យ៉ាងណាក៏ដោយ បុគ្គលនោះនៅតែមានជម្រើស ប្រសិនបើពួកគេចង់បានមេធាវី ប៉ុន្តែចំណុចនេះមិនមែនជាបន្ទុករបស់តុលាការនោះទេ។

---

[52] សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក “សិទ្ធិមានវត្តមានក្នុងសវនាការ និងសិទ្ធិការពារខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងផ្លូវច្បាប់” (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-be-present-at-trial-and-the-right-to-defend-oneself-in-person-or-through-legal-representation

[53] ក.អ.ស.ព.ន, មាត្រា ១៤(៣)(ឃ); គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅ លេខ៣២ វាក្យខណ្ឌ ៣៨។

*តួលេខទី៤៖ ភាគរយនៃជនជាប់ចោទមានមេធាវីការពារសិទ្ធិនៅឆ្នាំ ២០២៣ នៅតាមតុលាការទាំង៤*[54]




នៅឆ្នាំ២០២៣ មានជនជាប់ចោទ ៥៨,៧% ក្នុងសំណុំរឿងដែលបានសង្កេត (៦៥៦ ក្នុងចំណោម ១.១១៨ នាក់) មានមេធាវីការពារ គឺមានការធ្លាក់ចុះបើធៀបនឹងឆ្នាំ ២០២២ មានដល់ ៦៦,៧%។ សិទ្ធិនេះមានសារៈសំខាន់ តែសិទ្ធិមានមេធាវីមានការថយចុះមួយឆ្នាំទៅមួយឆ្នាំ ដែលជាតួលេខគឺមានជនជាប់ចោទជាងបួននាក់ក្នុងចំណោមដប់នាក់មិនមានមេធាវីការពារនោះទេ ទោះបីជាករណីកើតឡើងចំពោះតែក្នុងបទមជ្ឈិម និងបទលហុក៏ដោយក៏ជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ដែរ។ ទោះបីជាតុលាការចំនួនពីរត្រូវបានមើលឃើញថាការគោរពសិទ្ធិមានមេធាវីមានការថយចុះ ក្នុងអំឡុងពេលធ្វើរបាយការណ៍ក៏ដោយ ក៏ ម.ស.ម.ក សាទរចំពោះសាលាឧទ្ធរណ៍ព្រះសីហនុ ដែលបានគោរពសិទ្ធិមានមេធាវីនៅក្នុងឆ្នាំ២០២៣ ដែលនេះជាករណីមិនធ្លាប់មាននៅតុលាការគោលដៅណាមួយទេចាប់តាំងពីឆ្នាំ២០១៤/២០១៥ មក។

នៅក្នុងការកំណត់បទចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទ ជនជាប់ចោទគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានអំពីជំនួយផ្នែកច្បាប់ ប្រសិនបើពួកគេមិនមានជំនួយផ្នែកច្បាប់។[55] ទោះបីច្បាប់កម្ពុជាដាក់ការទទួលខុសត្រូវនេះលើមន្ត្រីនគរបាលយុត្តិធម៌ ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាក៏ដោយ[56] ក៏ ម.ស.ម.ក លើកទឹកចិត្តដល់ចៅក្រមសាលាឧទ្ធរណ៍ឱ្យអនុវត្តតាមនូវការប្រតិបត្តិល្អពោលគឺមិនត្រឹមតែផ្តល់ព័ត៌មានអំពីសិទ្ធិមានមេធាវីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពន្យល់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារសិទ្ធិនេះផងដែរ ដើម្បីឱ្យពួកគេការពារខ្លួនដោយផ្ទាល់ ឬតាមរយៈមេធាវីផងដែរ។ ក្នុងឆ្នាំ២០២៣ ចៅក្រមបានធ្វើបែបនេះក្នុងសំណុំរឿងពាក់ព័ន្ធចំនួន ៤១,៣% ដែលជនជាប់ចោទបានចូលរួមសវនាការដែលត្រូវបានសង្កេត (១២១ ក្នុងចំណោម ២៩២ នាក់)។ តួលេខនេះបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងឆ្នាំ២០២២ ដែលមានតែ ១៨,៣% ប៉ុណ្ណោះ។ ដូចគ្នានេះដែរ ភាគរយនៃ

---

[54] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (១.១១៨ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៧៧២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ ២០២៣។

[55] ក.អ.ស.ព.ន មាត្រា ១៤(៣)(ឃ)។

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៦, ៤៨, ៩៧, ១៤៣, ៣០៤។

សំណុំរឿងដែលចៅក្រមមិនបានអានប្រាប់ និងពន្យល់អំពីសិទ្ធិមានមេធាវីនេះដល់ជនជាប់ចោទបានថយចុះពី ៤៨,៦% ក្នុងឆ្នាំ២០២២ មក ២៤% ក្នុងឆ្នាំ២០២៣។ ម្យ៉ាងវិញទៀត យ៉ាងហោចណាស់ជនជាប់ចោទត្រូវបានអានប្រាប់អំពីសិទ្ធិនេះមាន ៧៦% នៃសំណុំរឿងដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣ គឺកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានតែ ៥១,៤%។ ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក៏ដោយ ក៏នៅតែមានភាពខុសគ្នាទៅតាមតុលាការគោលដៅទាំងនោះដែរ។

*តួលេខទី៥ ៖ ភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទនូវសិទ្ធិរបស់ពួកគេក្នុងការទទួលបានមេធាវី ឬដើម្បីការពារខ្លួន ដោយតុលាការទាំងបួន*[57]




ជាចុងក្រោយ ៤៣,៣% នៃជនជាប់ចោទដែលមានមេធាវីការពារ (២៨៤ នាក់ក្នុងចំណោម ៦៥៦នាក់) ត្រូវបានការពារដោយមេធាវីឱ្យជនជាប់ចោទច្រើនជាងម្នាក់ ដែលជាការកើនឡើងចំនួនបួនភាគរយបើធៀបនឹងឆ្នាំមុន។ ស្ថានភាពដែលមេធាវីការពារជនជាប់ចោទច្រើននាក់ ពេលខ្លះអាចមានការសន្សំសំចៃលើការចំណាយ តែក៏បង្ហាញពីការព្រួយបារម្ភចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់បុគ្គលដែរ ឧទាហរណ៍នៅពេលដែលមេធាវីការពារជនជាប់ចោទច្រើននាក់ ឬមានភាពខុសគ្នា ឬផ្ទុយគ្នាពីស្ថានភាពរបស់ជនជាប់ចោទមួយទៅជនជាប់ចោទមួយទៀត។ ប្រសិនបើមេធាវីដែលការពារក្តីជនជាប់ចោទលើសពីម្នាក់នោះ ការផ្តល់មេធាវីការពារនឹងជះឥទ្ធិពលអវិជ្ជមានដល់គ្នា ដូច្នេះប៉ះពាល់ដល់ការការពារក្តីប្រកបដោយប្រសិទ្ធភាព និងប៉ះពាល់ការការពារឱ្យបានគ្រប់ជ្រុងជ្រោយអស់ពីសមត្ថភាពរបស់មេធាវី។ ដូច្នេះ ជនជាប់ចោទម្នាក់ៗគួរតែមានមេធាវីដាច់ដោយឡែក។[58] យ៉ាងណាក៏ដោយ គួរឱ្យសាទរដែរ ម.ស.ម.ក បានកត់សម្គាល់ថាមានទំនាស់ផលប្រយោជន៍តែពីរប៉ុណ្ណោះក្នុងឆ្នាំ២០២៣ គឺនៅសាលាឧទ្ធរណ៍ព្រះសីហនុ។

[57] ទិន្នន័យនេះគឺផ្អែកលើសំណុំរឿងដែលបានសង្កេតចំនួន ៦៨៥ សំណុំរឿងដែលយ៉ាងហោចណាស់មានជនជាប់ចោទម្នាក់មានវត្តមាននៅក្នុងសវនាការ (២៩១ សំណុំរឿងនៅសាលាឧទ្ធរណ៍ភ្នំពេញ ២២២ សំណុំរឿងនៅសាលាឧទ្ធរណ៍បាត់ដំបង, ៧៥ សំណុំរឿងនៅសាលាឧទ្ធរណ៍ព្រះសីហនុ និង ៩៧ សំណុំរឿងនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

[58] *សូមមើល* "គោលការណ៍ណែនាំស្តីពីតារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍របស់ ម.ស.ម.ក" ទំព័រ ៤៧។

*តួលេខទី៦៖ភាគរយនៃជនជាប់ចោទដែលមានមេធាវី ហើយមេធាវីការពារឱ្យជនជាប់ចោទច្រើនជាងម្នាក់នៅតាមតុលាការទាំងបួន*




## សាលាឧទ្ធរណ៍ភ្នំពេញ

គួរឱ្យកត់សម្គាល់ ភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារមានចំនួន ៦០,៩% នៅសាលាឧទ្ធរណ៍ភ្នំពេញ (២៨០ ក្នុងចំណោម ៤៦០) ក្នុងនោះ ១០០% នៃជនជាប់ចោទពីបទឧក្រិដ្ឋ (២០០ ក្នុងចំណោម ២០០ នាក់)មានមេធាវីការពារសិទ្ធិដែលនេះបង្ហាញថា តុលាការបានអនុវត្តពេញលេញតាមច្បាប់ជាតិដែលតម្រូវមានមេធាវីសម្រាប់បទឧក្រិដ្ឋ ប៉ុន្តែ ៧,២% នៃជនជាប់ចោទពីបទមជ្ឈិម(៨១ ក្នុងចំណោម ២៥០ នាក់) និង ២០% នៃជនជាប់ចោទពីបទលហុ(២ ក្នុងចំណោម ១០ នាក់)ប៉ុណ្ណោះ មានមេធាវីការពារសិទ្ធិមានន័យថា ៦៧,៦% នៃជនជាប់ចោទបទមជ្ឈិម(១៦៩ ក្នុងចំណោម ២៥០ នាក់) និង៨០% នៃជនជាប់ចោទពីបទលហុ(៨ ក្នុងចំណោម ១០ នាក់)មិនមានមេធាវីការពារសិទ្ធិ ហើយតាមការបញ្ជាក់របស់តុលាការគឺជនជាប់ចោទយល់ព្រមឱ្យតុលាការដំណើរការសវនាការរបស់គេមិនចាំបាច់មានមេធាវីការពារសិទ្ធិ គឺគេអាចការពារខ្លួនដោយខ្លួនឯងបាន។ តួលេខនេះថយចុះគួរឱ្យកត់សម្គាល់ពីឆ្នាំ២០២២ (៧៥,៦%) និងជាតួលេខទាបបំផុតដែលមិនធ្លាប់បានកត់ត្រាដោយ ម.ស.ម.ក នៅតុលាការនេះ។ ទោះបីជា ៣០,៧% នៃជនជាប់ចោទដែលមានមេធាវីការពារ (៨៦ ក្នុងចំណោម ២៨០ នាក់) បានការពារឱ្យជនជាប់ចោទច្រើនជាងម្នាក់ក្នុងឆ្នាំ២០២៣ ក៏ដោយ ក៏មិនបានរកឃើញមានទំនាស់ផលប្រយោជន៍ដែរ។ ម.ស.ម.ក កត់សម្គាល់ថា សិទ្ធិមានមេធាវីមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយនៅតុលាការនេះទេ លើកលែងតែភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារ មានចំនួន ៨៣,៩% នៅឆ្នាំ២០២១/២០២១៥។ ការរកឃើញទាំងនេះចង្អុលបង្ហាញពីតម្រូវការចាំបាច់សម្រាប់វិធានការបន្ទាន់ ដើម្បីធ្វើឱ្យប្រសើរឡើងជៀសវាងការថយចុះមិនធ្លាប់មានពីមុនមកដែលបានសង្កេតពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៣ នេះ ហើយយ៉ាងហោចណាស់ ការលើកកម្ពស់សិទ្ធិនេះមានកម្រិតដូចនឹងកំណត់ត្រាក្នុងឆ្នាំ២០១៤/២០១៥ ដែរ។

*តួលេខទី៧៖ ការវិវត្តគិតជាភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារនៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២៣)*[59]




ក្នុងអំឡុងពេលធ្វើបាយការណ៍នេះ ចៅក្រមបានអានប្រាប់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារអំពីសិទ្ធិរបស់ពួកគេក្នុងការការពារខ្លួនដោយផ្ទាល់ ឬតាមរយៈមេធាវីមានចំនួន ៧៥,២% នៃសំណុំរឿងពាក់ព័ន្ធដែលត្រូវបានសង្កេត (៧៩ ក្នុងចំណោម ១០៥ នាក់) គឺកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានត្រឹម ៦៣,៣%។ ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក៏ដោយ ចៅក្រមបានអនុវត្តល្អក្នុងការពន្យល់អំពីសិទ្ធិនេះមាន ១៧,១% (១៨ ក្នុងចំណោម ១០៥ នាក់) នៃសំណុំរឿងពាក់ព័ន្ធ ដោយថយចុះបន្តិចបើធៀបនឹងឆ្នាំ២០២២ (២២,៤%)។ ដើម្បីបង្កើនលទ្ធភាពនៃទទួលបាននូវសិទ្ធិមានមេធាវី ម.ស.ម.ក សូមស្នើដល់តុលាការធ្វើការពន្យល់ជាប្រចាំអំពីសិទ្ធិនេះដល់ជនជាប់ចោទដែលមិនមានមេធាវីការពារ ដើម្បីធានាថាពួកគេយល់ច្បាស់អំពីផលប៉ះពាល់ដែលអាចកើតមានចេញពីការលះបង់សិទ្ធិរបស់ពួកគេក្នុងការការពារដោយមេធាវី។ ក្នុងករណីដែលជនជាប់ចោទបង្ហាញថាខ្លួនចង់បានមេធាវីបន្ទាប់ពីការពន្យល់នេះ ការជំនុំជម្រះគួរតែត្រូវបានពន្យារពេលជាបន្ទាន់ និងមានការចាត់វិធានការ ដើម្បីជួយសម្រួលដល់ការទទួលបានការប្រឹក្សាផ្លូវច្បាប់ភ្លាមៗ រួមទាំងតាមរយៈគម្រោងជំនួយផ្នែកច្បាប់ដែលមានស្រាប់។

[59] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទ ១៣៥ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ១៦១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតក្នុងឆ្នាំ២០១៤/២០១៥។ ជនជាប់ចោទ ៤៣៩ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៥៥៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតក្នុងឆ្នាំ២០១៦/២០១៧, ជនជាប់ចោទ ២៤១ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៣១៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតក្នុងឆ្នាំ២០១៧/២០១៨, ជនជាប់ចោទ ២៦២ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតក្នុងឆ្នាំ២០១៨/២០១៩, ជនជាប់ចោទ ១៨៣ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ២៥៥ នាក់ ដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ២០៣ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៩/២០២០, ជនជាប់ចោទ ៨៩ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ១១៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតក្នុងឆ្នាំ២០២១, ជនជាប់ចោទ ២៦៦ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតក្នុងឆ្នាំ២០២២, និងជនជាប់ចោទ ២៨០ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៤៦០ នាក់ដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿង ៣៣៦ ដែលបានសង្កេតក្នុងឆ្នាំ២០២៣។

នៅខែសីហា ឆ្នាំ២០២០ តុលាការបានថ្លែងថាចៅក្រម និងមន្ត្រីតុលាការព្យាយាមជួយជនជាប់ចោទឱ្យទទួលបានជំនួយផ្នែកច្បាប់ក្នុងសំណុំរឿងមជ្ឈិម។ ទោះជាយ៉ាងណាក៏ដោយ តុលាការបានចង្អុលបង្ហាញថា ការដាក់ពាក្យស្នើសុំមេធាវី គឺមានការលំបាកសម្រាប់ជនក្រីក្រ ដោយសារតែមានការតម្រូវឱ្យផ្តល់លិខិតបញ្ជាក់ពីស្ថានភាពសេដ្ឋកិច្ចកម្រិតទាបរបស់ពួកគេ ជូនដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយសារតែគណៈមេធាវីប្រឈមនឹងបញ្ហាផ្នែកថវិកា ដូច្នេះជារឿយៗគណៈមេធាវីមានការឆ្លើយតបយឺតយ៉ាវទៅនឹងការស្នើសុំមេធាវីនេះ។ [60] នៅខែវិច្ឆិកា ឆ្នាំ២០២៣ អ្នកតំណាងមកពីតុលាការ និងមហាអយ្យការអមតុលាការបានទទួលស្គាល់ថា ជួនកាលចៅក្រមមិនបានអានប្រាប់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារអំពីសិទ្ធិនេះ។ ពួកគេបាននិយាយថា តុលាការនឹងរៀបចំកិច្ចប្រជុំជាមួយចៅក្រមទាំងអស់ និងណែនាំឱ្យធ្វើបែបនេះជាប្រចាំ។[61]

**សាលាឧទ្ធរណ៍បាត់ដំបង**

នៅក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នា សិទ្ធិមានមេធាវីបានគោរពមិនទាន់ពេញលេញនៅឡើយនៅសាលាឧទ្ធរណ៍បាត់ដំបង ដោយសារមានជនជាប់ចោទត្រឹមតែ ៥៣,៨% (១៨៦ ក្នុងចំណោម ៣៤៦ នាក់)ដែលមានមេធាវីការពារក្នុងសវនាការដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ក្នុងនោះ ១០០% នៃជនជាប់ចោទពីបទឧក្រិដ្ឋ (១១៨ ក្នុងចំណោម ១១៨ នាក់) មានមេធាវីការពារសិទ្ធិដែលនេះបង្ហាញថាតុលាការបានអនុវត្តពេញលេញតាមច្បាប់ជាតិដែលតម្រូវមានមេធាវីសម្រាប់បទឧក្រិដ្ឋ ប៉ុន្តែ ៣០,២% នៃជនជាប់ចោទពីបទមជ្ឈិម(៦៧ ក្នុងចំណោម ២២២ នាក់) និង១៦,៧% នៃជនជាប់ចោទពីបទលហុ(១ ក្នុងចំណោម ៦ នាក់) ប៉ុណ្ណោះមានមេធាវីការពារសិទ្ធិ មានន័យថា ៦៩,៨% នៃជនជាប់ចោទបទមជ្ឈិម(១៥៥ ក្នុងចំណោម ២២២ នាក់) និងមានចំនួន ៨៣,៣ % នៃជនជាប់ចោទពីបទលហុ(៥ ក្នុងចំណោម ៦ នាក់)មិនមានមេធាវីការពារសិទ្ធិ ហើយតាមចំនួបជាមួយតុលាការបានគូសបញ្ជាក់ជនជាប់ចោទយល់ព្រមឱ្យតុលាការដំណើរការសវនាការរបស់គេមិនចាំបាច់មានមេធាវីការពារសិទ្ធិ គឺគេអាចការពារខ្លួនដោយខ្លួនឯងបាន។ នេះជាការថយចុះដ៏គួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២២ តួលេខនេះមានចំនួន ៦១,៨%។ ទោះបីមេធាវីការពារជនជាប់ចោទមាន ៥៤,៣% (១០១ ក្នុងចំណោម ១៨៦ នាក់) បានការពារជនជាប់ចោទច្រើនជាងម្នាក់ក្នុងឆ្នាំ២០២៣ ក៏ដោយ ក៏មិនឃើញថាមានទំនាស់ផលប្រយោជន៍ដែរ។

គួរឱ្យសាទរ ចំពោះភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់ដល់ជនជាប់ចោទដែលមិនមានមេធាវីតំណាង អំពីសិទ្ធិរបស់ពួកគេក្នុងការការពារខ្លួនដោយផ្ទាល់ ឬតាមរយៈមេធាវី ចំនួនដល់ ៨០,៤% (៩០ ក្នុងចំណោម ១១២ នាក់) នៅឆ្នាំ២០២៣។ នេះគឺជាការកើនឡើងគួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងឆ្នាំ២០២២ ដែលតួលេខនេះមានត្រឹម ៤៣,៧៥% ប៉ុណ្ណោះ។ ដូចគ្នាដែរ ចៅក្រមបានអនុវត្តនូវការប្រតិបត្តិល្អដោយការពន្យល់អំពីសិទ្ធិនេះមានចំនួ ៦៦,១% នៃសំណុំរឿងពាក់ព័ន្ធ (៧៤ ក្នុងចំណោម ១១២ នាក់) គឺមានការកើនឡើងបើធៀបនឹងឆ្នាំ ២០២២ មានត្រឹម ១៦,៧% ដែលជាការគួរឱ្យស្វាគមន៍។ ដូច្នេះ ទោះបីជា ម.ស.ម.ក មិនចាត់ថ្នាក់ថាសិទ្ធិមានមេធាវីត្រូវបាន

[60] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយឯកឧត្តមប្រធាន និងឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ ឯកឧត្តមអគ្គព្រះរាជអាជ្ញា និងឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ព្រមទាំងឯកឧត្តមអគ្គលេខាធិការ និងឯកឧត្តមអគ្គលេខាធិការរងនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ឆ្នាំ២០១៨/២០១៩។

[61] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

គោរពដោយសាលាឧទ្ធរណ៍បាត់ដំបងក៏ដោយ ក៏ម.ស.ម.ក កត់សម្គាល់ដោយស្វាគមន៍ចំពោះការខិតខំប្រឹងប្រែងដែលបានធ្វើឡើង ដើម្បីធានាថាជនជាប់ចោទដែលមិនមានមេធាវីបានដឹង និងយល់ពីសិទ្ធិនេះ។ វិធានការបន្ថែមទៀតនោះគឺថា ការពន្យល់អំពីសិទ្ធិនេះគួរត្រូវបានអនុវត្តជាប្រចាំដើម្បីបង្កើនលទ្ធភាពនៃការទទួលបានសិទ្ធិមានមេធាវីរបស់ជនជាប់ចោទ។

នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមអនុប្រធានតុលាការបានលើកឡើងថា សំណើសុំមេធាវីត្រូវតែដាក់ទៅគណៈមេធាវីតាមរយៈក្រសួងយុត្តិធម៌។ ទោះបីជាឯកឧត្តមទទួលស្គាល់ថាដំណើរការនេះអាចត្រូវការចំណាយពេលវេលាយូរក៏ដោយ ឯកឧត្តមបានលើកឡើងថា គ្រប់តម្រូវការមេធាវីទាំងអស់គឺត្រូវបានបំពេញជូន។[62] នៅក្នុងខែមីនា ឆ្នាំ២០២៣ ឯកឧត្តមបានលើកឡើងថា សំណុំរឿងបទឧក្រិដ្ឋទាំងអស់ត្រូវបានជំនុំជម្រះដោយមានមេធាវី លើកលែងតែសំណុំរឿងទាំងនោះត្រូវបានតុលាការចាត់ថ្នាក់ឡើងវិញជាបទមជ្ឈិម។[63]

## សាលាឧទ្ធរណ៍ព្រះសីហនុ

ជាលើកទីមួយ ដែលសិទ្ធិមានមេធាវីត្រូវបានគោរពនៅចំពោះសាលាឧទ្ធរណ៍ព្រះសីហនុ។ ភាគរយនៃជនជាប់ចោទដែលត្រូវបានការពារដោយមេធាវីបានកើនឡើងដល់ ៨៣,៦% ក្នុងឆ្នាំ២០២៣ (១១២ ក្នុងចំណោម ១៣៤ នាក់) ក្នុងនោះ ១០០% នៃជនជាប់ចោទពីបទឧក្រិដ្ឋ (៦៥ ក្នុងចំណោម ៦៥ នាក់) មានមេធាវីការពារសិទ្ធិដែលនេះបង្ហាញថាតុលាការបានអនុវត្តពេញលេញតាមច្បាប់ជាតិដែលតម្រូវមានមេធាវីសម្រាប់បទឧក្រិដ្ឋ ប៉ុន្តែ ៦៨,៦% នៃជនជាប់ចោទពីបទមជ្ឈិម(៤៨ ក្នុងចំណោម ៧០ នាក់) និង១០០% នៃជនជាប់ចោទពីបទលហុ(១ ក្នុងចំណោម ១ នាក់)មានមេធាវីការពារសិទ្ធិមានន័យថា ៣១,៤% នៃជនជាប់ចោទបទមជ្ឈិម(២២ ក្នុងចំណោម ៧០ នាក់) មិនមានមេធាវីការពារសិទ្ធិ ហើយបើតាមចំនួបជាមួយតុលាការបានបញ្ជាក់ថាជនជាប់ចោទយល់ព្រមឱ្យតុលាការដំណើរការសវនាការរបស់គេមិនចាំបាច់មានមេធាវីការពារសិទ្ធិគឺគេអាចការពារខ្លួនដោយខ្លួនឯងបាន។ នេះមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានត្រឹម ៦៤,៤% ដែលនេះជាតួលេខខ្ពស់បំផុតក្នុងចំណោមតុលាការទាំងបួនក្នុងអំឡុងពេលធ្វើរបាយការណ៍។ ទោះបីជាមេធាវីការពារជនជាប់ចោទមាន ៥១,៨% (៥៨ ក្នុងចំណោម ១១២ នាក់) ការពារឱ្យជនជាប់ចោទលើសពីម្នាក់ក៏ដោយ ក៏ទំនាស់ផលប្រយោជន៍កើតមានតែពីរនាក់ប៉ុណ្ណោះ ដែលស្មើនឹង ៣,៤% នៃចំនួនសរុប។ ទោះបីជាតួលេខនេះមានកម្រិតទាបក៏ដោយ ក៏ជារឿងសំខាន់ដែលចៅក្រមត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការកំណត់ករណីដែលមេធាវីការពារឱ្យជនជាប់ចោទជាច្រើននាក់ អាចជះឥទ្ធិពលអវិជ្ជមានដល់ផលប្រយោជន៍ជនជាប់ចោទទាំងនោះ។ ក្នុងករណីបែបនេះ សវនាការគួរត្រូវពន្យារពេល ហើយត្រូវមានវិធានការណ៍ដើម្បីសម្រួលដល់លទ្ធភាពឱ្យជនជាប់ចោទនេះអាចទទួលបានការការពារពីមេធាវីផ្សេងជំនួសវិញ។

---

[62] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[63] នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតការណ៍សវនាការរបស់ខ្លួន។

នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមប្រធានតុលាការបានយល់ស្របថាមានកង្វះខាតខ្លះក្នុងការពន្យល់អំពីសិទ្ធិដល់ជនជាប់ចោទ និងតុលាការនឹងរៀបចំកិច្ចប្រជុំបច្ចេកទេសដើម្បីដោះស្រាយបញ្ហានេះ។[64] ទោះបីជាមានការសន្យា និងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងលើក៏ដោយ ក៏ ម.ស.ម.ក កត់សម្គាល់ថា តុលាការគ្រាន់តែអានប្រាប់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារអំពីសិទ្ធិមានមេធាវីក្នុងការការពារខ្លួនដោយផ្ទាល់ ឬតាមរយៈមេធាវីមានចំនួន ១៧,៤% នៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៣ (៤ ក្នុងចំណោម ២៣ នាក់)។ ទោះបីជានេះបានបង្ហាញពីការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្នុងចំនួន ១១,៨ % ក៏ដោយ ជាក់ស្តែងគឺថាមានជនជាប់ចោទតិចជាងម្នាក់ ក្នុងចំណោម ៥ នាក់ដែលមិនមានមេធាវីការពារមិនបានទទួលការអានប្រាប់អំពីសិទ្ធិនេះ។ លើសពីនេះ តុលាការបានអនុវត្តនូវការប្រតិបត្តិល្អដោយពន្យល់អំពីសិទ្ធិនេះមានមួយសំណុំរឿង ដែលបង្ហាញពីកង្វះខាតនៃដំណើរការប្រកបដោយអត្ថន័យចាប់តាំងពីឆ្នាំ ២០២២ នៅពេលដែលតុលាការមិនបានធ្វើដូច្នេះ។

នៅខែមីនា ឆ្នាំ២០២៣ តំណាងតុលាការបានលើកឡើងថា ចៅក្រមបានអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌយ៉ាងពេញលេញ ដែលចែងថាការមានមេធាវីមិនមែនជាកាតព្វកិច្ចទេ សម្រាប់បទមជ្ឈិម។ ទោះជាយ៉ាងណា តុលាការនៅតែសួរជនជាប់ចោទពាក់ព័ន្ធនឹងបទមជ្ឈិមថា តើពួកគេចង់មានមេធាវីតំណាងឬទេ។ ប្រសិនបើពួកគេចង់បានមេធាវីការពារ សវនាការត្រូវលើកពេលរហូតទាល់តែរកបានមេធាវី។ បន្ទាប់មក ជនជាប់ចោទនឹងត្រូវចំណាយលើថ្លៃសេវាមេធាវីដោយខ្លួនឯង។[65] នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងតុលាការ និងមហាអយ្យការអមតុលាការ បាននិយាយថា ជនជាប់ចោទដែលមិនមានមេធាវីការពារមួយចំនួន ដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿងដែលត្រូវបានសង្កេត បានទទួលការជូនដំណឹងរួចហើយអំពីសិទ្ធិមានមេធាវីក្នុងអំឡុងពេលសវនាការនៃបណ្តឹងឧទ្ធរណ៍លើកដំបូង។ ដូច្នេះ ចៅក្រមមិនបានប្រាប់ពួកគេអំពីសិទ្ធិនេះម្តងទៀតក្នុងការជំនុំជម្រះបន្ទាប់នោះទេ។ តំណាងតុលាការក៏បានលើកឡើងថា ក្រមនីតិវិធីព្រហ្មទណ្ឌមិនមានចែងពីកាតព្វកិច្ចក្នុងការជូនដំណឹងដល់ជនជាប់ចោទអំពីសិទ្ធិនេះទេ លើកលែងតែសំណុំរឿងជំនុំជម្រះភ្លាមៗ។ តំណាងតុលាការបានបន្ថែមថា ជាទូទៅជនជាប់ចោទទទួលបានព័ត៌មាននេះ។[66]

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

សម្រាប់រយៈពេលពីរឆ្នាំជាប់គ្នា សិទ្ធិមានមេធាវីមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ មានជនជាប់ចោទតែ ៤៤,៩% ប៉ុណ្ណោះដែលមានមេធាវីការពារនៅក្នុងសវនាការដែលត្រូវបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ (៧៩ ក្នុងចំណោម ១៧៦ នាក់) ក្នុងនោះ ១០០% នៃជនជាប់ចោទពីបទឧក្រិដ្ឋ

---

[64] នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតការណ៍សវនាការរបស់ខ្លួន។

[65] នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតការណ៍សវនាការរបស់ខ្លួន។

[66] នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។

(៤៨ ក្នុងចំណោម ៤៨ នាក់) មានមេធាវីការពារសិទ្ធិដែលនេះបង្ហាញថាតុលាការបានអនុវត្តពេញលេញតាមច្បាប់ជាតិដែលតម្រូវមានមេធាវីសម្រាប់បទឧក្រិដ្ឋ ប៉ុន្តែ ២៤,២% នៃជនជាប់ចោទពីបទមជ្ឈិម( ៣០ ក្នុងចំណោម ១២៤ នាក់) និង២៥% នៃជនជាប់ចោទពីបទលហុ(១ ក្នុងចំណោម ៤ នាក់) ប៉ុណ្ណោះមានមេធាវីការពារសិទ្ធិមានន័យថា ៧៥,៨% នៃជនជាប់ចោទបទមជ្ឈិម (៩៤ ក្នុងចំណោម ១២៤ នាក់) និង៧៥% នៃជនជាប់ចោទពីបទលហុ(៣ ក្នុងចំណោម ៤ នាក់)មិនមានមេធាវីការពារសិទ្ធិ ហើយតាមចំនួបជាមួយតុលាការបានបង្ហាញថាជនជាប់ចោទយល់ព្រមឱ្យតុលាការដំណើរការសវនាការរបស់គេមិនចាំបាច់មានមេធាវីការពារសិទ្ធិ គឺគេអាចការពារខ្លួនដោយខ្លួនឯងបាន។ នេះបង្ហាញថាមិនទាន់មានប្រសើរឡើងគួរឱ្យកត់សម្គាល់នោះទេ បើធៀបនឹងឆ្នាំ២០២២ ដែលតួលេខនេះមានចំនួន ៤៤,២%។ នេះគឺជា តួលេខទាបក្នុងចំណោមតុលាការទាំងបួន និងវាធ្វើឱ្យមានភាពមិនច្បាស់លាស់ថាតើជនជាប់ចោទដែលបានចូលសវនាការនៅតុលាការ បានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីសិទ្ធិនេះដោយអាជ្ញាធរទទួលខុសត្រូវដែរឬទេ (ភាគច្រើនជាមន្ត្រីនគរបាលយុត្តិធម៌ ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា) នៅដំណាក់កាលដំបូងក្នុងដំណើរការនីតិវិធី។ វាក៏អាចបង្ហាញពីការលំបាកក្នុងការទទួលបានសេវាជំនួយផ្នែកច្បាប់នៅក្នុងខេត្តដាច់ស្រយាលមួយចំនួន ដែលស្ថិតនៅក្រោមដែនយុត្តាធិការរបស់តុលាការ។ ទោះបីជាជនជាប់ចោទ ៤៩,៤% ដែលទទួលបានការការពារដោយមេធាវីក្នុងឆ្នាំ២០២៣ មានមេធាវីការពាររួមគ្នាជាមួយជនជាប់ចោទផ្សេងទៀត (៣៩ ក្នុងចំណោម ៧៩ នាក់) ក៏ដោយ ក៏ ម.ស.ម.ក មិនបានរកឃើញថាមានទំនាស់ផលប្រយោជន៍ណាមួយនោះទេ។

គួរឱ្យសាទរចំពោះភាគរយនៃសំណុំរឿង ដែលចៅក្រមបានអានប្រាប់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារអំពីសិទ្ធិរបស់ពួកគេក្នុងការការពារខ្លួនដោយផ្ទាល់ ឬតាមរយៈមេធាវី គឺបានកើនឡើងពី ៧៤,១% ក្នុងឆ្នាំ ២០២២ ដល់ ៩៤,២% ក្នុងឆ្នាំ២០២៣ (៤៩ ក្នុងចំណោម ៥២ នាក់)។ បន្ថែមពីលើដំណើរការវិវត្តដ៏ប្រសើរនេះ ចៅក្រមបានអនុវត្តនូវការប្រតិបត្តិល្អក្នុងការពន្យល់អំពីសិទ្ធិនេះក្នុងសំណុំរឿងចំនួន ៥៣,៨% (២៨ ក្នុងចំណោម ៥២ នាក់) គឺកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានចំនួនតែ ២៥,៩%។ ទោះបីជា ម.ស.ម.ក មិនបានចាត់ថ្នាក់សិទ្ធិមានមេធាវីថាត្រូវបានគោរពពេញលេញដោយសាលាឧទ្ធរណ៍ត្បូងឃ្មុំក៏ដោយ ក៏ម.ស.ម.ក ស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីធានាថា ជនជាប់ចោទដែលមិនមានមេធាវីការពារទទួលបានការអានប្រាប់អំពីសិទ្ធិនេះ។ វិធានការបន្ថែមទៀតគួរតែត្រូវអនុវត្ត ដើម្បីធានាថា កិច្ចការនេះត្រូវបានធ្វើនៅជាប្រចាំ និងដើម្បីលើកកម្ពស់របស់ជនជាប់ចោទក្នុងការទទួលបានមេធាវីការពារ។ នៅខែកញ្ញា ឆ្នាំ២០២៣ តំណាងតុលាការបានលើកឡើងថា តុលាការបានអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌពេញលេញពាក់ព័ន្ធនឹងសិទ្ធិមានមេធាវីរបស់ជនជាប់ចោទ។ តំណាងតុលាការបានបន្ថែមថា តុលាការអាចដំណើរការសវនាការនៃបណ្ដឹងឧទ្ធរណ៍បាន ចំពោះបទមជ្ឈិមដែលជាជាប់ចោទមិនមានមេធាវីការពារ តែមានការយល់ព្រមពីជនជាប់ចោទឱ្យតុលាការធ្វើដូច្នោះ ដែលស្របតាមបទប្បញ្ញត្តិច្បាប់ដែលមានស្រាប់។[67] នៅខែសីហា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអះអាងថាចៅក្រមបានប្រាប់សិទ្ធិមានមេធាវីដល់ជនជាប់ចោទ ហើយ តែជនជាប់ចោទមិនស្វែងរកមេធាវីដើម្បីការពារសិទ្ធិរបស់គាត់ ព្រមឱ្យតុលាការជំនុំជម្រះរឿងក្ដីរបស់គាត់ដោយ

[67] នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាអំពីលទ្ធផលនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

មិនមានមេធាវី ម្យ៉ាងទៀតតុលាការមិនជាប់កាតព្វកិច្ចស្វែងរកមេធាវីឱ្យជនជាប់ចោទទេ មិនតែប៉ុណ្ណោះតាមច្បាប់បទមជ្ឈិមអាចធ្វើការជំនុំជម្រះដោយគ្មានមេធាវីបាន។[68]

## ៤.២. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ |
| មាត្រា ១៤(១) | មាត្រា ៣៩២ | មាត្រា ៧ |

ជនគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ថាមានពិរុទ្ធភាព ឬគ្មានទោសនៅក្នុងការជំនុំជម្រះជាសាធារណៈ[69] លើកលែងតែដំណើរការសវនាការ *ជាអសាធារណៈ* ទាំងស្រុង ឬដោយផ្នែក គឺហានិភ័យដែលថាសវនាការសាធារណៈ អាចបណ្តាលឱ្យមាន "ការប៉ះពាល់យ៉ាងខ្លាំង" ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬសីលធម៌ ផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី (ជាពិសេស ក្នុងសំណុំរឿងរំលោភផ្លូវភេទមួយចំនួន) ឬវត្តមានកុមារដែលទំនាស់នឹងច្បាប់។[70]

*ការធានានៅក្នុងករណីសវនាការជាអសាធារណៈ*

ទោះបីជាសាធារណជនទាំងអស់ ឬផ្នែកខ្លះនៃសាធារណៈជនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសវនាការដោយសារកាលៈទេសៈពិសេសក៏ដោយ ក៏នៅតែមានការធានានូវសាធារណភាពផងដែរ។ ក្នុងស្ថានភាពបែបនេះ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុច្បាប់ ត្រូវតែធ្វើជាសាធារណៈ។[71] មានតែនៅក្នុងករណីមួយចំនួនតូចប៉ុណ្ណោះ (ឧទាហរណ៍៖ ប្រសិនបើមានភាពចាំបាច់ដើម្បីជាប្រយោជន៍របស់កុមារ) ទើបអាចមានការលើកលែងចំពោះការធានានូវសាធារណភាពនេះ។

---

[68] នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[69] សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនេះសូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ"(ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-a-public-hearing

[70] គណៈកម្មាធិការសិទ្ធិកុមារអង្គការសហប្រជាជាតិ (“គណៈកម្មាធិការសិទ្ធិកុមារ”) សេចក្តីពន្យល់ទូទៅ លេខ ២៤ ស្តីពីសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌កុមារ (ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩) CRC/C/GC/២៤ វាក្យខណ្ឌ ៦៧ https://tinyurl.com/2s4kka6

[71] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

មានតែនៅក្នុងកាលៈទេសៈពិសេសដែលច្បាប់កំណត់ប៉ុណ្ណោះ ទើបសាធារណៈជនទាំងអស់ ឬមួយផ្នែក មិនអាចត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការបាន។[72] នៅក្នុងកាលៈទេសៈផ្សេងទៀត សវនាការត្រូវតែធ្វើឡើងជាសាធារណៈ ដោយរាប់បញ្ចូលទាំងសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយផងដែរ ហើយមិនគួរមានក្រុមមនុស្សជាក់លាក់ណាមួយត្រូវបានផាត់ចេញឡើយ។[73] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈក៏ពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងពេលវេលា និងទីកន្លែងសម្រាប់សវនាការផ្ទាល់មាត់ទៅដល់សាធារណជន និងផ្តល់មធ្យោបាយគ្រប់គ្រាន់សម្រាប់ការចូលរួមជាសាធារណៈនៅក្នុងកម្រិតសមរម្យ។[74]

### *តួលេខទី៨៖ ភាគរយនៃសំណុំរឿងដែលមានការបិទផ្សាយកាលវិភាគសវនាការជាសរុប*[75]




ការបិទផ្សាយកាលវិភាគសវនាការដែលបង្ហាញអំពីកាលបរិច្ឆេទ ទីតាំង និងពេលវេលា ចាប់ផ្តើមសវនាការនៅខាងក្រៅបន្ទប់សវនាការ ឬផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត គឺជាមធ្យោបាយមួយក្នុងការផ្សព្វផ្សាយ អំពីសវនាការជាសាធារណៈ តាមរយៈការជូនដំណឹងដល់សាធារណជនអាចចូលទៅកាន់បន្ទប់សវនាការដែលការជំនុំជម្រះកំពុងប្រព្រឹត្តទៅនោះបាន។

គួរឱ្យកត់សម្គាល់ផងដែរថា ដូចទៅនឹងឆ្នាំ២០២២ ដែរ តាមសំណុំរឿងដែលត្រូវបានសង្កេតនៅទូទាំងតុលាការទាំងអស់នៅឆ្នាំ២០២៣ នេះ គឺមិនមានការបង្ហាញថា សាធារណជន ឬប្រព័ន្ធផ្សព្វផ្សាយត្រូវបានរារាំង ឬ បណ្តេញចេញពីបន្ទប់សវនាការនោះទេ។ លើសពីនេះទៀត កាលវិភាគសវនាការត្រូវបានបិទផ្សាយនៅលើក្តារព័ត៌មានសាធារណៈនៅខាងក្រៅបន្ទប់សវនាការ និង/ឬតាមប្រព័ន្ធអ៊ីនធឺណិតក្នុងចំនួន ៨៤,១% ក្នុងចំណោមសវនាការដែលបានសង្កេតសរុប (៦៤៩ ក្នុងចំណោម ៧៧២ សំណុំរឿង) គឺមានកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានត្រឹម ៧៣,១%។ ទោះបីជាមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ក៏ដោយ ក៏ ម.ស.ម.ក មិនអាចចាត់ទុកថាសិទ្ធិនេះត្រូវបានគោរពយ៉ាងពេញលេញនោះទេ ដោយសារតែមានភាពខុសគ្នារវាងតុលាការនីមួយៗ។

## សាលាឧទ្ធរណ៍ភ្នំពេញ

---

[72] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

[73] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

[74] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៨; គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ២១៥/១៩៨៦, *Van Meurs ទល់នឹង ប្រទេសហូឡង់* (ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០) CCPR/C/៣៩/D/២១៥/១៩៨៦, វាក្យខណ្ឌ ៦.២ https://tinyurl.com/2nc55r5f

[75] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៧៧២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

នៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ សាលាឧទ្ធរណ៍ភ្នំពេញ[76] បានទទួលស្គាល់ថាមានចំណុចខ្វះខាតមួយចំនួនពាក់ព័ន្ធនឹងការជូនដំណឹងជាសាធារណៈ អំពីកាលវិភាគសវនាការរបស់តុលាការ ព្រមទាំងបានប្រាប់ដល់ ម.ស.ម.ក ថានឹងមានវិធានការដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីកាលវិភាគសវនាការ និងងាយស្រួលក្នុងការចូលរួមសវនាការ។ នៅឆ្នាំ២០១៩ តុលាការបានបញ្ជាក់ថា ការបិទកាលវិភាគវសវនាការជាសាធារណៈ គឺជាបញ្ហារដ្ឋបាល និងមិនត្រូវបានតម្រូវដោយច្បាប់ទេ។ ទោះបីជាយ៉ាងនេះក្តី តុលាការបានផ្តល់អាទិភាពលើបញ្ហានេះ និងបានបង្កើត គេហទំព័រ មួយដើម្បីបង្ហោះព័ត៌មានអំពីសំណុំរឿង ក៏ដូចជា កាលវិភាគសវនាការ ផងដែរ។ ព័ត៌មានដែលអាចស្វែងរកបានរួមមាន កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការ លេខសំណុំរឿង បទចោទប្រកាន់ និងឈ្មោះរបស់ចៅក្រម។

***តួលេខទី៩៖ ភាគរយនៃសំណុំរឿងដែលមានការបិទផ្សាយកាលវិភាគសវនាការ នៅសាលាឧទ្ធរណ៍ភ្នំពេញ[77]***




គួរឱ្យសាទរ សាលាឧទ្ធរណ៍ភ្នំពេញបានបិទផ្សាយកាលវិភាគសវនាការចំនួន ៩៥,២% (៣២០ ក្នុងចំណោម ៣៣៦ សំណុំរឿង) នៃសំណុំរឿងសរុបដែលបានសង្កេតក្នុងឆ្នាំ២០២៣ គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានចំនួន ៦៧,៧%។ អ្វីដែលគួរឱ្យកត់សម្គាល់ជាពិសេសគឺមានចំនួន ៩៦,៩% នៃកាលវិភាគសវនាការទាំងនេះត្រូវបានបង្ហោះតាមប្រព័ន្ធអនឡាញ ហើយបើធៀបនឹងឆ្នាំ២០២២ មាន ៩៩,៤%។ ទោះបីជាតុលាការនេះមិនទាន់បានអនុវត្តល្អជាប្រចាំ ចំពោះការបិទផ្សាយកាលវិភាគសវនាការទាំងតាមប្រព័ន្ធអនឡាញ និងនៅលើក្តារព័ត៌មានសាធារណៈរបស់តុលាការក៏ដោយ ក៏តុលាការនេះបានបានបិទផ្សាយកាលវិភាគសវនាការទាំងអនឡាញ និងលើក្តារខៀនព័ត៌មានចំនួន ៤៩% ក្នុងចំណោមសំណុំរឿងដែលបានសង្កេត គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានចំនួន ២០,៦%។ ការផ្លាស់ប្តូរទាំងនេះពិតជាគួរឱ្យកត់សម្គាល់ខ្លាំងណាស់ ព្រោះនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់តុលាការក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ដោយបង្ហាញនូវលទ្ធផលជាក់ស្តែង ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម។ ដូច្នេះហើយ គួរតែមានការយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថាវឌ្ឍនភាពនេះបន្តទៅមុខជានិច្ច។ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានអះអាងថា នឹងបន្តខិតខំអនុវត្តការបិទផ្សាយកាលវិភាគសវ

[76] នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ និងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីពិភាក្សាលើការរកឃើញដែលមាននៅក្នុងឆ្នាំ២០១៦/២០១៧ និងរបាយការណ៍ឆ្នាំ២០១៧/២០១៨។

[77] ទិន្នន័យនេះផ្អែកលើសំណុំរឿងសរុប ៣៣៦ ដែលបានសង្កេតនៅតុលាការនេះក្នុងឆ្នា២០២៣។

នាការនៅបញ្ជរព័ត៌មាន និងនៅតាមប្រព័ន្ធឌីជីថល (ទំព័រហ្វេសប៊ុក និងគេហទំព័ររបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ) ដើម្បីជានាវឌ្ឍនភាពឱ្យកាន់តែមានការរីកចម្រើន។[78]

*តួលេខទី១០៖ ការវិវត្តជាភាគរយនៃសំណុំរឿងដែលកាលវិភាគសវនាការត្រូវបានបិទផ្សាយនៅខាងក្រៅបន្ទប់សវនាការ (រហូតដល់ឆ្នាំ២០២២) និងនៅខាងក្រៅបន្ទប់សវនាការ ឬតាមប្រព័ន្ធអនឡាញ (ពីឆ្នាំ២០២២) នៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២៣)[79]*




## សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបងបានបិទផ្សាយកាលវិភាគសវនាការចំនួន ៧៥,១% នៃសំណុំរឿងដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣ (១៨១ ក្នុងចំណោម ២៤១ សំណុំរឿង) ដែលតួលេខនេះធ្លាក់ចុះ បើធៀបនឹងឆ្នាំ២០២២ ដែលមានចំនួនដល់ទៅ ៩៣,៧%។ ការថយចុះនេះ បង្ហាញថាសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈថាមិនត្រូវបានគោរពពេញលេញឡើយ។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមអនុប្រធាន តុលាការបានទទួលស្គាល់ថា កាលវិភាគសវនាការមិនបានបិទផ្សាយនៅលើក្ដារខៀនព័ត៌មានរបស់តុលាការជាទៀងទាត់ទេ តែយ៉ាងណា តុលាការនឹងពង្រឹងលើការងារនេះ។[80] ម.ស.ម.ក បានកត់ត្រា រាល់កាលវិភាគសវនាការដែលតុលាការបានបិទផ្សាយក្នុងឆ្នាំ២០២៣ មាននៅលើក្ដារខៀនព័ត៌មានទាំងអស់ គឺបានកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានតែ ៨៤,៣% ដែលនេះបង្ហាញពីការខិតខំប្រឹងប្រែង។ លើសពីនេះទៀត ៥៧,៥% នៃកាលវិភាគទាំងនេះ (១០៤ ក្នុងចំណោម ១៨១ សំណុំរឿង) ត្រូវបានបង្ហោះតាមប្រព័ន្ធអនឡាញផងដែរ គឺមានការកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានចំនួនតែ ២៩,៨%។

---

[78] លិខិតលេខ៧០៦ រប្ឌ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[79] ទិន្នន័យនេះផ្អែកលើសំណុំរឿងសរុបចំនួន ១២៨ ដែលបានសង្កេតក្នុងឆ្នាំ២០១៤/២០១៥, សំណុំរឿងសរុបចំនួន ៣៤០ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៦/២០១៧, សំណុំរឿងសរុបចំនួន ២១៣ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៧/២០១៨, សំណុំរឿងសរុបចំនួន ២៣៩ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៨/២០១៩, សំណុំរឿងសរុបចំនួន ២០៣ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៩/២០២០, សំណុំរឿងសរុបចំនួន ៨៥ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២១, សំណុំរឿងសរុបចំនួន ២៥៧ ដែលត្រូវបានសង្កេតនៅឆ្នាំ២០២២, និងសំណុំរឿងសរុបចំនួន ៣៣៦ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

[80] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

*តួលេខទី១១៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបង*[81]




ទោះបីជាមានភាពប្រសើរទាំងនេះក៏ដោយ តុលាការបានបង្ហោះកាលវិភាគសវនាការរបស់ខ្លួនតាមប្រព័ន្ធអនឡាញមានតែចំនួន ៤៣,២% ប៉ុណ្ណោះ ក្នុងចំណោមសំណុំរឿងសរុប ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣ ដែលមានការកើនតិចតួចគឺ ០,៥% បើធៀបនឹងរបាយការណ៍ឆ្នាំមុន។ គួរកត់សម្គាល់ថា ទិន្នន័យនេះមិនដូចនៅឆ្នាំ២០២២ ទេ ដែលតុលាការបានបង្ហោះកាលវិភាគសវនាការរបស់ខ្លួន ទាំងតាមប្រព័ន្ធអនឡាញ និងក្ដារខៀនព័ត៌មានជាប្រសើរជាង។ ដូចនេះ តុលាការគួរបន្ថែមការយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយកាលវិភាគសវនាការតាមប្រព័ន្ធអនឡាញផងដែរ ដើម្បីពង្រីកវិសាលភាពនៃព័ត៌មាននេះដល់សាធារណជនទូទៅអាចទទួលបានតាមប្រព័ន្ធអនឡាញ។

## សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុបានខកខានក្នុងការបិទផ្សាយកាលវិភាគសវនាការចំនួន ៧៨% ក្នុងចំណោមសំណុំរឿងសរុបដែលបានសង្កេតក្នុងឆ្នាំ២០២២។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមប្រធានតុលាការបានទទួលស្គាល់អំពីការអនុវត្តមិនទាន់ពេញលេញនេះ ហើយបានណែនាំសហការីរបស់គាត់ឱ្យចាប់ផ្ដើមបង្ហោះកាលវិភាគសវនាការនៅលើទំព័រហ្វេសបុករបស់តុលាការ។[82] ទោះបីជា មានការវិវត្តប្រសើរឡើងខ្លះនៅឆ្នាំ២០២៣ ក៏ដោយ ក៏ ម.ស.ម.ក កត់សម្គាល់ថា តុលាការនៅតែខកខានផ្សព្វផ្សាយកាលវិភាគសវនាការចំនួន ៦២,៧% ក្នុងចំណោមសំណុំរឿងសរុបដែលត្រូវបានសង្កេត (៤៧ ក្នុងចំណោម ៧៥ សំណុំរឿង)។ ខុសពីតុលាការគោលដៅដទៃទៀត តុលាការនេះមិនបានបង្ហោះកាលវិភាគសវនាការតាមប្រព័ន្ធអនឡាញទេ គឺមានតែបិទបង្ហាញព័ត៌មានទាំងនោះនៅលើក្ដារខៀនព័ត៌មានតែប៉ុណ្ណោះ។ ឆ្លើយតបនឹងការរកឃើញនេះ តុលាការគួរបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាថា កាលវិភាគសវនាការត្រូវបានផ្សព្វផ្សាយជាសាធារណៈ រួមទាំងប្រព័ន្ធអនឡាញអនឡាញផងដែរ។ នៅខែសីហា ឆ្នាំ២០២៤ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានឆ្លើយតបថា តុលាការមិនដែលហាមឃាត់សាធារណជនចូលមើលសវនាការនោះទេ។ ម្យ៉ាងទៀត គួរពិចារណាលើចំនួនសាធារណជនដែលបានចូលមើលសវនាការនៅសាលា

[81] ទិន្នន័យនេះផ្អែកលើសំណុំរឿងសរុប ២៤១ ដែលបានសង្កេតនៅតុលាការនេះក្នុងឆ្នាំ២០២៣។

[82] នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

ឧទ្ធរណ៍ព្រះសីហនុ តើមានសាធារណជនចូលមើលសវនាការញឹកញាប់ប៉ុណ្ណា បើមិនមានសាធារណជនចូលមើលសវនាការច្រើនផង តើការសរសេរក្នុងរបាយការណ៍លើចំណុចនេះមានសារៈសំខាន់ដែរឬទេ។[83]

*តួលេខទី១២៖ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយនូវកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ព្រះសីហនុ[84]*




នៅខែកញ្ញា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានកត់សម្គាល់ថា សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈគឺបើកបន្ទប់សវនាការសម្រាប់សាធារណជនអាចចូលរួមស្តាប់សវនាការបាន ហើយបន្ថែមថា តុលាការមិនមានកាតព្វកិច្ចក្នុងការប្រកាសកាលវិភាគសវនាការលើប្រព័ន្ធអនឡាញ ឬនៅលើក្តារខៀនព័ត៌មាននោះទេ។ តំណាងតុលាការ និងមហាអយ្យការបានរំឭកឡើងវិញនូវទស្សនៈនេះ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ ថាការបិទផ្សាយកាលវិភាគសវនាការគឺជាបញ្ហារដ្ឋបាលដាច់ដោយឡែកពីតួនាទីរបស់តុលាការ។[85]

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

*តួលេខទី១៣៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយនូវកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ[86]*




គួរឱ្យសាទរ សាលាឧទ្ធរណ៍ត្បូងឃ្មុំបានផ្សព្វផ្សាយកាលវិភាគសវនាការជាសាធារណៈ ចំនួន ១០០% នៃសំណុំរឿងចំនួន ១២០ ដែលបានសង្កេតក្នុងឆ្នាំ២០២៣ គឺមានការកើនឡើង បើធៀបនឹងឆ្នាំ ២០២២ មានចំនួន ៩៦,៨%។ ការសង្កេតសវនាការរបស់ ម.ស.ម.ក បង្ហាញថា កាលវិភាគសវនាការទាំងនេះ ភាគច្រើនលើសលប់នៃ (៩៩,២%) គឺត្រូវបានបង្ហោះតាមប្រព័ន្ធអនឡាញ។ ទោះជាយ៉ាងនេះក៏ដោយ តុលាការនេះបានបង្ហោះព័ត៌មានអំពីកាលវិភាគសវនាការទាំងនោះនៅលើប្រព័ន្ធអនឡាញនិងនៅលើក្តារខៀនព័ត៌មានជាសាធារណៈ មានចំនួនត្រឹម ៦២,៥% ក្នុងចំណោមសវនាការសរុបដែលបានសង្កេត គឺមានចំនួនភាគរយតិចជាងឆ្នាំ២០២២ ដែលមានចំនួនដល់ទៅ ៨២,៣%។ យ៉ាងណាក៏

[83] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[84] ទិន្នន័យនេះគឺផ្អែកលើសំណុំរឿងសរុបចំនួន ៧៥ ដែលបានសង្កេតនៅតុលាការនេះក្នុងឆ្នាំ២០២៣។

[85] លិខិតលេខ ១៩១៩/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[86] ទិន្នន័យនេះគឺផ្អែកលើសំណុំរឿងសរុបចំនួន ១២០ ដែលបានសង្កេតនៅតុលាការនេះក្នុងឆ្នាំ២០២៣។

ដោយ សាលាឧទ្ធរណ៍ត្បូងឃ្មុំឈរឈ្មោះជាតុលាការគោលដៅតែមួយគត់ ដែលគោរពនូវសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈទាំងឆ្នាំ២០២២ និងឆ្នាំ២០២៣។

## ៤.៣.សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃចោទប្រកាន់

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣) (ក) & (ច) | មាត្រា ៣២២, ៣២៥, ៣៣០, ៣៣១ & ៣៩៦ | មាត្រា ៦ និង ៥១ |

ជនជាប់ចោទបទព្រហ្មទណ្ឌ ត្រូវទទួលបានការជូនដំណឹង "ភ្លាមៗ" អំពីប្រភេទនៃបទល្មើសដែលបានចោទប្រកាន់មកលើពួកគេ។ ចៅក្រមមានកាតព្វកិច្ចផ្តល់ការពន្យល់ឱ្យបានគ្រប់គ្រាន់ និងធានាថាជនជាប់ចោទយល់អំពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់មកលើពួកគេ ធ្វើដូច្នេះពួកគេអាចរៀបចំមេធាវីការពារបានត្រឹមត្រូវ។ [87] ព័ត៌មានទាក់ទងនឹងការចោទប្រកាន់ត្រូវតែផ្តល់ជូនភ្លាមៗនៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ជាផ្លូវការពីបទព្រហ្មទណ្ឌតាមច្បាប់ជាតិ ឬភ្លាមៗនៅពេលដែលជននោះត្រូវបានកំណត់ជាសាធារណៈថាជាជនជាប់ចោទ។ ការជូនដំណឹងនេះអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ (លុះត្រាតែមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរនៅពេលក្រោយ) ឬជាលាយលក្ខណ៍អក្សរ ដែលព័ត៌មានបង្ហាញទាំងអង្គច្បាប់ និងអង្គហេតុសម្រាប់ជាមូលដ្ឋាននៃការចោទប្រកាន់។[88]

គួរកត់សម្គាល់ថា អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យនៅពេលចាប់ផ្តើមសវនាការរបស់សាលាឧទ្ធរណ៍ ខណៈពេលដែលជនជាប់ចោទបានដឹងច្បាស់រួចហើយអំពីបទចោទប្រកាន់មកលើពួកគេ។ ទោះបីជាយ៉ាងនេះក្តី ប្រការនេះមានសារៈសំខាន់សម្រាប់ចៅក្រមដើម្បីរំឭកជនជាប់ចោទអំពីព័ត៌មាននេះ និងដើម្បីធានាថា ជនជាប់ចោទយល់ដឹងអំពីព័ត៌មាននេះ ជាពិសេសនៅក្នុងករណីដែលការចោទប្រកាន់អាចមានការប្តូរ ឬកែប្រែនៅចន្លោះពេលឃាត់ខ្លួន/ការចោទប្រកាន់ដំបូង និងការជំនុំជម្រះជាក់ស្តែង។ បន្ថែមពីនេះ មាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា វិធានដែលអនុវត្តចំពោះមុខតុលាការជាន់ដំបូងក៏ត្រូវយកមកអនុវត្តចំពោះមុខសាលាឧទ្ធរណ៍ដែរ។

---

[87] សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់" (ខែកញ្ញា ឆ្នាំ២០២២)https://sithi.org/km/fair-trial-rights/the-right-to-be-informed-of-the-nature-and-causes-of-the-charges

[88]គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ *សូមមើលផងដែរ*គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៦០៩/១៩៩៥, *Nathaniel Williams និងចាម៉ៃកា* (ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧) CCPR/C/៦១/D/៦០៩/១៩៩៥ ដែលក្នុងនោះគណៈកម្មាធិការបានបញ្ជាក់បន្ថែមថា ព័ត៌មានលម្អិតអំពីការចោទប្រកាន់ត្រូវតែផ្តល់ជូននៅ "*ពេលចាប់ផ្តើមការស៊ើបអង្កេតបឋម ឬនៅពេលកំណត់សវនាការមួយចំនួនផ្សេងទៀត ដែលនាំទៅដល់ការសង្ស័យជាផ្លូវការយ៉ាងច្បាស់ចំពោះជនជាប់ចោទ*"។

*តួលេខទី១៤៖ ភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់ពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ នៅតាមតុលាការទាំង៤*[89]




គួរឱ្យសាទរ ចៅក្រមបានអានប្រាប់ពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទចំនួន ៨៨,៦% (៦៤៩ ក្នុងចំណោម ៧៧២ សំណុំរឿង) នៃសវនាការដែលបានសង្កេតក្នុងឆ្នាំ២០២៣។ នេះគឺជាវឌ្ឍនភាពដ៏សំខាន់មួយបើប្រៀបធៀបទៅនឹងឆ្នាំ២០២២ ដែលតួលេខនេះមានចំនួនត្រឹមតែ ៥៩,៧% ប៉ុណ្ណោះ។ ភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់ដល់ជនជាប់ចោទខ្លះអំពីបទចោទប្រកាន់ពាក់ព័ន្ធមកលើពួកគេ បានថយចុះពី ៣០,៣% ក្នុងឆ្នាំ២០២២ មកត្រឹម ៩,៦% ក្នុងឆ្នាំ២០២៣ ខណៈដែលភាគរយនៃសំណុំរឿងដែលចៅក្រមមិនបានអានប្រាប់ដល់ជនជាប់ចោទអំពីបទចោទប្រកាន់នឹងពួកគេទាំងអស់ មានចំនួន ១,៨% គឺមានការធ្លាក់ចុះ បើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ ១០%។ តុលាការទាំងអស់បានផ្តល់អ្នកបកប្រែដល់ជនជាប់ចោទទាំងអស់ដែលត្រូវការ (សរុបចំនួន ៣៩ សំណុំរឿង) នេះក៏បង្ហាញពីភាពវិជ្ជមានផងដែរ។

សរុបមក ទោះបីជា មានភាពខុសគ្នាខ្លះរវាងតុលាការមួយទៅតុលាការទៀតក៏ដោយ ក៏ចៅក្រមបានបង្ហាញយ៉ាងខ្ជាប់ខ្ជួននូវកាលបរិច្ឆេទនៃបទល្មើស(៩១,៨% នៃសវនាការដែលបានសង្កេតក្នុងឆ្នាំ២០២៣ គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានត្រឹ ៨៤,៣% ប៉ុណ្ណោះ), កន្លែងប្រព្រឹត្តបទល្មើស (៩១,២% គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានតែ៨២,១%) និងភាគីពាក់ព័ន្ធ (៩៧,៣% មានការកើនឡើងដែរ បើធៀបនឹងឆ្នាំ២០២២ មានតែ ៨៩,១%)។ ទោះបីជាមានការវិវត្តដ៏ប្រសើរចំពោះការគោរពសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់យ៉ាងខ្ជាប់ខ្ជួនក៏ដោយ ក៏ ម.ស.ម.ក កត់សម្គាល់ថាចៅក្រមបានអានប្រាប់ច្បាប់ដែលពាក់ព័ន្ធចំនួន ៦៩,៨% ក្នុងចំណោមចំនួនសវនាការដែលបានសង្កេតក្នុងឆ្នាំ២០២៣ ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តីនេះបង្ហាញពីការវិវឌ្ឍដ៏សំខាន់មួយ បើធៀបទៅនឹងឆ្នាំ២០២២ ដែលតួលេខនេះមានចំនួនត្រឹមតែ ៤៨% ប៉ុណ្ណោះ។ ក្នុងចំណោមតុលាការគោលដៅទាំងអស់ មានតែផ្នែកមួយពាក់ព័ន្ធនឹងអានប្រាប់អំពីច្បាប់នៅមិនទាន់សម្រេចបានចំនួន ៨០% ដែលបានកំណត់របស់ ម.ស.ម.ក ដែលថាបានគោរពយ៉ាងពេញលេញ ចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[89] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៧៧២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

**សាលាឧទ្ធរណ៍ភ្នំពេញ**

សាលាឧទ្ធរណ៍ភ្នំពេញបានអានប្រាប់ដល់ជនជាប់ចោទអំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ចំពោះពួកគេក្នុងសំណុំរឿង ៨២,១% នៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៣ (២៧៦ ក្នុងចំណោម ៣៣៦ សំណុំរឿង) ដែលនេះជាការប្រសើរឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២២ ដែលតួលេខនេះមានតែ ៤៧,៩%។ បន្ថែមពីលើការកើនឡើងគួរឱ្យសាទរនេះ ម.ស.ម.ក កត់សម្គាល់ថា ភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់អំពីការចោទប្រកាន់មួយចំនួនដល់ជនជាប់ចោទក៏មានភាពប្រសើរដែរដែលមានចំនួនពី ៥០,១% ក្នុងឆ្នាំ២០២២ ចុះមកត្រឹម ១៧,៩% ក្នុងឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមនៅតែខកខាននូវការអានប្រាប់ពីច្បាប់ពាក់ព័ន្ធក្នុងសំណុំរឿងដែលបានសង្កេតចំនួន ៣៨,៧% ក្នុងឆ្នាំ២០២៣ (១៣០ ក្នុងចំណោម ៣៣៦ សំណុំរឿង) ដោយធ្លាក់ចុះបន្តិច បើធៀបនឹងឆ្នាំ២០២២ មានចំនួន ៣៨,៩%។ ការខកខាននេះបានបង្ហាញថា សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មិនទាន់ត្រូវបានគោរពយ៉ាងពេញលេញនៅឡើយទេ។ សាលាឧទ្ធរណ៍ និងមហាអយ្យអមសាលាឧទ្ធរណ៍ភ្នំពេញ បានឆ្លើយតបថា តុលាការនឹងបន្តអនុវត្តនីតិវិធីប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់ អង្គហេតុ និងការសម្រេចសេចក្តីឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។[90]

សាលាឧទ្ធរណ៍ភ្នំពេញបានគោរពសិទ្ធិនេះកាលពីអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៤/២០១៥ និងឆ្នាំ ២០១៦/២០១៧។ បន្ទាប់មកសិទ្ធិនេះត្រូវបានចាត់ទុកថាមិនត្រូវបានគោរពទាំងស្រុងនោះទេ នេះដោយសារតែទិន្នន័យមិនបានឈានដល់កម្រិតចំនួន ៨០% នៅផ្នែកខ្លះដែលបានកំណត់ ដូចដែលបានបង្ហាញក្នុងតារាងខាងក្រោម។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ២០២៣នេះ ម.ស.ម.ក សាទរចំពោះតុលាការនេះដែលបានគោរពសិទ្ធិនេះក្នុងកម្រិតមួយល្អដូចក្នុងឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ សម្រាប់គ្រប់ផ្នែកទាំងអស់ លើកលែងតែផ្នែកមួយដែលបានរៀបរាប់ខាងលើ។ ដោយសារមានការរកឃើញនូវចំណុចត្រូវកែលម្អនេះ គួរតែមានវិធានការ ដើម្បីដោះស្រាយឱ្យបានត្រឹមត្រូវ និងរក្សាវឌ្ឍនភាពដែលសម្រេចបានក្នុងឆ្នាំ២០២៣ ក្នុងគោលបំណងលើកកម្ពស់សិទ្ធិនេះឱ្យបានពេញលេញ។

[90] លិខិតលេខ៧០៦ របឧ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

*តួលេខទី១៥៖ ការវិវត្តនៃសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២៣)*[91]




## សាលាឧទ្ធរណ៍បាត់ដំបង

មានការប្រសើរឡើងដែលសាលាឧទ្ធរណ៍បាត់ដំបងបានពង្រឹងដល់ការគោរពសិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់អំឡុងពេលធ្វើរបាយការណ៍នេះ បើធៀបនឹងឆ្នាំមុន។ ចៅក្រមបានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទក្នុងសំណុំរឿងចំនួន ៨៩,២% នៃសំណុំរឿងដែលត្រូវបានសង្កេតក្នុងឆ្នាំ ២០២៣ (២១៥ ក្នុងចំណោម ២៤១ សំណុំរឿង) គឺមានការកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានចំនួនតែ ៥១,៧% ប៉ុណ្ណោះ។ គួរឱ្យសាទរផងដែរដែលភាគរយនៃសំណុំរឿងដែលចៅក្រមមិនបានអានប្រាប់អំពីបទចោទប្រកាន់ទាំងអស់ដល់ជនជាប់ចោទ បានធ្លាក់ចុះពី ៣២,២% ក្នុងឆ្នាំ២០២២ មកត្រឹម ៥,៤% ក្នុងឆ្នាំ២០២៣។ ដូចគ្នានេះ ចៅក្រមបានអានប្រាប់អំពីបទចោទប្រកាន់មួយចំនួនដល់ជនជាប់ចោទត្រឹមចំនួន ៥,៤% នៃសំណុំរឿងដែលត្រូវបានសង្កេតក្នុងឆ្នាំ ២០២៣ គឺមានការធ្លាក់ចុះបើធៀបនឹងឆ្នាំ២០២២ មានចំនួន ១៦,១%។ ទោះបីជាតុលាការអនុវត្តបានល្អប្រសើរជាងមុនក្នុងការអានប្រាប់អំពីច្បាប់ដែលពាក់ព័ន្ធក្នុងឆ្នាំ២០២៣ (៦៤,៧% នៃសវនាការដែលបានសង្កេតដោយកើនឡើង

---

[91] ទិន្នន័យនេះផ្អែកលើសំណុំរឿងសរុបចំនួន ១២៨ ដែលបានសង្កេតក្នុងឆ្នាំ២០១៤/២០១៥, សំណុំរឿងសរុបចំនួន ៣៤០ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៦/២០១៧, សំណុំរឿងសរុបចំនួន ២១៣ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៧/២០១៨, សំណុំរឿងសរុបចំនួន ២៣៩ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៨/២០១៩, សំណុំរឿងសរុបចំនួន ២០៣ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០១៩/២០២០ សំណុំរឿងសរុបចំនួន ៨៥ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២១, សំណុំរឿងសរុបចំនួន ២៥៧ ដែលត្រូវបានសង្កេតនៅឆ្នាំ២០២២ និងសំណុំរឿងសរុបចំនួន ៣៣៦ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

បើធៀបនឹងឆ្នាំ២០២២ មានត្រឹមចំនួន ២៦,៦%) ប៉ុន្តែនៅតែត្រូវការឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីគោរពនូវសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ឱ្យកាន់តែប្រសើរឡើង។

## សាលាឧទ្ធរណ៍ព្រះសីហនុ

ជាថ្មីម្តងទៀត សាលាឧទ្ធរណ៍ព្រះសីហនុបានអនុវត្តយ៉ាងល្អប្រសើរក្នុងការគោរពសិទ្ធិជនជាប់ចោទពាក់ព័ន្ធនឹងការយល់ដឹងពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់។ ចៅក្រមបានអានប្រាប់ពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ ចំនួន ៩៧,៣% នៃសវនាការដែលបានសង្កេតក្នុងឆ្នាំ២០២៣ គឺកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានចំនួន ៩១,៥%។ ទោះជាយ៉ាងណាក៏ដោយ ការណ៍ដែលចៅក្រមបានអានប្រាប់តែច្បាប់ដែលពាក់ព័ន្ធមានចំនួនត្រឹម ៧៦% នៃសំណុំរឿងដែលបានសង្កេតមានការថយចុះ បើធៀបនឹង ឆ្នាំ២០២២ តួលេខនេះមានចំនួនដល់ទៅ ៨៩,៨%។ ការថយចុះនេះបង្ហាញថាសិទ្ធិនេះមិនត្រូវបានគោរពពេញលេញនោះទេ។ ដូចនេះ គួរតែមានការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីឱ្យនិន្នាការនេះមានភាពប្រសើរឡើងវិញ ហើយយ៉ាងហោចណាស់ទទួលបានដូចនិន្នាការនៅឆ្នាំ២០២២។

នៅខែកញ្ញា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបាននិយាយថា ចៅក្រមស៊ើបសួរបានប្រាប់អំពីការចោទប្រកាន់ដល់ជនត្រូវចោទ បន្ទាប់ពីមានដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរចេញដោយព្រះរាជអាជ្ញា គឺមិនមែនជាបន្ទុករបស់សាលាឧទ្ធរណ៍ទេ។ តំណាងតុលាការបានលើកឡើងថា ជាធម្មតា ចៅក្រមសាលាឧទ្ធរណ៍ត្រូវអានសំណុំរឿងទាំងមូល និងសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងបន្ទាប់មកចៅក្រមត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេ និងភាគីពាក់ព័ន្ធ។ មុនសួរសំណួរថាតើផ្នែកណាមួយនៃសាលក្រមរបស់សាលាដំបូងខ្លួនប្តឹងមិនសុខចិត្ត និងតើមានមូលហេតុអ្វី។ ជាទូទៅ ជនជាប់ចោទបដិសេធថាខ្លួនមិនបានប្រព្រឹត្តបទល្មើស ឬលើកឡើងថា ការផ្តន្ទាទោសនោះគឺធ្ងន់ធ្ងរពេក។ ដូច្នោះហើយ មិនចាំបាច់តម្រូវឱ្យចៅក្រមត្រូវអានប្រាប់ និងពន្យល់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នោះទេ។ តំណាងតុលាការ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានថ្លែងថា ចៅក្រមនឹងអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទ លុះណាតែ ជនជាប់ចោទនិយាយថា ខ្លួនមិនយល់អំពីបទចោទប្រកាន់លើពួកគេ។[92] តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានលើកឡើងថា ម.ស.ម.ក គួរពិចារណាលើការវាស់វែងចំពោះសិទ្ធិដែលអនុវត្តនៅសាលាឧទ្ធរណ៍បានហើយ ពីព្រោះសិទ្ធិមួយចំនួនដែលសាលាឧទ្ធរណ៍មិនបានប្រាប់នោះ គឺដោយសារសាលាដំបូងបានប្រាប់រួចទៅហើយ ដូច្នោះជនជាប់ចោទបានយល់ដឹងអំពីសិទ្ធិទាំងនោះរួចហើយ។[93]

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

គួរឱ្យសាទរ សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអនុវត្តយ៉ាងល្អប្រសើរក្នុងការគោរពសិទ្ធិជនជាប់ចោទពាក់ព័ន្ធនឹងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់ ដោយហេតុថាចៅក្រមបានអានប្រាប់អំពីបទចោទប្រកាន់ពាក់

[92] លិខិតលេខ ១៩១៩/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[93] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

ព័ន្ធទាំងអស់ក្នុងសំណុំរឿង ១០០% ដែលបានសង្កេតក្នុងឆ្នាំ២០២៣ (១២០ សំណុំរឿង) គឺកើនឡើងបើធៀបនឹងឆ្នាំ ២០២២ មានចំនួន ៩៦,៨%។ លើសពីនេះ តុលាការបានអានប្រាប់ជាប្រចាំនូវទីកន្លែង, កាលបរិច្ឆេទនៃបទល្មើស, ភាគីពាក់ព័ន្ធ និងច្បាប់ពាក់ព័ន្ធ ដែលមានភាពប្រសើរខ្ពស់ជាងលទ្ធផលនៃការសង្កេតឃើញក្នុងឆ្នាំ២០២២។ ជាលទ្ធផល តុលាការត្បូងឃ្មុំមានភាពលេចធ្លោ ដោយសារតុលាការនេះដែលបានគោរពសិទ្ធិនេះទាំងនៅក្នុងឆ្នាំ២០២២ និងឆ្នាំ ២០២៣។

*តួលេខទី១៦៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅតាមតុលាការគោលដៅ*[94]




## ៤.៤. សិទ្ធិមានវត្តមានពេលសវនាការ[95]

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | | |
|---|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ច្បាប់ស្តីពីពន្ធនាគារ[96] |
| មាត្រា ១៤(៣)(ឃ) | មាត្រា ៣៨ | មាត្រា ៣០០ | មាត្រា ៦ និង ៥១ | មាត្រា ៦២ |

ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ [97] ដោយសារតែការធ្វើបែបនេះផ្តល់ឱកាសឱ្យពួកគេបានស្តាប់ និងឆ្លើយតបទៅនឹងភស្តុតាងដែលដាក់បន្ទុកលើពួកគេ និងអាចការពារខ្លួនបាន។ ចំពោះកុមារទំនាស់នឹងច្បាប់វិញ សវនាការត្រូវមានវត្តមាន "មេធាវី ឬជំនួយការផ្នែកច្បាប់សមស្របផ្សេងទៀត"[98] និងវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ឬអ្នកមើលថែផ្សេងទៀត លុះត្រាតែមានការរកឃើញថាប៉ះពាល់ដល់ឧត្តម

94 ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៧៧២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

95 សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមានវត្តមានក្នុងសវនាការ និងសិទ្ធិការពារខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងផ្លូវច្បាប់" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-be-present-at-trial-and-the-right-to-defend-oneself-in-person-or-through-legal-representation

96 ច្បាប់ស្តីពីពន្ធនាគារ (២០១១), http://national-assembly.org.kh/ViewLawFile.aspx?LawDID=406

97 ក.អ.ស.ព.ន មាត្រា ១៤(៣)(ឃ); គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦។

98 គណៈកម្មាធិការអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៣។

ប្រយោជន៍របស់កុមារ ឬតាមការស្នើសុំមិនចូលរួមសវនាការរបស់កុមារ។ [99] សិទ្ធិមានវត្តមាននៅពេលសវនាការអាចអនុវត្តបានចំពោះដំណើរការបណ្តឹងតវ៉ា ប្រសិនបើពាក់ព័ន្ធនឹងបញ្ហានៃអង្គហេតុ និងអង្គច្បាប់ [100] ដែលជាករណីកើតឡើងនៅកម្ពុជា។ ការជំនុំជម្រះ *ដោយកំបាំងមុខ* ពេលគឺក្នុងអវត្តមានជនជាប់ចោទ គឺអាចអនុញ្ញាតបានតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ នៅក្នុងកាលៈទេសៈពិសេស និងនៅពេលដែលជាប្រយោជន៍នៃការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។ [101] យុត្តិកម្មច្បាស់លាស់ត្រូវតែផ្តល់ជូនសម្រាប់ពួកគេ។ [102] ជនជាប់ចោទក៏អាចលះបង់សិទ្ធិមានវត្តមានក្នុងសវនាការបានផងដែរ។[103]

*តួលេខទី១៧៖ ភាគរយនៃសំណុំរឿងដែលជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ នៅតាមតុលាការគោលដៅ*[104]




នៅឆ្នាំ២០២៣ ជនជាប់ចោទ ៨១,៦% (៩១២ នាក់ ក្នុងចំណោមជនជាប់ចោទ ១.១១៨ នាក់) ដែលមានវត្តមាននៅក្នុងសវនាការដែលបានសង្កេត មានការថយចុះបន្តិចបើប្រៀបធៀបទៅនឹងឆ្នាំ២០២២ ដែលមានចំនួន ៨៣,៤%។ ទោះបីជាតួលេខនេះមានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយក៏ដោយ ម.ស.ម.ក បានរកឃើញថា តុលាការចំនួនបីក្នុងចំណោមតុលាការទាំងបួន បានគោរពនូវសិទ្ធិមានវត្តមាននៅពេលសវនាការក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។

## សាលាឧទ្ធរណ៍ភ្នំពេញ

---

99 គណៈកម្មាធិការអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៥៦។

100 គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៣៨៧/១៩៨៩ *Karttunen ទល់នឹងប្រទេសហ្វាំងឡង់* (ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩២) CCPR/C/៤៦/D/៣៨៧/១៩៨៩ វាក្យខណ្ឌ ៧.៣ https://tinyurl.com/267vaeud

101 គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦។

102 គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ០១៦/១៩៧៧, *Mbenge ទល់នឹងប្រទេសហ្សាអៀ* (ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨៣) CCPR/C/១៨/D/១៦/១៩៧៧, វាក្យខណ្ឌ ១៤.១ https://tinyurl.com/2e7vba៣k

103 គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦។

104 ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (១.១១៨ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៧៧២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

សាលាឧទ្ធរណ៍ភ្នំពេញបានគោរពនូវសិទ្ធិមានវត្តមានក្នុងសវនាការជាប្រចាំ ចាប់តាំងពីឆ្នាំ ២០១៧/២០១៨ និងឆ្នាំ២០២៣។ ភាគរយនៃជនជាប់ចោទដែលមានវត្តមាននៅពេលសវនាការមាន ៨១,៥% (៣៧៥ ក្នុងចំណោមជនជាប់ចោទ ៤៦០ នាក់) ដោយធ្លាក់ចុះបន្តិចបើធៀបនឹងឆ្នាំ២០២២ មានចំនួន ៨១,៨% និង៨៣,១% ក្នុងឆ្នាំ២០២១។ ទោះបីជា និន្នាការនេះបង្ហាញពីវឌ្ឍភាពតិចជាងឆ្នាំ ២០១៩/២០២០ ដែលតួលេខនេះមានចំនួន ៩០,២% ក៏ដោយ នេះជាការគួរសាទរចំពោះតុលាការដែលអាចរក្សាកម្រិតខ្ពស់នៃគោរពសិទ្ធិនេះក្នុងរយៈពេលកន្លងមក។

នៅអំឡុងពេលធ្វើរបាយការណ៍ពីមុន អវត្តមានរបស់ជនជាប់ចោទជារឿយៗតែងតែកើតមាន គឺដោយសារតែបញ្ហាភស្តុភារ ព្រមទាំងបញ្ហាទំនាក់ទំនងរវាងតុលាការ និងមណ្ឌលកែប្រែ។ នៅក្នុងករណីជាច្រើន គឺមិនមានការដឹកជញ្ជូនជនជាប់ចោទមកនោះទេ ដោយសារតែតុលាការបានបញ្ជូនព័ត៌មានទៅខុសមណ្ឌលកែប្រែ ឬដោយសារតែមណ្ឌលកែប្រែមិនបានផ្តល់ព័ត៌មានបច្ចុប្បន្នភាព ដល់តុលាការអំពីការផ្ទេរជនជាប់ឃុំទៅមណ្ឌលកែប្រែផ្សេងទៀត។ បញ្ហានេះចាំបាច់ត្រូវដោះស្រាយដោយការកែលម្អនៃការធ្វើកំណត់ត្រា និងទំនាក់ទំនងរវាងតុលាការ និងមណ្ឌលកែប្រែ។ តុលាការក៏បានពន្យល់ដែរថា តុលាការក៏អាចបើកសវនាការលើសំណុំរឿងដោយគ្មានវត្តមានរបស់ជនជាប់ចោទបាន ប្រសិនបើមេធាវីរបស់ពួកគេមានវត្តមាន, ប្រសិនបើបណ្តឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ, ប្រសិនបើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយអយ្យការ ឬប្រសិនបើសំណុំរឿងកកស្ទះនៅតុលាការអស់រយៈពេលយូរ ហើយភាគីស្នើសុំឱ្យចៅក្រមជំនុំជម្រះដោយគ្មានវត្តមានជនជាប់ចោទ។[105]

### *តួលេខទី១៨ ៖ ការវិវត្តនៃសំណុំរឿងដែលជនជាប់ចោទមានវត្តមានពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២៣) គិតជាភាគរយ*[106]

| តើជនជាប់ចោទមានវត្តមានពេលសវនាការដែរឬទេ? | មាន | គ្មាន |
|---|---|---|
| ២០១៤/២០១៥ | ៧៩,០% | ២១,០% |
| ២០១៦/២០១៧ | ៧២,៤% | ២៧,៦% |
| ២០១៧/២០១៨ | ៨២,៥% | ១៧,៥% |

105 លិខិតលេខ ៤៣១/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៩/២០២០ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

106 ទិន្នន័យនេះផ្អែកលើជនជាប់ចោទ ១២៩ នាក់ ដែលមានវត្តមានពេលសវនាការ ក្នុងចំណោមជនជាប់ចោទ ១៦១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតក្នុងឆ្នាំ២០១៤/២០១៥, ជនជាប់ចោទ ៤០៤ នាក់ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទ ៥៥៨ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតក្នុងឆ្នាំ២០១៦/២០១៧, ជនជាប់ចោទ ២៦០ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទ ៣១៥ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតក្នុងឆ្នាំ២០១៧/២០១៨ ,ជនជាប់ចោទ ២៨៤ នាក់ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទ ៣៥២ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតក្នុងឆ្នាំ២០១៨/២០១៩, ជនជាប់ចោទ ២៣០ នាក់ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទ ២៥៥ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតក្នុងឆ្នាំ ២០១៩/២០២០, ជនជាប់ចោទ ៩៨ នាក់ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទ ១១៨ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ត្រូវបានសង្កេតក្នុងឆ្នាំ២០២១, ជនជាប់ចោទ ២៨៨ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទ ៣៥២ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ត្រូវបានសង្កេតក្នុងឆ្នាំ២០២២, ជនជាប់ចោទ ៣៧៥ នាក់ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទ ៤៦០ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៣៦ ដែលបានសង្កេតក្នុងឆ្នាំ២០២៣។

| | | |
|---|---|---|
| ២០១៨/២០១៩ | ៨០,៧% | ១៩,៣% |
| ២០១៩/២០២០ | ៩០,២% | ៩,៨% |
| ២០២១ | ៨៣,១% | ១៦,៩% |
| ២០២២ | ៨១,៨% | ១៨,២% |
| ២០២៣ | ៨១,៥% | ១៨,៥% |

### សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបងបានគោរពសិទ្ធិមានវត្តមានពេលសវនាការនៅក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នា បើគិតត្រឹមឆ្នាំ២០២៣ ដោយមានជនជាប់ចោទចំនួន ៨២,៤% មានវត្តមានពេលសវនាការក្នុងសំណុំរឿងដែលត្រូវបានសង្កេត (២៨៥ ក្នុងចំណោម ៣៤៦ នាក់) មានការថយចុះបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ទៅ ៩១%។ យោងតាមរបកគំហើញនេះ គួរតែមានការយកចិត្តទុកដាក់ ដើម្បីធានាថាសមិទ្ធផលខ្ពស់របស់តុលាការមិនគួរថយចុះនោះទេ។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមអនុប្រធានតុលាការបានមានប្រសាសន៍ថា តុលាការចាត់វិធានការលើបញ្ហានេះយ៉ាងម៉ឺងម៉ាត់ ដោយសារតែវត្តមានរបស់ជនជាប់ចោទក្នុងសវនាការ គឺជាធាតុដ៏ចម្បងមួយនៃលទ្ធភាពទទួលបានយុត្តិធម៌។ ឯកឧត្តមបានមានប្រសាសន៍បន្ថែមថា តុលាការតម្រូវឱ្យជនជាប់ចោទគ្រប់រូបមានវត្តមាន រួមទាំងជនជាប់ចោទដែលបានស្នើសុំមិនបង្ហាញខ្លួនផងដែរ។[107]

### សាលាឧទ្ធរណ៍ព្រះសីហនុ

ជាលើកដំបូង សាលាឧទ្ធរណ៍ព្រះសីហនុបានគោរពសិទ្ធិមានវត្តមានពេលសវនាការនៅឆ្នាំ២០២៣ ដោយមានជនជាប់ចោទ ៩០,៤% បានបង្ហាញខ្លួនពេលសវនាការក្នុងសំណុំរឿងដែលត្រូវបានសង្កេត (១២៣ ក្នុងចំណោម ១៣៦ នាក់)។ នេះជាតួលេខខ្ពស់បំផុតក្នុងចំណោមតុលាការគោលដៅទាំងបួន និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២២ មានត្រឹមតែ ៧៤,៧%។

### សាលាឧទ្ធរណ៍ត្បូងឃ្មុំ

សាលាឧទ្ធរណ៍ត្បូងឃ្មុំបានការគោរពសិទ្ធិមានវត្តមានពេលសវនាការមិនទាន់ឱ្យបានពេញលេញនោះទេ នៅក្នុងឆ្នាំ២០២៣ ដោយមានជនជាប់ចោទតែ ៧៣,៣% (១២៩ នាក់ក្នុងចំណោម ១៧៦ នាក់) ប៉ុណ្ណោះ ដែលបានបង្ហាញខ្លួនពេលសវនាការក្នុងសំណុំរឿងដែលបានសង្កេត។ មានន័យថា ជនជាប់ចោទច្រើនជាងម្នាក់ក្នុងចំណោមបួននាក់ បានអវត្តមានពេលសវនាការក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ នេះគឺជាតួលេខទាបជាងគេក្នុងចំណោមតុលាការគោលដៅទាំងបួន ដែលគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២២ មានចំនួន (៨១,៤%) ដែលត្រូវបានចាត់ថ្នាក់សិទ្ធិនេះថាត្រូវបានគោរព។ ការរកឃើញទាំងនេះបង្ហាញពីភាពចាំបាច់គួរមានវិធានការសមស្រប ដើម្បីធ្វើឱ្យនិន្នាការនេះមានភាពប្រសើរឡើងវិញ ហើយយ៉ាងហោចណាស់ គួរទទួលបាននិន្នាការដូចឆ្នាំ២០២២ ដែរ។ នៅខែ

107 នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

កញ្ញា ឆ្នាំ២០២៣ តំណាងតុលាការ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំបាននិយាយថាសិទ្ធិមានវត្តមានពេលសវនាការរបស់ជនជាប់ចោទមានសារៈសំខាន់ណាស់។ ជាការអនុវត្តកន្លងមក តុលាការនៅតែបន្តកោះហៅជនជាប់ចោទពីបទឧក្រិដ្ឋឱ្យចូលរួមក្នុងសវនាការ ទោះបីជាជនជាប់ចោទនោះ បានបោះបង់សិទ្ធិមិនចូលរួមសវនាការជាមួយនឹងហេតុផលមួយចំនួនក៏ដោយ។[108] សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំបានឆ្លើយតបថា ចំណុចមានវត្តមានរបស់ជនជាប់ចោទពេលសវនាការនេះ គួរជាចំណុចវិជ្ជមានទៅវិញទេ ពីព្រោះកន្លងមកតុលាការបានធ្វើតាមនីតិវិធីច្បាប់ពេញលេញរួចហើយ ដូចជា បានកោះហៅជនជាប់ចោទជាច្រើនដងឱ្យចូលរួមសវនាការ ព្រមទាំងមានការលើកពេលសវនាការ និងមានបានធ្វើសវនាការកំបាំងមុខជាដើម។[109]

## ៤.៥. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

| ច្បាប់អន្តរជាតិ | ច្បាប់ជាតិ |
|---|---|
| ក.អ.ស.ព.ន | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤ (៣) (គ) | មាត្រា ៥៧ |

មាត្រា ១៤(៣)(គ) នៃ ក.អ.ស.ព.ន ធានាថា ជនគ្រប់រូបដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវទទួលបានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ការពន្លឿននីតិវិធីគឺជាធាតុជាសារវន្តមួយនៃការជំនុំជម្រះដោយយុត្តិធម៌។[110] ច្បាប់ជាតិមិនមានបទប្បញ្ញត្តិណាមួយចែងថាសាលាឧទ្ធរណ៍ត្រូវចាត់ការលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនក្នុងវេលាជាក់លាក់ឡើយសម្រាប់ជនជាប់ចោទជានីតិជន។ តែមាត្រា ៥៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា បណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងដោយកុមារទំនាស់នឹងច្បាប់ដែលជាប់ឃុំ តុលាការត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ ខែយ៉ាងយូរ លើកលែងតែមានមូលហេតុសន្យានុម័តមិនអាចជម្នះបាន។ ម.ស.ម.ក នឹងចាត់ទុកថា សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានគោរព ប្រសិនបើតុលាការបានជំនុំជម្រះលើសំណុំរឿងរបស់គេក្នុងអំឡុងពេលតិចជាង ៦ ខែ បន្ទាប់ពីបានទទួលបណ្ដឹងឧទ្ធរណ៍។

*តួលេខទី១៩៖ ចន្លោះពេលរវាងសាលាឧទ្ធរណ៍បានទទួលបណ្ដឹងឧទ្ធរណ៍ (ចុះលេខសំណុំរឿង) រហូតដល់ថ្ងៃសវនាការលើបណ្ដឹងឧទ្ធរណ៍ទាំងនោះ*[111]

[108] នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[109] នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

[110] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៧។

[111] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៧៧២ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

| រយៈពេល | សាលាឧទ្ធរណ៍ភ្នំពេញ | សាលាឧទ្ធរណ៍បាត់ដំបង | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | សាលាឧទ្ធរណ៍ព្រះសីហនុ | សរុប |
|---|---|---|---|---|---|
| តិចជាង ៦ ខែ | ២០៣ | ២២១ | ១០០ | ៧០ | **៥៩៤** |
| ចន្លោះ ៦ ខែ ដល់ ១ ឆ្នាំ | ៥១ | ១១ | ១៤ | ១ | **៧៧** |
| លើសពី ១ ឆ្នាំ ដល់ ២ ឆ្នាំ | ៣៤ | ០ | ៦ | ០ | **៤០** |
| លើស ២ ឆ្នាំដល់ ៣ ឆ្នាំ | ១៥ | ០ | ០ | ០ | **១៥** |
| លើសពី ៣ ឆ្នាំ | ២៥ | ០ | ០ | ០ | **២៥** |
| មិនមានទិន្នន័យ | ៨ | ៩ | ០ | ៤ | **២១** |
| សរុប | **៣៣៦** | **២៤១** | **១២០** | **៧៥** | **៧៧២** |

នៅឆ្នាំ២០២៣ ចំនួន ៧៩,១% នៃសំណុំរឿងដែលបានសង្កេតដែលតុលាការបានចំណាត់ការសវនាការក្នុងរយៈពេលតិចជាង ៦ ខែ ពាក់ព័ន្ធនឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល (៥៩៤ ក្នុងចំណោម ៧៥១ សំណុំរឿង) ដោយបង្ហាញពីការថយចុះ៣,៣% បើធៀបនឹងឆ្នាំមុន។ មានតុលាការចំនួន៣ បានគោរពសិទ្ធិនេះដូចគ្នានៅឆ្នាំ២០២២ដែរ។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា មានសវនាការច្រើនជាងមុនដែលត្រូវបានសង្កេតនៅឆ្នាំ២០២៣ (កើនឡើង ៤៨,២% ធៀបនឹងឆ្នាំ២០២២) ហើយមានសំណុំរឿងច្រើនជាងមុន ដែលមានព័ត៌មានអំពីកាលបរិច្ឆេទរវាងការទទួលបណ្តឹងឧទ្ធរណ៍ និងកាលបរិច្ឆេទសវនាការ (៩៧,៣% នៅឆ្នាំ២០២៣ បើធៀបនឹងឆ្នាំ២០២២ មានចំនួន ៧០,៨%)។

## សាលាឧទ្ធរណ៍ភ្នំពេញ

តុលាការបានជំនុំជម្រះលើសំណុំរឿងក្នុងអំឡុងពេលតិចជាង ៦ ខែ បន្ទាប់ពីសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍ មានចំនួនត្រឹមតែ ៦១,៩% (២០៣ ក្នុងចំណោម ៣២៨ សំណុំរឿង) នៃសំណុំរឿងដែលត្រូវបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញក្នុងឆ្នាំ២០២៣ មានការកើនឡើងបើធៀបនឹងឆ្នាំមុន ចំនួន ២,៤% ដែលតួលេខទាបជាងគេក្នុងចំណោមតុលាការគោលដៅទាំងបួន។ គួរឱ្យកត់សម្គាល់សវនាការត្រូវបានធ្វើក្នុងរយៈពេលលើស ១ ឆ្នាំបន្ទាប់ពីសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿងដែលបានសង្កេតចំនួន ២២,៦% (៧៤ ក្នុងចំណោម ៣២៨ សំណុំរឿង) ដោយកើនឡើងបន្តិច បើធៀបនឹងឆ្នាំ២០២២ មានចំនួន ២២,៤%។ ក្នុងចំណោមនោះ សំណុំរឿង ៣៣,៨% បានចំណាយពេលជាង ៣ ឆ្នាំ (២៥ ក្នុងចំណោម ៧៤ សំណុំរឿង) គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានចំនួន ១៥,៤%។ ការពន្យារពេលបែបនេះនាំឱ្យជនជាប់ចោទស្ថិតក្នុងភាពមិនច្បាស់លាស់ ដែលបានប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ ថាតើពួកគេត្រូវជាប់ឃុំខ្លួនបណ្តោះអាសន្នបន្ត ឬអត់នោះទេ។ ការរកឃើញពីបញ្ហានេះ បានបង្ហាញថាគួរមានវិធានការសមស្របដើម្បីដោះស្រាយសំណុំរឿងដែលយឺតយ៉ាវ និងបង្ហាញថាសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនទាន់ត្រូវបានគោរពយ៉ាងពេញលេញក្នុងអំឡុងពេលពីរជាប់ៗគ្នានេះ។

### សាលាឧទ្ធរណ៍បាត់ដំបង និងព្រះសីហនុ

សវនាការនេះធ្វើឡើងតិចជាងប្រាំមួយខែបន្ទាប់ពីសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍ និងចុះលេខលើបណ្តឹងឧទ្ធរណ៍នោះ មានចំនួន ៩៥,៣% នៃសំណុំរឿងដែលត្រូវបានសង្កេតនៅសាលាឧទ្ធរណ៍**បាត់ដំបង**ក្នុងឆ្នាំ ២០២៣ (២២១ ក្នុងចំណោម ២៣២ សំណុំរឿង) មានការថយចុះបន្តិចបើធៀបនឹង ឆ្នាំ២០២២ មាន ៩៦,៤%។ រីឯនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** តួលេខនេះមានចំនួន ៩៨,៦% (៧០ ក្នុងចំណោម ៧១ សំណុំរឿង) មានការកើនឡើងបើធៀបនឹងឆ្នាំមុន មានចំនួនត្រឹម ៩២,៣%។ នៅខែកក្កដា ឆ្នាំ២០២៤ តំណាងតុលាការ និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងបានលើកឡើងថា តុលាការបានចាត់ការលើសំណុំរឿងនៃបណ្តឹងឧទ្ធរណ៍បន្ទាប់សាលាឧទ្ធរណ៍បានចុះលេខសំណុំរឿង ក្នុងចន្លោះពេល ៦ ខែ ដល់ ១ ឆ្នាំ ដោយសារតែកត្តាមួយចំនួន ដូចជា មានការស្នើសុំពន្យារពេលសវនាការដោយជនជាប់ចោទ ឬមេធាវីការពារសិទ្ធិរបស់គេ ជនជាប់ចោទបានប្តឹងទាស់នឹងសាលដីកាកំបាំងមុខ និងតុលាការបានកោះហៅជនជាប់ចោទដែលនៅក្រៅឃុំជាច្រើនដងតែជនជាប់ចោទមិនបានទទួលដីកានោះ។[112] នៅខែសីហា ឆ្នាំ២០២៤ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានបញ្ជាក់ថាករណីជនជាប់ចោទត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ តុលាការតែងតែចាត់ការលើសំណុំរឿងនោះយ៉ាងរហ័ស គឺមិនទុកយូរជាដាច់ខាត ហើយក្រសួងយុត្តិធម៌ក៏បានជំរុញ និងពន្លឿនលើកិច្ចការនេះដែរ តែមានករណីខ្លះមានការយឺតយ៉ាវនោះអាចជាសំណុំរឿងដែលជនជាប់ចោទនៅក្រៅឃុំ ហើយជនជាប់ចោទបានប្តឹងទាស់នឹងសាលដីកាកំបាំងមុខ ជនជាប់ចោទត្រូវបានកោះហៅច្រើនដងដោយតុលាការតែមិនចូលរួមក្នុងសវនាការ ដូចនេះសវនាការត្រូវពន្យារពេល។[113] ទោះបីជារបកគំហើញទាំងនេះបង្ហាញថា សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ត្រូវបានគោរពដោយតុលាការទាំងពីរ ក្នុងអំឡុងពេល ២ ឆ្នាំជាប់ៗគ្នា និងគួរឱ្យសាទរក៏ដោយ និន្នាការថយចុះនេះ គួរមានការយកចិត្តទុកដាក់ដើម្បីធ្វើឱ្យប្រសើរឡើងវិញថែមទៀត។

### សាលាឧទ្ធរណ៍ត្បូងឃ្មុំ

សាលាឧទ្ធរណ៍ត្បូងឃ្មុំបានបន្តការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ក្នុងឆ្នាំ ២០២៣ មានចំនួន ៨៣,៣% (១០០ ក្នុងចំណោម ១២០ សំណុំរឿង) នៃសំណុំរឿងដែលត្រូវបានសង្កេត។ តួលេខនេះគឺជាការថយចុះបន្តិចបើធៀបនឹងឆ្នាំ២០២២(៨៥,៥%)។

## ៤.៦.សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |

---

112 នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

113 នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

| មាត្រា ១៤(២) | មាត្រា ៣៨ | មាត្រា ៥ |
|---|---|---|

ការសន្មតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិជាមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសាកល ថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានអនុវត្តនៅអំឡុងពេលស៊ើបអង្កេតសំណុំរឿងព្រហ្មទណ្ឌ និងដំណើរការជំនុំជម្រះទាំងមូល រហូតដល់បណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ។[114] នេះមានន័យថា បុគ្គលម្នាក់ត្រូវបានសន្មតទុកជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានបង្ហាញតាមច្បាប់ និងតាមរយៈសេចក្តីសម្រេចស្ថាពរ។ ជាគោលការណ៍ បន្ទុកភស្តុតាងស្ថិតនៅលើស្ថាប័នតំណាងអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទ។[115] ទោះបីជា ជនជាប់ចោទមិននិយាយអ្វី និងមិនបង្ហាញភស្តុតាងអ្វីក៏ដោយ ក៏ពួកគេត្រូវតែបានឱ្យរួចទោសដែរ ប្រសិនបើអយ្យការមិនបានបង្ហាញភស្តុតាងដាក់បន្ទុកចាំបាច់គ្រប់គ្រាន់សម្រាប់ការផ្តន្ទាទោស ម្យ៉ាងវិញទៀត ជនជាប់ចោទមិនមែនជាអ្នកដែលបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថាខ្លួនគ្មានទោសនោះទេ។[116]

### *តួលេខទី២០៖ ចំនួនសំណុំរឿងដែលចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទនូវសិទ្ធិនៅស្ងៀមរបស់ពួកគេ[117]*




សិទ្ធិនៅស្ងៀមជាឫសគល់នៅក្នុងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ ដូច្នេះ ជនជាប់ចោទគ្រប់រូបត្រូវជូនដំណឹងអំពីសិទ្ធិនេះ ហើយច្បាប់កម្ពុជាបានកំណត់ការទទួលខុសត្រូវនេះលើចៅក្រមស៊ើបសួរក្នុងពេលជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ។[118] ទោះយ៉ាងណាក៏ដោយ ម.ស.ម.ក លើកទឹកចិត្តឱ្យចៅក្រមសាលាឧទ្ធរណ៍អនុវត្តនូវការប្រតិបត្តិល្អជាប្រចាំ មិនត្រឹមតែអានប្រាប់ជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពន្យល់អំពីសិទ្ធិនេះផងដែរ។

នៅឆ្នាំ២០២៣ ចៅក្រមបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះមានចំនួន ៣៧,៥% នៃសំណុំរឿងដែលជនជាប់ចោទបានបង្ហាញខ្លួនពេលសវនាការដែលបានសង្កេត (២៥៧ ក្នុងចំណោម ៦៨៥ សំណុំរឿង)។ តួលេខនេះបង្ហាញពីការកើនឡើងបើធៀបនឹងឆ្នាំ២០២២ ដែលមានចំនួន ២៣,៧%។ ដូចគ្នានេះដែរ ភាគរយនៃសំណុំរឿងដែល

---

[114] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី ១) ជំពូកទី ៦ ទំព័រ ២១៩ https://tinyurl.com/35w2rrm6; អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌" (២០១៤) ទំព័រ ១២៥ ផ្នែកទី ១៥.១។

[115] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០។

[116] សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិរក្សាភាពស្ងៀមស្ងាត់" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-the-presumption-of-innocence-and-the-right-to-remain-silent

[117] ទិន្នន័យនេះផ្អែកលើសំណុំរឿងដែលបានសង្កេតចំនួន ៦៨៥ (ក្នុងចំណោម ៧៧២) ដែលជនជាប់ចោទមានវត្តមាននៅពេលសវនាការ។

[118] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៣។

ចៅក្រមខកខានអានប្រាប់ ឬពន្យល់អំពីសិទ្ធិនេះដល់ជនជាប់ចោទបានថយចុះពី ៤៩,២% ក្នុងឆ្នាំ២០២២ មកត្រឹម ៣៤,៣% ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ (២៣៥ ក្នុងចំណោម ៦៨៥ សំណុំរឿង)។ សរុបមក យ៉ាងហោចណាស់ ចៅក្រមបានអានប្រាប់អំពីសិទ្ធិនេះដល់ជនជាប់ចោទចំនួន ៦៥,៧% នៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៣ (៤៥០ក្នុងចំណោម៦៨៥ សំណុំរឿង) គឺមានការកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានតែចំនួន៤៩,២%។ ទោះបីជាមានភាពប្រសើរបែបនេះក៏ដោយ ក៏មានភាពមិនស្មើគ្នារវាងសាលាឧទ្ធរណ៍ព្រះសីហនុ និងសាលាឧទ្ធរណ៍ផ្សេងៗទៀតដែរ។

ម.ស.ម.ក សាទរ សម្រាប់រយៈពេលពីរឆ្នាំជាប់ៗគ្នានេះ មិនមានការលើកឡើងណាមួយដែលថា ចៅក្រមបានទាញសេចក្តីសន្និដ្ឋានថាមានពិរុទ្ធពីការនៅស្ងៀមរបស់ជនជាប់ចោទនោះទេ។ លើសពីនេះ ចៅក្រមភាគច្រើនលើសលុបមិនបានធ្វើសេចក្តីថ្លែងការណ៍អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ មុនពេលចេញសាលដីកានោះទេ។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា ករណីនេះបានកើតឡើងនៅសាលាឧទ្ធរណ៍បាត់ដំបង ដែលប៉ះពាល់ដល់ជនជាប់ចោទចំនួនបីនាក់ (០,៩% នៃចំនួនជនជាប់ចោទសរុប)។

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ក៏ដាក់កាតព្វកិច្ចលើអាជ្ញាធរផងដែរ ដើម្បីធានាថាគ្មានការបង្ហាញពីពិរុទ្ធភាពណាមួយ ដូចជា ដាក់ខ្នោះជើង ខ្នោះដៃ ទ្រុងដែក ឬឯកសណ្ឋានពន្ធនាគារ ត្រូវបានអនុវត្តដល់ជនជាប់ចោទនៅអំឡុងពេលសវនាការឡើយ។[119] ការអនុវត្តល្អជាអន្តរជាតិនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌបង្ហាញថា ជនជាប់ចោទគួរស្លៀកសម្លៀកបំពាក់របស់ខ្លួន នៅពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ប្រការនេះអាចមានលក្ខណៈបុរេនិច្ឆ័យ នៅពេលជនជាប់ឃុំចូលរួមសវនាការនៃបណ្តឹងឧទ្ធរណ៍ដោយស្លៀកពាក់ឯកសណ្ឋានពន្ធនាគារដូចគ្នាទៅនឹងជនជាប់ឃុំ ដែលត្រូវបានកាត់ទោសរួចជាស្ថាពរ ហើយ ដោយសារតែការធ្វើបែបនេះជះឥទ្ធិពលលើសេចក្តីសម្រេចរបស់ចៅក្រម និងការយល់ឃើញរបស់សាធារណជន។

វិធានអង្គការសហប្រជាជាតិឆ្នាំ២០១៥ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ("វិធាននែលសាន់ម៉ាន់ដឺឡា")[120] ដែលតំណាងឱ្យការអនុវត្តល្អ ត្រូវបានទទួលស្គាល់ជាអន្តរជាតិលើការប្រព្រឹត្តទៅលើជនជាប់ឃុំចែងថា ជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះ គួរត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេនៅពេលជំនុំជម្រះ ឬប្រសិនបើពួកគេពាក់ឯកសណ្ឋានពន្ធនាគារ ពួកគេត្រូវតែមាន លក្ខណៈខុសពីទណ្ឌិត។ ដូចគ្នានេះដែរ ជនជាប់ចោទដែលត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ រហូតដល់មានការផ្តន្ទាទោសជាស្ថាពរ។ នៅកម្ពុជាបញ្ហាជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការ ក្នុងឯកសណ្ឋានពន្ធនាគារ គឺជាបន្ទុករបស់អគ្គនាយកដ្ឋានពន្ធនាគារ។

---

[119] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០ *សូមមើលផងដែរ* ECtHR, *Samoila និង Cionca ទល់នឹងប្រទេសរូម៉ានី* (ថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨) ពាក្យស្នើសុំលេខ ៣៣០៦៥/០៣ វាក្យខណ្ឌ ៩៩-១០១ https://tinyurl.com/yaebnffc

[120] មហាសន្និបាតអង្គការសហប្រជាជាតិ, "វិធានអង្គការសហប្រជាជន ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ" ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ៧០/១៧៥ (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥) , https://tinyurl.com/3hrbhupp

យោងតាម*ប្រកាស*របស់ក្រសួងមហាផ្ទៃ ឯកសណ្ឋានពណ៌ខៀវ គឺសម្រាប់ទណ្ឌិតដែលផ្តន្ទាទោសជាស្ថាពរ ចំណែកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីចុងឆ្នាំ២០១៣ គឺសម្រាប់ជនជាប់ឃុំដែលមិនទាន់ត្រូវបានផ្តន្ទាទោសស្ថាពរនៅឡើយ។ [121] ជនជាប់ចោទគួរត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេ ឬយ៉ាងហោចណាស់ ក្នុងឯកសណ្ឋានពណ៌ទឹកក្រូចសម្រាប់ជនជាប់ឃុំដែលមិនទាន់ត្រូវបានផ្តន្ទាទោសជាស្ថាពរ។ ទោះជាយ៉ាងនេះក្តី មិនថាកាលៈទេសៈណាក៏ដោយ អ្នកដែលមិនទាន់បានទទួលការកាត់ទោសជាស្ថាពរ មិនគួរស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវនៅក្នុងសវនាការនៃបណ្តឹងឧទ្ធរណ៍នោះទេ ព្រោះនេះជាការរំលោភលើសិទ្ធិរបស់ពួកគេក្នុងការសន្មតទុកជាមុនថាគ្មានទោស។

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ជនជាប់ចោទចំនួន ៣៦,៥% ក្នុងចំណោមជនជាប់ចោទទាំងអស់ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន និងបង្ហាញខ្លួនពេលសវនាការដែលបានសង្កេត (២៨០ ក្នុងចំណោម ៧៦៨ នាក់) បានពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវសម្រាប់ទណ្ឌិតនៅក្នុងសវនាការរបស់ពួកគេ។ តួលេខនេះបង្ហាញពីកង្វះនូវវឌ្ឍនភាព បើប្រៀបធៀបទៅនឹងឆ្នាំ២០២២ មានចំនួន ៣៤,៥% ដែលនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការសន្មតទុកជាមុនថាគ្មានទោស។ ទោះជាយ៉ាងនេះក្តី មានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយទៀត។ ជនជាប់ចោទផ្សេងពីនោះ បានបង្ហាញខ្លួនពេលសវនាការដោយស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ ទោះបីជាករណីនេះត្រូវបានលើកលែង តែគួរផ្តល់អាទិភាពដល់ការស្លៀកសម្លៀកបំពាក់ស៊ីវិល ដើម្បីគោរពសិទ្ធិនេះឱ្យបានពេញលេញ។ គួរឱ្យសាទរ សម្រាប់រយៈពេលពីរឆ្នាំជាប់ៗគ្នា គ្មានជនជាប់ចោទណាម្នាក់ត្រូវបានដាក់ខ្នោះក្នុងអំឡុងសវនាការដែលបានសង្កេតនោះទេ។

*តួលេខទី២១៖ ការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសដោយតុលាការគោលដៅ*[122]

| រយៈពេល | សាលាឧទ្ធរណ៍ភ្នំពេញ | | | សាលាឧទ្ធរណ៍បាត់ដំបង | | | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | | | សាលាឧទ្ធរណ៍ព្រះសីហនុ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ |
| តើជនជាប់ចោទត្រូវបានដាក់ខ្នោះនៅអំឡុងពេលសវនាការដែរឬទេ? | ០ | ៣៣២ | ១២៨ | ០ | ២៣៥ | ១១១ | ០ | ៩៨ | ៧៨ | ០ | ១០៣ | ៣៣ |
| តើចៅក្រមបានធ្វើសេចក្តីថ្លែងការណ៍ណាមួយអំពីពិរុទ្ធភាពរបស់ជនជាប់ | ០ | ៤៦០ | ០ | ៣ | ៣៤៣ | ០ | ០ | ១៧៦ | ០ | ០ | ១៣៥ | ០ |

[121] *សូមមើល* ព្រឹត្តិបត្រព័ត៌មានរបស់ ម.ស.ម.ក ស្តីពី "ឯកសណ្ឋានពន្ធនាគារ និងការសន្មតទុកជាមុនថាគ្មានទោស" (ខែមិថុនា ឆ្នាំ ២០១៧) https://sithi.org/medias/files/projects/tmp/publication/CCHR%20Fair%20Trial%20Rights%20Newsletter%20on%20the%20Presumption%20of%20Innocence%20_KH.pdf

[122] ទិន្នន័យនេះ គឺផ្អែកលើចំនួនជនជាប់ចោទសរុប (១.១១៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៧៧២ ដែលបានសង្កេត។ មិនពាក់ព័ន្ធ = ជនជាប់ចោទអវត្តមាន ឬមិនជាប់ពន្ធនាគារ។

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចោទមុនពេលចេញសាលដីកាដែរឬទេ? | | | | | | | | | | | | |
| តើមានអ្វីមួយដែលបង្ហាញថា ចៅក្រមទាញការសន្និដ្ឋានអំពីពិរុទ្ធភាពពីការនៅស្ងៀមរបស់ជនជាប់ចោទដែរឬទេ? | ០ | ៣៧៥ | ៨៥ | ០ | ២៨៥ | ៦១ | ០ | ១២៩ | ៤៧ | ០ | ១២៣ | ១៣ |

## សាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍ភ្នំពេញខកខានក្នុងការអានប្រាប់អំពីសិទ្ធិនៅស្ងៀមទៅជនជាប់ចោទក្នុងចំនួន ៣០,២% នៃសំណុំរឿងដែលបានសង្កេត (៨៨ ក្នុងចំណោម ២៩១ សំណុំរឿង)។ នេះ គឺជាការធ្លាក់ចុះបន្តិចបើធៀបនឹងឆ្នាំ ២០២២ ដែលតួលេខនេះមានដល់ ៣៦,២% ហើយមានភាពប្រសើរគួរឱ្យកត់សម្គាល់ក្នុងរយៈពេលនៃការធ្វើរបាយការណ៍ចំនួនបួនលើកដំបូង (សូមមើលតួលេខទី២២) និងគួរសាទរ។ ទោះជាយ៉ាងណាក៏ដោយ តុលាការបានអនុវត្តនូវការប្រតិបត្តិល្អដោយពន្យល់អំពីសិទ្ធិនេះមានចំនួន ១៩,៩% នៃសំណុំរឿងនៅឆ្នាំ២០២៣ នេះបង្ហាញពីនិន្នាការថយចុះបើធៀបនឹង ឆ្នាំ២០២១ មានចំនួនដល់ ៤៨,៧% ដែលជាភាគរយខ្ពស់មិនធ្លាប់មាន។ ដូច្នេះ គួរតែមានការចាត់វិធានការសមស្រប យ៉ាងហោចណាស់ និន្នាការនេះគួរមានដូចឆ្នាំ២០២១ ដែរ។

តំណាងតុលាការនេះធ្លាប់បានថ្លែងថា គោលការណ៍នៃការសន្មតទុកជាមុនថាគ្មានទោស មិនតម្រូវឱ្យចៅក្រមប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេនោះទេ។ តុលាការបានបន្ថែមថា ទោះជាយ៉ាងណា ជនជាប់ចោទមានសេរីភាពក្នុងការអនុវត្តសិទ្ធិនៅស្ងៀមរបស់ពួកគេ ប្រសិនបើជនជាប់ចោទមានបំណងធ្វើដូច្នេះ។[123] នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងតុលាការ និងមហាអយ្យការអមតុលាការបានទទួលស្គាល់ថា ជួនកាលចៅក្រមមិនបានជូនដំណឹងដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ។ តុលាការបាននិយាយថា តុលាការនឹងរៀបចំការប្រជុំជាមួយចៅក្រមទាំងអស់ ហើយណែនាំពួកគេឱ្យធ្វើវាជាប្រចាំ។[124] សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា នឹងពិនិត្យកែសម្រួលអំពីការប្រាប់សិទ្ធិនៅស្ងៀមទៅកាន់ជនជាប់ចោទឱ្យកាន់តែល្អប្រសើរ។[125]

---

[123] លិខិតលេខ ៤៣១/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៩/២០២០ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[124] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[125] លិខិតលេខ៧០៦ រប២/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

*តួលេខទី២២៖ការវិវត្តគិតជាភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់និងពន្យល់ដល់ចុងចោទនូវសិទ្ធិនៅស្ងៀមរបស់ពួកគេ (២០១៤-២០២៣)*[126]




នៅក្នុងរយៈពេលប្រាំមួយឆ្នាំជាប់ៗគ្នា សាលាឧទ្ធរណ៍ភ្នំពេញមិនទទួលបាននូវភាគរយដែលត្រូវបានកំណត់និងចាត់ទុកថា មានការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសនោះនៅឡើយទេ។ ទោះបីជា ភាគរយនៃជនជាប់ចោទដែលបង្ហាញខ្លួនពេលសវនាការរបស់ពួកគេដោយស្លៀកពាក់ក្នុងឯកសណ្ឋានពណ៌ខៀវសម្រាប់ទណ្ឌិតមានការថយចុះបន្តិចជាបណ្តើរៗពី ៣២,៦% ក្នុងឆ្នាំ២០១៩/២០២០ មក ២៣,២% ក្នុងឆ្នាំ២០២៣ (៧៧ ក្នុងចំណោម ៣៣២ នាក់)ក៏ដោយ ក៏តួលេខនេះនៅតែមិនទាន់ដល់កម្រិតកំណត់នៅឡើយ ដើម្បីចាត់ទុកថាមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋាននេះ។ តុលាការគួរអនុវត្តដូចការប្រតិបត្តិបានប្រសើរនៅឆ្នាំ២០១៤/២០១៥ នៅពេលដែលជនជាប់ចោទប្រមាណជាម្នាក់ក្នុងចំណោម ២០ នាក់ បានចូលរួមសវនាការរបស់ពួកគេដោយស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវ នៅក្នុងសំណុំរឿងដែលត្រូវបានសង្កេត។ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថាសិទ្ធិសន្មតជាមុខថាគ្មានទោស គឺជាសិទ្ធិរបស់ជនជាប់ចោទដែលតុលាការត្រូវតែគោរពដោយហ្មត់ចត់ ប៉ុន្តែមិនមែនជាសិទ្ធិដែលតុលាការត្រូវប្រាប់ជនជាប់ចោទនោះទេ។[127]

*តួលេខទី២៣៖ សម្លៀកបំពាក់របស់ជនជាប់ចោទដែលជាប់ឃុំបណ្ដោះអាសន្ននៅពេលបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ*[128]

---

126 ទិន្នន័យដែលបង្ហាញក្នុងតារាងនេះផ្អែកលើចំនួនសំណុំរឿងដែលជនជាប់ចោទមានវត្តមានពេលសវនាការដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នីមួយៗ។

127 លិខិតលេខ៧០៦ បឧ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

128 ទិន្នន័យបង្ហាញក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទត្រូវឃុំខ្លួនបណ្ដោះអាសន្ន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញក្នុងឆ្នាំ២០២៣ (៣៣២ សំណុំរឿង)។




ការមិនទាន់មានភាពប្រសើរនៅតែបន្តមាន ទោះបីមានការទាមទារឱ្យមានការកែលម្អកន្លងមក តាមរយៈកិច្ចពិភាក្សាជាមួយតុលាការជាច្រើនដងក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ។ នៅឆ្នាំ២០២០ តំណាងតុលាការបានលើកឡើងថា សំណួរអំពីឯកសណ្ឋានរបស់ជនជាប់ចោទមិនស្ថិតក្រោមការទទួលខុសត្រូវរបស់តុលាការទេ ដោយបន្ថែមថាតុលាការនឹងមិនជ្រៀតជ្រែកដល់ការអនុវត្តរបស់អគ្គនាយកដ្ឋានពន្ធនាគារឡើយ។[129] នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងតុលាការ និងមហាអយ្យការបានថ្លែងថា តុលាការបានលើកបញ្ហានេះយកទៅពិភាក្សាជាមួយអាជ្ញាធរពន្ធនាគារ ប៉ុន្តែបញ្ហានេះនៅតែកើតមានដដែល។ តុលាការបានបន្តលើកឡើងថានឹងយកបញ្ហានេះទៅពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធនាគារម្តងទៀត។[130]

***តួលេខទី២៤៖ ភាគរយនៃជនជាប់ចោទដែលបានបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញដោយសម្លៀកបំពាក់ឯកសណ្ឋានទណ្ឌិត (២០២១-២០២៣)***[131]




## សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបងសម្រេចបាននូវវឌ្ឍនភាពដ៏ប្រសើរ ចំពោះការអានប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ដោយសារការខកខានអានប្រាប់ពីសិទ្ធិនេះនៅក្នុងសំណុំរឿងដែលបានសង្កេតចំនួន ២៤,៣% ក្នុងឆ្នាំ២០២៣ (៥៤ ក្នុងចំណោម ២២២ សំណុំរឿង) គឺមានការថយចុះបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ ៥៥,៦%។ លើសពីនេះទៀត តុលាការនេះបានអនុវត្តល្អដោយបានពន្យល់អំពី

---

[129] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយឯកឧត្តមប្រធាន និងឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តមអគ្គព្រះរាជអាជ្ញា និងឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ភ្នំពេញ និងឯកឧត្តមអគ្គលេខាធិការ និងអគ្គលេខាធិការរងនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ឆ្នាំ២០១៨/២០១៩ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[130] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[131] ទិន្នន័យបង្ហាញក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទត្រូវឃុំខ្លួនបណ្តោះអាសន្ន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញនៅក្នុងពេលធ្វើរបាយការណ៍នីមួយៗ។

សិទ្ធិនេះមានចំនួន ៧០,៣% នៃសំណុំរឿងដែលបានសង្កេត (១៥៦ ក្នុងចំណោម ២២២ សំណុំរឿង)។ នេះគឺជាតួលេខខ្ពស់បំផុតក្នុងចំណោមតុលាការគោលដៅ និងបានធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២២ មានចំនួនត្រឹម ២១,៨%។ គួរសាទរ តែគួមានវិធានការសមស្របបន្តទៀត ដើម្បីធានាថាវឌ្ឍនភាពដែលគួរឱ្យកត់សម្គាល់នេះ នឹងកាន់តែប្រសើរឡើងបន្តទៀតនៅពេលខាងមុខ។

***តួលេខទី២៥៖ សម្លៀកបំពាក់របស់ជនជាប់ចោទដែលជាប់ឃុំបណ្ដោះអាសន្ននៅពេលបង្ហាញខ្លួននៅសាលាឧទ្ធរណ៍បាត់ដំបង[132]***




ទោះបីជាមានទិន្នន័យដ៏ល្អប្រសើរដែលបានបង្ហាញខាងលើ ម.ស.ម.ក កត់សម្គាល់ឃើញថា ភាគរយនៃជនជាប់ចោទដែលបានជាប់ឃុំ និងស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវនៅក្នុងសំណុំរឿងដែលត្រូវបានសង្កេត មានចំនួនដល់ ៦៥,១% នៅឆ្នាំ២០២៣ (១៥៣ ក្នុងចំណោម ២៣៥ នាក់) គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានតែ ៤៧,៤% នេះជាតួលេខខ្ពស់បើធៀបនឹងតុលាការផ្សេង ដូច្នេះ ការលើកកម្ពស់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសនៅឆ្នាំ២០២៣ មិនទាន់គោរពបានពេញលេញនៅឡើយទេ។ ហេតុនេះ ជនជាប់ចោទដែលបង្ហាញខ្លួនក្នុងឯកសណ្ឋានពណ៌ខៀវពេលសវនាការគឺជាបញ្ហាគួរត្រូវដោះស្រាយ។ ដូចដែលបានរៀបរាប់ខាងលើ ក្នុងស្ថានភាពបែបនេះជាសារមួយបង្ហាញថា ពួកគេមានពិរុទ្ធភាពមុនពេលចេញសាលដីកា ដែលអាចបង្ហាញពីភាពលម្អៀង និងអាចជះឥទ្ធិពលដល់លទ្ធផលនៃការសម្រេចសេចក្ដីដល់ជនជាប់ចោទ។

របកគំហើញទាំងនេះបង្ហាញថា គួរមានវិធានការសមស្រប ដើម្បីឱ្យនិន្នាការនេះប្រសើរឡើងវិញ ដូច្នេះហើយសិទ្ធិនេះត្រូវបានចាត់ទុកថា មិនទាន់បានគោរពពេញលេញនៅឡើយក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នានេះ។ នៅក្នុងខែធ្នូ ឆ្នាំ ២០២២ ឯកឧត្តមអនុប្រធានតុលាការបានលើកឡើងថា ឯកឧត្តមបានស្នើឱ្យមន្ត្រីពន្ធនាគារនាំជនជាប់ចោទមកចូលរួមសវនានាការគឺត្រូវមានសម្លៀកបំពាក់របស់ពួកគេផ្ទាល់ ប៉ុន្តែមន្ត្រីពន្ធនាគារបានឆ្លើយថាការធ្វើបែបនេះគឺត្រូវអគ្គនាយកដ្ឋានពន្ធនាគារហាមឃាត់ដោយសារតែហេតុផលសន្តិសុខ។[133] នៅខែសីហា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍បានអះអាងថា ការស្លៀកពាក់ឯកសណ្ឋានពន្ធនាគាររបស់ជនជាប់ចោទមកចូលរួមសវនាការ គឺជាបន្ទុករបស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលនេះមិនមែនជាការទទួលខុសត្រូវរបស់សាលាឧទ្ធរណ៍ឡើយ។[134]

---

[132] ទិន្នន័យបង្ហាញក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលត្រូវបានឃុំបណ្ដោះអាសន្ន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍បាត់ដំបងក្នុងឆ្នាំ២០២៣ (២៣៥ សំណុំរឿង)។

[133] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[134] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

### សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុបានខកខានក្នុងការអានប្រាប់អំពីសិទ្ធិនៅស្ងៀមចំនួន ៨៦,៧% នៃសំណុំរឿងដែលបានសង្កេត (៦៥ ក្នុងចំណោម ៧៥ សំណុំរឿង) ដែលតួលេខនេះបង្ហាញពីការកើនឡើងបន្តិច បើធៀបនឹងឆ្នាំ២០២២ មានចំនួនត្រឹម ៨៣,៣%។ លើសពីនេះ ចៅក្រមបានពន្យល់អំពីសិទ្ធិនេះចំនួន ១២% នៃសំណុំរឿងដែលបានសង្កេត (៩ ក្នុងចំណោម ៧៥ សំណុំរឿង) គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានចំនួន ៣,៧%។ នៅខែមីនា ឆ្នាំ ២០២៣ តំណាងតុលាការបានលើកឡើងថា ចៅក្រមមិនចាំបាច់អានប្រាប់ដល់ជនជាប់ចោទដែលមានមេធាវីការពារនោះទេ ដោយហេតុថាការធ្វើដូច្នេះ បើតាមទ្រឹស្តីគឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់មេធាវី។[135] យ៉ាងណាក៏ដោយ សិទ្ធិនេះគួរតែត្រូវបានពន្យល់ជាប្រចាំដល់ជនជាប់ចោទដែលមិនមានមេធាវីការពារ និងជាការប្រសើរដែលតុលាការអាចពង្រីកការអនុវត្តបែបនេះដល់ជនជាប់ចោទទាំងអស់ ដើម្បីធានាថាពួកគេបានយល់ពេញលេញ និងជៀសវាងការឆ្លើយដាក់បន្ទុកលើខ្លួនឯងដោយអចេតនា។ នៅខែកញ្ញា ឆ្នាំ២០២៣ តំណាងតុលាការ និងមហាអយ្យការ បានទទួលស្គាល់ថា ជួនកាលចៅក្រមមិនបានអានប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀម។ ទោះយ៉ាងនេះក្តី តុលាការបានកត់សម្គាល់ថាជនជាប់ចោទភាគច្រើនគឺបានយល់ និងអនុវត្ត។ តំណាងតុលាការក៏បាននិយាយថា តុលាការមិនដែលប្រើហិង្សាបង្ខំឱ្យជនជាប់ចោទឆ្លើយទេ បើសួរម្តង ឬពីរដង មិនឆ្លើយទេ តុលាការនឹងបន្តសួរសំណួរផ្សេងទៀត។[136] នៅខែសីហា ឆ្នាំ២០២៤ តំណាងសាលាឧទ្ធរណ៍ព្រះសីហនុ បានលើកឡើងថាខណៈជនជាប់ចោទស្លៀកសំលៀកបំពាក់ទណ្ឌិតក្នុងសវនាការនោះ អាចថាជនជាប់ចោទនោះជាទណ្ឌិតនៃសំណុំរឿងមួយ តែសម្រាប់សំណុំរឿងកំពុងជំនុំជម្រះនេះជាសំណុំរឿងថ្មី ហើយមន្ត្រីពន្ធនាគារមិនបានប្តូរសំលៀកបំពាក់នេះចេញ។ តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានបញ្ជាក់ថា ការស្លៀកពាក់របស់ជនជាប់ចោទនេះមិនមែនជាកំហុសនីតិវិធីទេ ច្បាប់ក៏មិនសរសេរអំពីករណីនេះដែរ ដូច្នោះការវាយតម្លៃរបស់ ម.ស.ម.ក លើការស្លៀកពាក់នេះដូចជាពុំសូវត្រឹមត្រូវទេ។ រីឯការប្រាប់ ឬពន្យល់អំពីសិទ្ធិនេះសាលាដំបូងបានប្រាប់រួចអស់ហើយ ជនជាប់ចោទក៏បានដឹងដែរ និងម្យ៉ាងទៀតការប្តឹងឧទ្ធរណ៍របស់ជនជាប់ចោទមួយចំនួន គឺប្តឹងមិនសុខចិត្តនឹងបទចោទប្រកាន់ មិនសុខចិត្តនឹងការផ្តន្ទាទោស ប្តឹងមិនសុខចិត្តនឹងការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។[137]

*តួលេខទី២៦៖ សម្លៀកបំពាក់របស់ជនជាប់ចោទដែលជាប់ឃុំបណ្តោះអាសន្ននៅពេលបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ព្រះសីហនុ*[138]

135 នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍នេះ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

136 លិខិតលេខ ១៩១៩/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

137 នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

138 ទិន្នន័យបង្ហាញក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលជាប់ឃុំបណ្តោះអាសន្ន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ព្រះសីហនុនៅឆ្នាំ២០២៣ (១០៣ សំណុំរឿង)។




គួរឱ្យសោកស្តាយ ភាគរយនៃជនជាប់ចោទដែលបានចូលរួមសវនាការដោយស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវនៅក្នុងសំណុំរឿងដែលបានសង្កេតមានត្រឹមតែ ១,៩% (២ ក្នុងចំណោម ១០៣ នាក់) ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ នេះគឺជាតួលេខទាបបំផុតនៅក្នុងកំណត់ត្រា និងជាការអនុវត្តដ៏ល្អប្រសើរជាង បើធៀបនឹងឆ្នាំ២០២២ មានចំនួន ២០%។ យោងតាមវិធីសាស្ត្រវាយតម្លៃថ្មីរបស់ម.ស.ម.ក ទិន្នន័យទាំងនេះបង្ហាញថា សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសត្រូវបានគោរពដោយសាលាឧទ្ធរណ៍ព្រះសីហនុក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នា។ ម.ស.ម.ក សាទរតុលាការនេះ ចំពោះការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរពសិទ្ធិនេះ និងស្នើឱ្យតុលាការអាចឱ្យជនជាប់ចោទចូលរួមសវនាការដោយស្លៀកពាក់សម្លៀកបំពាក់ស៊ីវិលកាន់តែប្រសើរ។ នៅខែមីនា ឆ្នាំ២០២៣ តំណាងតុលាការបានលើកឡើងថា តុលាការបានប្រាប់មន្ត្រីពន្ធនាគារឱ្យអនុញ្ញាតឱ្យជនជាប់ចោទមកសវនាការដោយស្លៀកពាក់សម្លៀកបំពាក់ស៊ីវិល[139] ប៉ុន្តែមិនទាន់មានជនជាប់ជាប់បង្ហាញខ្លួនក្នុងសវនាការជាមួយនឹងសម្លៀកបំពាក់ស៊ីវិលនៅឡើយទេ។

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

ភាគរយនៃសំណុំរឿងដែលចៅក្រមនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ខកខានអានប្រាប់អំពីសិទ្ធិនៅស្ងៀមបានថយចុះពី ៥២,៨% ក្នុងឆ្នាំ២០២២ មកចំនួន ២៨,៩% នៅឆ្នាំ២០២៣ (២៨ ក្នុងចំណោម ៩៧ សំណុំរឿង)។ បន្ថែមពីលើការវិវត្តដ៏ប្រសើរនេះ ចៅក្រមបានពន្យល់អំពីសិទ្ធិនេះមានចំនួន ៣៥,១% នៃសំណុំរឿងដែលបានសង្កេត គឺមានការកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានតែ ២៤,៥%។ ដូច្នេះ បើទោះបីជាទិន្នន័យជាភាគរយនៅមានកម្រិតក៏ដោយ ក៏ ម.ស.ម.ក សាទរចំពោះការខិតខំប្រឹងប្រែងដែលតុលាការបានធ្វើឡើងដើម្បីធានាថា ជនជាប់ចោទកាន់តែច្រើនបានដឹង និងយល់ពីសិទ្ធិនេះ។ ម.ស.ម.ក ស្នើដល់តុលាការជានាការគោរពសិទ្ធិជាមូលដ្ឋាននេះ គួរត្រូវបានអនុវត្តជាប្រចាំ។

*តួលេខទី២៧៖ សម្លៀកបំពាក់របស់ជនជាប់ចោទដែលជាប់ឃុំបណ្តោះអាសន្ននៅពេលបង្ហាញខ្លួននៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ*[140]

[139] នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[140] ទិន្នន័យបង្ហាញក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលជាប់ឃុំបណ្តោះអាសន្ន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំក្នុងឆ្នាំ២០២៣ (៩៨ សំណុំរឿង)។




ជនជាប់ចោទដែលជាប់ពន្ធនាគារមាន ចំនួន ៤៩% ដែលបានចូលរួមសវនាការបាន ស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវនៅក្នុងសំណុំរឿងដែលបានសង្កេតនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នៅឆ្នាំ២០២៣ (៤៨ ក្នុងចំណោម ៩៨ នាក់)។ តួលេខនេះបង្ហាញថាមានការថយចុះគួរឱ្យកត់សម្គាល់ និងគួរឱ្យសាទរ បើធៀបនឹងឆ្នាំ២០២២ មានចំនួន ៦៥,៣% ដែលនេះបញ្ជាក់ថា ជិតមួយនាក់ ក្នុងចំណោមជនជាប់ចោទពីរនាក់ រងផលប៉ះពាល់ពីបញ្ហានេះក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសមិនត្រូវបានចាត់ទុកថាបានគោរពពេញលេញក៏ដោយ ក៏សង្ឃឹមថាចៅក្រមមានវិធានការចាំបាច់សមស្រប ដើម្បីឱ្យសិទ្ធិនេះ សម្រេចបាននូវការគោរពកាន់តែប្រសើរនៅឆ្នាំ ២០២៤។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងតុលាការ និងមហាអយ្យការបានពន្យល់ថា ទោះបីជាចៅក្រមណែនាំមន្ត្រីពន្ធនាគារឱ្យអនុញ្ញាតឱ្យជនជាប់ចោទផ្លាស់ប្តូរពីឯកសណ្ឋានពណ៌ខៀវមុនពេលចូលរួមសវនាការក៏ដោយ ក៏មានការបារម្ភថា ជនជាប់ចោទអាចនឹងព្យាយាមរត់គេចខ្លួនក្នុងអំឡុងពេលដំណើរការនីតិវិធី។ តំណាងតុលាការបានបន្តលើកឡើងថា ហានិភ័យនៃការលួចរត់គេចខ្លួនអាចត្រូវបានកាត់បន្ថយ ប្រសិនបើបន្ទប់សវនាការមានស្តង់ដារបច្ចេកទេសប្រហាក់ប្រហែលទៅនឹងប្រទេសមួយចំនួនដទៃទៀត តែយ៉ាងណាតុលាការបានប្តេជ្ញាចិត្តក្នុងការស្វែងរកដំណោះស្រាយជំនួសដើម្បីដោះស្រាយបញ្ហានេះប្រកបដោយប្រសិទ្ធភាព។[141] នៅខែសីហា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានលើកឡើងឆ្លើយតបនឹងការស្លៀកពាក់ឯកសណ្ឋានពន្ធនាគារនេះ ថាសាលាឧទ្ធរណ៍បានត្រៀមសំលៀកបំពាក់ស៊ីវិលរួចរាល់ហើយសម្រាប់ប្តូរឯកសណ្ឋានពន្ធនាគារ (ជាទណ្ឌិត) ដល់ជនជាប់ចោទក្នុងពេលសវនាការ តែមិនទាន់បានអនុវត្តនៅឡើយ។[142]

[141] នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[142] នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

## ៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនទាន់ត្រូវបានគោរពពេញលេញ

### ៥.១.សិទ្ធិមានសេរីភាព

| ច្បាប់អន្តរជាតិ | | ច្បាប់កម្ពុជា | |
|---|---|---|---|
| ស.ស.ស.ម | ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| មាត្រា ៣ | មាត្រា ៩ (១) | មាត្រា ៣២<br>មាត្រា ៣៨ | មាត្រា ២០៣, ២០៤, ២០៥, ២០៨, ២០៩ និង ២១១ |

មាត្រា ៩(១) នៃ ក.អ.ស.ព.ន ធានានូវសេរីភាពរបស់ជនគ្រប់រូបពីការបង្ខាំងរូបរាងកាយ[143] មានន័យថាមិនត្រូវបានដកហូតសេរីភាពជារូបវន្តក្នុងការដើរហើរតាមបំណងប្រាថ្នាឡើយ។[144] ប៉ុន្តែសិទ្ធិមានសេរីភាពមិនមានលក្ខណៈដាច់ខាតទេ។ ហេតុដូចនេះ បុគ្គលម្នាក់ៗអាចត្រូវបានដកហូតសេរីភាពដោយផ្អែកទៅលើមូលដ្ឋាននៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដូចជាការឃាត់ខ្លួននៅដំណាក់កាលនគរបាលយុត្តិធម៌ ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ពន្ធនាគារបន្ទាប់ពីការកាត់ទោសជាដើម។[145] ដោយសារសិទ្ធិមានសេរីភាពមានសារៈសំខាន់ដើម្បីការការពារការសន្មតទុកជាមុនថាគ្មានទោស ការដកហូតសេរីភាពណាមួយដែលធ្វើឡើងក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវតែស្របច្បាប់ ពោលគឺត្រូវអនុវត្តទៅតាមនីតិវិធីដែលច្បាប់កំណត់ និងដោយគោរពនីតិរដ្ឋ[146] និងមិនត្រូវធ្វើតាមអំពើចិត្តឡើយ ពោលគឺមិនត្រូវអនុវត្តដោយមិនត្រឹមត្រូវតាមច្បាប់ អយុត្តិធម៌ ឬមិនអាចដឹងជាមុនបាន មិនមានសំអាងហេតុត្រឹមត្រូវ មិនមានភាពចាំបាច់ ឬមិនសមាមាត្រ។ ឧទាហរណ៍ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែប្រើជាវិធានការដោះស្រាយជាជម្រើសចុងក្រោយ និងធ្វើឡើងតែនៅពេលចាំបាច់ និងនៅក្នុងកាលៈទេសៈពិសេសដែលច្បាប់កំណត់តែប៉ុណ្ណោះ។

ច្បាប់កម្ពុជាចែងយ៉ាងច្បាស់ថា ជាគោលការណ៍ ជនត្រូវចោទត្រូវមានសេរីភាព[147] ហើយការឃុំខ្លួនបណ្តោះអាសន្ននោះអាចប្រើបានតែក្នុង «ករណីពិសេស» ប៉ុណ្ណោះ។[148] មានសារៈសំខាន់ជាខ្លាំងក្នុងការៈ (១) បញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។ (២) រារាំងកុំឱ្យមានគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។ (៣) រក្សាទុកភស្តុតាង ឬតម្រុយសម្ភារៈ (៤) ធានារក្សាជនត្រូវចោទទុក

[143] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣៥ វាក្យខណ្ឌ ៣។

[144] សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិទាំងនេះ សូមមើលនៅក្នុងកម្រងមេរៀនរបស់ ម.ស.ម.ក អំពី «សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-liberty-the-right-to-be-tried-within-reasonable-time-or-to-release-and-the-right-to-be-tried-without-undue-delay

[145] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣៥ វាក្យខណ្ឌ ៥។

[146] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣៥ វាក្យខណ្ឌ ១០។

[147] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៣។

[148] ដូចខាងលើ។

ជូនតុលាការចាត់ការតាមនីតិវិធី (៥) ការពារសន្តិសុខឱ្យជនត្រូវចោទ និង (៦) ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។[149]

ទិន្នន័យពីការសង្កេតសវនាការបង្ហាញថា បានបន្តប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្ន ជាក់ស្ដែងនៅឆ្នាំ២០២៣ ភាគរយនៃជនជាប់ចោទដែលទទួលរងពីវិធានការឃុំខ្លួនជាបណ្ដោះអាសន្ននេះមានការកើនឡើង នៅតុលាការគោលដៅ ៣ ក្នុងចំណោម ៤។ កំឡុងពេលធ្វើបាយការណ៍នេះ មានជនជាប់ចោទដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតចំនួន ៧៥,៤% ទទួលរងនូវការអនុវត្តការឃុំខ្លួននេះ យោងតាមទិន្នន័យដែលទទួលបាន (៦៩១ ក្នុងចំណោម ៩១៧ នាក់) គឺមានការកើនឡើង បើធៀបនឹងឆ្នាំ២០២២ មានចំនួន ៧២,៦%។ ជនជាប់ចោទទាំងអស់នៅតែស្ថិតក្នុងការឃុំខ្លួនក្នុងពន្ធនាគារក្នុងចន្លោះពេលរវាងសវនាការនៃបណ្ដឹងឧទ្ធរណ៍ និងថ្ងៃប្រកាសសាលដីការបស់តុលាការ។ ករណីនេះបង្ហាញថាជនជាប់ចោទច្រើនជាង៣ នាក់ ក្នុងចំណោម ៤ នាក់ ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន នាំឱ្យឃើញថាជាគោលការណ៍មានសេរីភាពមិនត្រូវបានគោរព ដែលការអនុវត្តនេះឃ្លាតពីគោលការណ៍ថា ការឃុំខ្លួនគឺសម្រាប់តែករណីពិសេសតែប៉ុណ្ណោះ។ ការអនុវត្តនេះមិនស្របតាម ក.អ.ស.ព.ន ដែលកម្ពុជាបានទទួលយក និងជាប់កាតព្វកិច្ចនោះទេ។ ម.ស.ម.ក កត់សម្គាល់ថា ក្នុងអំឡុងពេលធ្វើបាយការណ៍នេះ មានជនជាប់ចោទចំនួន ១៨,១% ដែលបានឃុំខ្លួនបណ្ដោះអាសន្ន និងដឹងពីកាលបរិច្ឆេទនៃការចាប់ខ្លួន (៦៧ ក្នុងចំណោម ៣៧១ នាក់) ត្រូវបានឃុំខ្លួនលើសពី ២ ឆ្នាំក្នុងពន្ធនាគារ គិតមកដល់ពេលសវនាការនៃបណ្ដឹងឧទ្ធរណ៍របស់ពួកគេ (សូមមើលតួលេខទី២៩)។

*តួលេខទី២៨ ៖ ភាគរយនៃជនជាប់ចោទដែលត្រូវបន្តការឃុំខ្លួនតាមតុលាការគោលដៅ*[150]




អំឡុងពេលធ្វើបាយការណ៍ពីឆ្នាំ២០២២ និង២០២៣ ភាគរយនៃជនជាប់ចោទដែលត្រូវបានបន្តឃុំខ្លួនបណ្ដោះអាសន្នមុនដំណើរការសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍**ភ្នំពេញ** មានការកើនឡើងពីចំនួន ៧៥,៩% ទៅ ៨២,៧% (៣០៧ ក្នុងចំណោម ៣៧១ នាក់) នៅសាលាឧទ្ធរណ៍**បាត់ដំបង** បានកើនឡើងពី ៧១,២% ទៅ ៧៣,៩% (១៨៤ លើ ២៤៩ នាក់) និងនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** បានកើនពី ៧៦,៧% ទៅ ៨២,១%។ នៅ

149 Ibid. មាត្រា ២០៥។

150 ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទដែលពាក់ព័ន្ធនឹងសំណុំរឿងបានសង្កេតក្នុងឆ្នាំ២០២៣ និងបង្ហាញថាតើពួកគេត្រូវបានឃុំខ្លួនបណ្ដោះអាសន្នដែរឬទេ (៩១៧ ក្នុងចំណោម ១១១៨ នាក់)។

ខែសីហា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍**បាត់ដំបង** បានលើកឡើងថា ចំពោះសំណុំរឿងដែលមានជនជាប់ចោទកំពុងជាប់ឃុំបណ្ដោះអាសន្នក្នុងពន្ធនាគារតែងត្រូវបានផ្ដល់អាទិភាពក្នុងការបើកសវនាការមុនគេ ដូចបង្ហាញក្នុងទិន្នន័យខាងលើ។ សាលាឧទ្ធរណ៍នេះ បានបញ្ជាក់បន្ថែមទៀតថា កិច្ចការនេះបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់តុលាការក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។[151] នៅខែកញ្ញា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍**ព្រះសីហនុ** បានចង្អុលបង្ហាញថា ការឃុំខ្លួនបណ្ដោះអាសន្នតែងតែជាជម្រើសចុងក្រោយ ដោយផ្អែកលើអង្គហេតុ និងស្ថានភាពនៃសំណុំរឿងនីមួយៗ ហើយបានបន្ថែមថាចំនួនមនុស្សដែលត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្នរួចទៅហើយ មិនគួររាប់បញ្ចូលទៅក្នុងវិធានការនេះទេ។[152] នៅខែសីហា ឆ្នាំ២០២៤ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានអះអាងថា ការសម្រេចឱ្យជនជាប់ចោទបន្តការឃុំខ្លួន ឬនៅក្រៅឃុំ អាស្រ័យមានការស្នើសុំរបស់ជនជាប់ចោទ ឬមេធាវីការពាររបស់គេ តែបើគ្មានការស្នើសុំទេនោះតុលាការមិនពិចារណាឱ្យនៅក្រៅឃុំឡើយ បើជនជាប់ចោទដែលឃុំខ្លួនពីសាលាដំបូង គឺនៅតែបន្តការឃុំខ្លួន។[153]

ផ្ទុយទៅវិញ ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** បានបង្ហាញពីការថយចុះនៃការប្រើប្រាស់នូវវិធានការឃុំខ្លួនបណ្ដោះអាសន្នពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារជនជាប់ចោទមានចំនួន ៥៦,៩% ត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្នក្នុងឆ្នាំ២០២៣ បានថយចុះបើធៀបនឹងឆ្នាំ២០២២ គឺមានចំនួនដល់ ៦១,៦%។ ភាពខុសគ្នាដ៏សំខាន់រវាងតុលាការនេះ និងតុលាការដទៃទៀតបង្ហាញថា ចៅក្រមស៊ើបសួរដែលអនុវត្តនូវសេចក្ដីសម្រេចរបស់ខ្លួនទំនងជ្រើសរើសជម្រើសផ្សេងក្រៅពីការឃុំខ្លួនបណ្ដោះអាសន្ន ដែលនេះជាចំណុចគួរឱ្យសាទរ។ ទោះបីមានការកត់សម្គាល់ជាវិជ្ជមានដូច្នេះក្ដី ក៏នៅតែចាត់ទុកថា សិទ្ធិមានសេរីភាព មិនទាន់ត្រូវបានគោរពបានពេញលេញនៅឡើយដែរ ដោយសារមានជនជាប់ចោទជាងពាក់កណ្ដាល ត្រូវរង់ចាំការជំនុំជម្រះរបស់ពួកគេនៅក្នុងពន្ធនាគារ។ ចំពោះតុលាការគោលដៅផ្សេងទៀតក៏មានដូច្នេះដែរ។

មានសារៈសំខាន់គឺការប្រើប្រាស់វិធានការឃុំខ្លួនបណ្ដោះអាសន្នសម្រាប់តែជាករណីលើកលែង និងជាគោលការណ៍គឺសេរីភាព ហើយជនជាប់ចោទត្រូវចាត់ទុកថាជាមនុស្សគ្មានទោស រហូតទាល់តែមានការសម្រេចរបស់តុលាការស្ថាពរថាមានពិរុទ្ធភាព វិធានការដាក់ឱ្យជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការគួរជាជម្រើសចម្បងខណៈដែលមិនប៉ះពាល់វត្តមានរបស់ជនជាប់ចោទក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។

*តួលេខទី២៩៖ រយៈពេលនៃការឃុំខ្លួនគិតពីថ្ងៃឃុំខ្លួនបណ្ដោះអាសន្នរបស់នីតិវិធីសាលាដំបូងមកដល់ថ្ងៃសវនាការលើបណ្ដឹងឧទ្ធរណ៍ នៅតាមតុលាការគោលដៅ*[154]

[151] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីលទ្ធផលនៃសកម្មភាពសង្កេតការណ៍សវនាការរបស់ខ្លួន។

[152] លិខិតលេខ ១៩១៩/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ ម.ស.ម.ក ស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[153] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[154] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទដែលត្រូវឃុំខ្លួនបណ្ដោះអាសន្ន (៦៩១ នាក់) ក្នុងសំណុំរឿងដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣។

| រយៈពេល | សាលាឧទ្ធរណ៍ភ្នំពេញ | សាលាឧទ្ធរណ៍បាត់ដំបង | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | សាលាឧទ្ធរណ៍ព្រះសីហនុ | សរុបជានាក់ |
|---|---|---|---|---|---|
| តិចជាង ១ ឆ្នាំ | ៥១ | ២៤ | ១៩ | ១៦ | ១១០ |
| ១ ដល់ ២ ឆ្នាំ | ១០៥ | ៣២ | ២២ | ៣៥ | ១៩៤ |
| លើស ២ ឆ្នាំដល់ ៣ ឆ្នាំ | ២៦ | មិនមាន | ៤ | ៦ | ៣៦ |
| លើស ៣ ឆ្នាំដល់ ៤ ឆ្នាំ | ២៨ | មិនមាន | ៣ | មិនមាន | ៣១ |
| លើស ៤ ឆ្នាំដល់ ៥ ឆ្នាំ | មិនមាន | មិនមាន | មិនមាន | មិនមាន | មិនមាន |
| លើស ៥ ឆ្នាំ | មិនមាន | មិនមាន | មិនមាន | មិនមាន | មិនមាន |
| មិនដឹងពីរយៈពេលឃុំខ្លួន | ៩៧ | ១២៨ | ៥១ | ៤៤ | ៣២០ |
| សរុប | ៣០៧ | ១៨៤ | ៩៩ | ១០១ | ៦៩១ |

## ៥.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង

| ច្បាប់អន្តរជាតិ | | | ច្បាប់កម្ពុជា | | |
|---|---|---|---|---|---|
| ស.ស.ស.ម | ក.អ.ស.ព.ន | អនុសញ្ញាប្រឆាំងទារុណកម្ម | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ៥ | មាត្រា ១៤(៣)(ឆ) និងមាត្រា ៧ | មាត្រា ១៥ | មាត្រា ៣៨ | មាត្រា ១៤៥ និង ៣២១ | មាត្រា ៥ និង ៦ |

មាត្រា ១៤(៣)(ឆ) នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិបុគ្គលម្នាក់ៗក្នុងការមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។[155] ទីមួយ មាត្រានេះមានន័យថា គ្មានការបង្ខិតបង្ខំទាំងផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ ឬដោយប្រយោលដើម្បីបង្ខំជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌឱ្យផ្តល់ភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។[156] ទីពីរ មាត្រានេះមានន័យថា បុគ្គលទាំងនោះមិនអាចត្រូវបានបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង តាមរយៈការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ហើយមានសេរីភាពក្នុងការប្រើសិទ្ធិមិនផ្តល់ភស្តុតាងដែលអាចប្រើ

[155] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-not-to-be-compelled-to-confess-guilt-or-to-testify-against-oneself

[156] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១ *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៩១២/២០០០ *Deolall ទល់នឹងប្រទេសហ្គីយ៉ាន* (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤), CCPR/C/៨២/D/៩១២/២០០០ វាក្យខណ្ឌ ៥.១ https://tinyurl.com/9ch8r85e គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១២៦៣/២០០៤ និង១២៦៤/២០០៤, *Khuseynova និង Butaeva ទល់នឹងប្រទេសតាហ្ស៊ីគីស្ថាន* (ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨) CCPR/C/៩៤/D/១២៦៣–១២៦៤/២០០៤, វាក្យខណ្ឌ ៨.៣ https://tinyurl.com/3768t8cd អ.វ.ត.ក. កាំង ហ្គេកអ៊ាវ ហៅ ឌុច (សំណុំរឿងលេខ ០០១), អង្គជំនុំជម្រះ (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) វាក្យខណ្ឌ ៣៦០។

ប្រាស់ប្រឆាំងនឹងខ្លួនឯង។[157] ប្រសិនបើជនណាម្នាក់បដិសេធមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពអំពីពិរុទ្ធភាព ក្នុងស្ថានភាពនោះ សេចក្តីសន្និដ្ឋានអវិជ្ជមានណាមួយដែលធ្វើឡើងដោយចៅក្រមចេញពីភាពនៅស្ងៀមនេះ ត្រូវបានហាមឃាត់។[158] នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់៖ កុមារទំនាស់នឹងច្បាប់មិនត្រូវបានបង្ខិតបង្ខំឱ្យ «ផ្តល់សក្ខីកម្ម» ឡើយ។[159]

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង រួមមានការហាមឃាត់ដាច់ខាតចំពោះការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬដាក់ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាប ដូចមានចែងក្នុងមាត្រា ៥ នៃ ស.ស.ស.ម មាត្រា ៧ នៃ ក.អ.ស.ព.ន និងនៅក្នុងអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬដាក់ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាបផ្សេងទៀត ជាពិសេសនៅក្នុងមាត្រា ១៥ នៃអនុសញ្ញា។ ការសារភាព ឬចម្លើយណាមួយដែលទទួលបានតាមរយៈការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬការធ្វើបាបដទៃទៀតមិនត្រូវចាត់ទុកជាភស្តុតាងឡើយ លើកលែងតែប្រើជាភស្តុតាងបង្ហាញថាមានការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬទម្រង់នៃការធ្វើបាបណាមួយបានកើតឡើង។[160] នៅខែសីហា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអះអាងថា ប្រសិនបើមានជនជាប់ចោទលើឡើងថាខ្លួនទទួលរងហិង្សាពីមន្ត្រីនគរបាលយុត្តិធម៌ដើម្បីបានចម្លើយសារភាព ការផ្តល់ភស្តុតាងនេះមិនមែនជាបន្ទុករបស់ព្រះរាជអាជ្ញាទេ គឺជនជាប់ចោទខ្លួនឯងជាអ្នកបង្ហាញភស្តុតាងជូនដល់តុលាការ ហើយតុលាការនឹងធ្វើការហោះហៅមន្ត្រីទាំងនោះមកសាកសួរ។[161]

ទោះបីបញ្ហានេះ ជាបញ្ហាដែលគួរតែដោះស្រាយក្នុងដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរនៃដំណើរការនីតិវិធីក៏ដោយ ចៅក្រមនៃតុលាការគោលដៅគួរតែមានការប្រុងប្រយ័ត្ន និងធានាផងដែរថា រាល់ការលើកឡើងអំពីការបង្ខិតបង្ខំដែលមិនទាន់ត្រូវបានដោះស្រាយក្នុងដំណាក់កាលមុនការជំនុំជម្រះ ត្រូវតែទទួលបានការស៊ើបអង្កេតយ៉ាងហ្មត់ចត់មុនពេលដល់ដំណើរការជំនុំជម្រះ។ ចៅក្រមត្រូវតែសម្រេចថាភស្តុតាងជាចម្លើយសារភាព មិនអាចទទួលយកបានទេ ប្រសិនបើមានមូលដ្ឋានហេតុផលត្រឹមត្រូវដែលបញ្ជាក់ថាភស្តុតាងទាំងនោះទទួលបានមកតាមរយៈការបង្ខិតបង្ខំ។

---

[157] ក.អ.ស.ព.ន មាត្រា ១៤(៣)(ឆ) *សូមមើលអ*.ស.ក មាត្រា ៤០(២)(ខ)(iv)។

[158] ECHR, *Condron និងចក្រភពអង់គ្លេស* (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០០០) ពាក្យស្នើសុំលេខ ៣៥៧១៨/៩៧ វាក្យខណ្ឌ ៥៦, https://tinyurl.com/yc4tphd8 ECHR, *Beckles និងចក្រភពអង់គ្លេស* (ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០២) ពាក្យស្នើសុំលេខ ៤៤៦៥២/៩៨ វាក្យខណ្ឌ ៥៨ https://tinyurl.com/3bw72a74

[159] គណៈកម្មាធិការអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(២)(ខ)(iv)។

[160] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១។

[161] នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើបេកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

*តួលេខទី៣០៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង*[162]




អំឡុងពេលធ្វើរបាយការណ៍នេះ គ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោម ១,១១៨ នាក់ បានលើកឡើងថាពួកគេត្រូវបានស្តាប់ចម្លើយដោយគ្មានវត្តមានមេធាវីនោះឡើយ។ គួរឱ្យសាទរ និងបង្ហាញពីការថយចុះបើធៀបនឹងឆ្នាំ ២០២២ ដែលបញ្ហានេះមានចំនួន ៦ ករណី។ លើសពីនេះ ជនជាប់ចោទតែ ៥ នាក់ប៉ុណ្ណោះ (០,៤% នៃចំនួនសរុប) បានអះអាងថាពួកគេទទួលរងការគំរាមកំហែងឱ្យផ្តល់ចម្លើយសារភាព (ជនជាប់ចោទម្នាក់នៅសាលាឧទ្ធរណ៍**ភ្នំពេញ** និងម្នាក់ទៀតនៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** និងបីនាក់ផ្សេងទៀតនៅសាលាឧទ្ធរណ៍**បាត់ដំបង**) មានការធ្លាក់ចុះបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ ១១ នាក់ (១,៥% នៃសំណុំរឿងសរុប)។

ទោះជាយ៉ាងណាក៏ដោយ ទាក់ទិននឹងបញ្ហានេះ មានជនជាប់ចោទចំនួន ១៦ នាក់ (១,៧% នៃជនជាប់ចោទ ៩១៩ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលជនជាប់ចោទ ឬមេធាវីរបស់ពួកគេបានចូលរួមសវនាការ) បានលើកឡើងថា ខ្លួនទទួលរងនូវអំពើហិង្សា ឬការធ្វើទារុណកម្មលើពួកគេ ដើម្បីទទួលបានចម្លើយសារភាពក្នុងអំឡុងពេលស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌។ តួលេខនេះគឺប្រហាក់ប្រហែលទៅនឹងឆ្នាំ២០២២ ដែលមានជនជាប់ចោទ ១៧ នាក់ (២,៥% នៃចំនួនសរុបជនជាប់ចោទ) នេះជាភាគរយទាបបំផុតដែលមិនធ្លាប់មាននិងគួរឱ្យសាទរ។ ទោះបីជាភាគរយនៃជនជាប់ចោទដែលបានរាយការណ៍ថា បានទទួលរងអំពើហិង្សាក្នុងការបង្ខិតបង្ខំឱ្យសារភាពបានថយចុះជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១៩/២០២០ ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោមក៏ដោយ ជាក់ស្តែងមានការអះអាងស្រដៀងគ្នាជាច្រើនត្រូវបានលើកឡើងអំឡុងពេលធ្វើរបាយការណ៍នីមួយៗបង្ហាញថា ការរំលោភបំពានលើរាងកាយនៅដំណាក់កាលនគរបាលយុត្តិធម៌ នៅតែបន្តកើតមាន។

[162] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទសរុប (១,១១៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៧៧២ ដែលបានសង្កេត។ មិនពាក់ព័ន្ធ = ទាំងជនជាប់ចោទ និងមេធាវីជនជាប់ចោទ មិនមានវត្តមាន ដូច្នេះហើយគ្មាននរណាម្នាក់លើកពីបញ្ហានោះទេ។

*តួលេខទី៣១៖និន្នាការពាក់ព័ន្ធនឹងការលើកឡើងរបស់ជនជាប់ចោទពីអំពើហិង្សា ឬការធ្វើទារុណកម្មពីសំណាក់នគរបាលយុត្តិធម៌ ដើម្បីបង្ខិតបង្ខំឱ្យសារភាពនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២១) និងតុលាការគោលដៅទាំងបួន (ចាប់តាំងពីឆ្នាំ ២០២២)។*[163]




នៅឆ្នាំ២០២៣ ការអះអាងភាគច្រើនអំពីការធ្វើទារុណកម្មនៅក្នុងដំណាក់កាលនគរបាលយុត្តិធម៌ ត្រូវបានលើកឡើងនៅចំពោះមុខសាលាឧទ្ធរណ៍**ព្រះសីហនុ** (មានជនជាប់ចោទចំនួន ៨ នាក់ ស្មើនឹង ៦,៣% នៃចំនួនសរុប)។ នៅសាលាឧទ្ធរណ៍**ភ្នំពេញ** (មានជនជាប់ចោទចំនួន ៤ នាក់ ស្មើនឹង ១% នៃចំនួនសរុប)។ នៅសាលាឧទ្ធរណ៍**បាត់ដំបង** (មានជនជាប់ចោទចំនួន ៣នាក់ ស្មើនឹង ១,១% នៃចំនួនសរុប) និងនៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** (មានជនជាប់ចោទចំនួន ១ នាក់ ស្មើនឹង ០,៧% នៃចំនួនសរុប)។ ទោះបីជាមានតួលេខទាបក៏ដោយ ការបង្ខិតបង្ខំ ឬការរំលោភបំពាន(ទាំងផ្លូវចិត្ត ឬផ្លូវកាយ) ក្នុងអំឡុងពេលស្តាប់ចម្លើយ គឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង។ ការហាមឃាត់ការធ្វើទារុណកម្មគឺមានលក្ខខណ្ឌពិសេសនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សិទ្ធិនេះមិនត្រឹមតែជាសិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិបាននោះទេ ថែមទាំងជាសិទ្ធិដាច់ខាតផងដែរ ហើយមានការទទួលស្គាល់យ៉ាងទូលំទូលាយថាជាបទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិ (*គោលការណ៍ ជូស ខូស្សិន*)។[164]

**វាក្យសព្ទច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ៖**

***សិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិបាន*** *៖* សិទ្ធិដែលរដ្ឋាភិបាលមិនអាចព្យួរការអនុវត្តបានក្នុងកាលៈទេសៈនៃ «ការដាក់ប្រទេសក្នុងគ្រាអាសន្ន» ក្រោមមាត្រា ៤ នៃ ក.អ.ស.ព.ន។

[163] ទិន្នន័យនេះផ្អែកលើភាគរយនៃជនជាប់ចោទដែលបានលើកឡើងថា មានការប្រើអំពើហិង្សា ឬការធ្វើទារុណកម្មមកលើពួកគេដើម្បីបង្ខិតបង្ខំពួកគេឱ្យសារភាពចំពោះបទល្មើសដែលចោទប្រកាន់មកលើពួកគេនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ(រហូតដល់ឆ្នាំ ២០២១) និងភាគរយនៃជនជាប់ចោទដែលបានលើកឡើងដូចគ្នានៅចំពោះមុខតុលាការគោលដៅទាំងបួន ក្នុងសំណុំរឿងដែលជនជាប់ចោទ ឬមេធាវីរបស់ពួកគេមានវត្តមានចូលរួមសវនាការ (ចាប់ពីឆ្នាំ២០២២ ទៅ)។ ដោយហេតុថាសាលាឧទ្ធរណ៍ភ្នំពេញមានយុត្តាធិការគ្របដណ្តប់ទូទាំងប្រទេស មុនពេលដែលសាលាឧទ្ធរណ៍ទាំងបីចាប់ផ្តើមដំណើរការ ក្នុងខែមេសា ឆ្នាំ២០២០ ដូច្នេះតួលេខចុងក្រោយក្នុងអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ អាចត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីនិន្នាការទាំងមូល។ និន្នាការនេះក៏ត្រូវអនុវត្តចំពោះតួលេខចាប់ពីឆ្នាំ២០២២ ទៅមុខដែរ ក្នុងពេលដែល ម.ស.ម.ក បានចាប់ផ្តើមការសង្កេតសវនាការរបស់ខ្លួននៅតុលាការទាំងបីនោះ។ តួលេខក្នុងឆ្នាំ២០២១ ត្រូវបានបង្ហាញដើម្បីបញ្ចៀសគម្លាតក្នុងទិន្នន័យ ហើយឆ្លុះបញ្ចាំងតែអំពីស្ថានភាពដែលស្ថិតក្រោមយុត្តាធិការរបស់សាលាឧទ្ធរណ៍ភ្នំពេញប៉ុណ្ណោះ។

[164] Manfred Nowak កតិកាសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – សេចក្តីពន្យល់របស់ CCPR (បោះពុម្ពផ្សាយលើកទី២, N.P Engel ឆ្នាំ២០០៥) ទំព័រ ១៥៧។

***សិទ្ធិដាច់ខាត៖*** សិទ្ធិដែលមិនត្រូវបានអនុញ្ញាតឱ្យមានការរិតត្បិតណាមួយ។

***បទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិទូទៅ (ជូស ខូស្សិន)*** ៖ "បទដ្ឋានដែលត្រូវបានសហគមន៍អន្តរជាតិនៃបណ្តារដ្ឋទាំងអស់ ទទួលយក និងទទួលស្គាល់ថា ជាបទដ្ឋានមួយដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន ហើយអាចកែប្រែបានតាមរយៈបទដ្ឋានដែលនៅក្រោមច្បាប់អន្តរជាតិទូទៅដែលមានលក្ខណៈដូចគ្នាតែប៉ុណ្ណោះ»។[165]

នៅខែសីហា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍**បាត់ដំបង** បានលើកឡើងថា ជាទូទៅជនជាប់ចោទដែលលើកឡើងថាខ្លួនរងនូវការគំរាមកំហែង ឬទារុណកម្មក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ មិនអាចបង្ហាញភស្តុតាងដែលគួរឱ្យជឿជាក់បានទេ។ ដូច្នេះ គឺអាស្រ័យលើចៅក្រមដែលមានសិទ្ធិក្នុងការសម្រេចថាជឿ ឬមិនជឿដោយឥស្សរចិត្ត។[166] នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍**ភ្នំពេញ** និងមហាអយ្យការអមសាលាឧទ្ធរណ៍បានលើកឡើងថា ការលើកឡើងរបស់ជនជាប់ចោទថាខ្លួនទទួលរងនូវហិង្សា ឬទារុណកម្មនៅដំណាក់កាលនគរបាលយុត្តិធម៌ គឺមិនមានប្រយោជន៍អ្វីក្នុងពេលសវនាការនៅសាលាឧទ្ធរណ៍ទេ ដោយសារតែការស្នើសុំមោឃភាពនីតិវិធីស៊ើបអង្កេតមិនអាចអនុវត្តបានទេនៅក្រោយការចេញដីកាដំណោះស្រាយ ដូចមានចែងក្នុងមាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ទោះជាយ៉ាងណាក៏ដោយ តុលាការថា ចៅក្រមសាលាឧទ្ធរណ៍នៅតែយកចិត្តទុកដាក់ជាពិសេសចំពោះការលើកឡើងបែបនេះ តែជាទូទៅជនជាប់ចោទគ្មានភស្តុតាងជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីឱ្យចៅក្រមពិចារណាពីបញ្ហានេះឡើយ។[167]

ក្នុងករណីដែលជនជាប់ចោទបានអះអាងថា មានការរំលោភមកលើសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាពរបស់ពួកគេ នោះបន្ទុកភស្តុតាងត្រូវស្ថិតនៅលើភាគីដែលបានចោទប្រកាន់នោះ មិនមែនជាបន្ទុករបស់ជនជាប់ចោទត្រូវបង្ហាញនោះទេ។ [168] ដោយសារមិនមានការស៊ើបអង្កេតឱ្យបានពេញលេញចំពោះការលើកឡើងរបស់ជនជាប់ចោទអំពីការធ្វើទារុណកម្មក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ សិទ្ធិនេះមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយទេ។ នៅសាលាឧទ្ធរណ៍**ព្រះសីហនុ** មានជនជាប់ចោទលើសពីម្នាក់ ក្នុងចំណោម ២០ នាក់ដែលបានចូលរួមសវនាការក្នុងឆ្នាំ២០២៣ បានអះអាងថាពួកគេរងការរំលោភបំពាននៅក្នុងដំណាក់កាលស៊ើបអង្កេត។ នេះជាបញ្ហាមួយគួរតែយកចិត្តទុកដាក់ ព្រោះវាជាបញ្ហាកើតមានជាច្រើននៅដំណាក់ស៊ើបអង្កេតដែលធ្វើឡើងដោយនគរ

---

[165] គណៈកម្មការច្បាប់អន្តរជាតិ, «របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងារនៃសម័យប្រជុំទី ៧១ របស់ខ្លួន» សេចក្តីបន្ថែមលេខ ១០ (A/៧៤/១០) (២០១៩) វាក្យខណ្ឌ ៥៦ https://tinyurl.com/42tkj27m

[166] នៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងមកពីសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីលទ្ធផលនៃសកម្មភាពសង្កេតការណ៍សវនាការរបស់ខ្លួន។

[167] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។

[168] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១ *សូមមើលផងដែរ* គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១០៣៣/២០០១, *Singarasa ទល់នឹងប្រទេស ស្រីលង្កា* (ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤) CCPR/C/៨១/D/១០៣៣/២០០១ វាក្យខណ្ឌ ៧.៤ https://tinyurl.com/3zhujfvk ; គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤, *Khuseynova និង Butaeva ទល់នឹងប្រទេស តាហ្ស៊ីគីស្ថាន* (ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨) CCPR/C/៩៤/D/១២៦៣-១២៦៤/២០០៤ វាក្យខណ្ឌ ៨.៣ https://tinyurl.com/4ccert5k

បាលយុត្តិធម៌។ នៅខែសីហា ឆ្នាំ២០២៤ តំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានអះអាងថា ជនជាប់ចោទមួយចំនួនបានលើកឡើងថាខ្លួនរងការប្រើហិង្សាដើម្បីបង្ខំឱ្យសារភាព តែនៅពេលដែលតុលាការសួរអំពីឈ្មោះរបស់មន្ត្រីនគរបាលដែលប្រើហិង្សានោះ បែរជាជនជាប់ចោទប្តូរសុំឱ្យតុលាការបន្ធូរបន្ថយទោសទៅវិញ។ តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានសង្កត់ធ្ងន់ថា របាយការណ៍នេះពុំសូវផ្តោតលើនីតិវិធីច្បាប់ទេ គឺផ្តោតលើសិទ្ធិរបស់ជនជាប់ចោទច្រើនជាង។[169]

## ៥.៣.សិទ្ធិបង្ហាញភស្តុតាង

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ង) | មាត្រា ១៥៣, ១៥៤, ២៩៨, ៣២១, ៣២២, ៣២៤, ៣២៦, ៣២៨ និង ៣៩៤ | មាត្រា ៦ |

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការ ត្រូវតែផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ។ ដូច្នេះភាគីនីមួយៗត្រូវមានលទ្ធភាពបង្ហាញភស្តុតាង និងហៅសាក្សីរបស់ខ្លួន ដើម្បីសាកសួរដេញដោលលើភស្តុតាង និងសាក្សីដែលបានបង្ហាញដោយភាគីម្ខាងទៀត និងតតាំងនឹងភស្តុតាងដែលពួកគេមិនទទួលយក។[170] ចំណុចនេះជាការចាំបាច់ណាស់ ដើម្បីធានាបាននូវសិទ្ធិស្មើគ្នារវាងភាគីពាក់ព័ន្ធ ជាគោលការណ៍មូលដ្ឋាន តម្រូវឱ្យមានការប្រព្រឹត្តចំពោះភាគីទាំងអស់ក្នុងរបៀបដែលធានានូវភាពស្មើគ្នាគ្រប់ដំណាក់កាលនៃការជំនុំជម្រះ ហើយគ្មានភាគីណាមួយត្រូវបាត់បង់ឱកាសក្នុងការបង្ហាញរឿងក្តីរបស់ខ្លួនឡើយ។ ការផ្តល់ភស្តុតាងតាមរយៈសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ (មិននៅក្នុងអំឡុងពេលសវនាការ) មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ប្រសិនបើពួកគេបានតទល់ និងសាកសួរសាក្សីនៅពេលដែលសាក្សីនោះបានផ្តល់សក្ខីកម្ម ឬនៅដំណាក់កាលនៃដំណើរការនីតិវិធីមុនពេលការជំនុំជម្រះ។[171]

គួរឱ្យសាទរ ព្រោះគ្មានសវនាការណាមួយក្នុងចំណោមសវនាការចំនួន ៧៧២ ដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានបង្ហាញថាមេធាវីការពាររបស់ជនជាប់ចោទមិនបានទទួលឱកាសហៅសាក្សីនោះទេ។

---

169 នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

170 គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ១៣ និង ៣៩។ សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិទាំងនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក «សិទ្ធិបង្ហាញភស្តុតាង (សិទ្ធិហៅ និងសាកសួរសាក្សី)» (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/fair-trial-rights/evidentiary-rights-right-to-call-and-examine-witnesses

171 *សូមមើល ឧ.* ECHR *Mirilashvili ទល់នឹងប្រទេស រុស្ស៊ី* (ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨) ពាក្យស្នើសុំលេខ ៦២៩១/០៤ វាក្យខណ្ឌ ១៦៣ https://tinyurl.com/4kktr8yr ECtHR, *Asch ទល់នឹងប្រទេស អូទ្រីស* (ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩១) លេខ A ២០៣ វាក្យខណ្ឌ ២៧ https://tinyurl.com/bdfpm2ah ECtHR,*Isgrò ទល់នឹងប្រទេសអ៊ីតាលី* (ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩១) លេខ A ១៩៤-A វាក្យខណ្ឌ៣៤, https://tinyurl.com/39mz7s7h ECtHR, *Kostovski ទល់នឹងប្រទេសហូឡង់* (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) លេខ A ១៦៦ វាក្យខណ្ឌ ៤១ https://tinyurl.com/2e2pbxsh

មានសំណុំរឿងចំនួន ៣ ដែលជនជាប់ចោទមិនត្រូវបានផ្តល់ឱកាសឱ្យហៅសាក្សីក្នុងឆ្នាំ២០២២ ដែលស្មើនឹងចំនួន ០,៦% នៃចំនួនសរុប។ លើសពីនេះ ក្នុងរយៈពេល ២ ឆ្នាំជាប់ៗគ្នានេះ គ្មានអ្វីបង្ហាញថាភាគីណាមួយមិនត្រូវបានផ្តល់ឱកាសឱ្យបង្ហាញភស្តុតាង ឬពិនិត្យមើលសំណុំរឿងមុនពេលសវនាការនោះទេ ឬបង្ហាញថាចៅក្រមបានចេញសាលក្រមដោយផ្អែកលើភស្តុតាងដែលមិនមាននៅក្នុងសំណុំរឿង ឬមិនបានបង្ហាញនៅក្នុងសវនាការទេ។ ទោះបីគួរឱ្យសាទរក៏ដោយ សិទ្ធិបង្ហាញភស្តុតាងនៅតែមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដោយផ្អែកលើមូលហេតុចម្បងចំនួនបី៖

ទីមួយ តុលាការគោលដៅត្រូវតែធានាថា ភស្តុតាងជាសំអាងនោះមានតម្លៃគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះ (អាចទុកចិត្តបាន និងត្រឹមត្រូវ)។ គុណភាព និងបរិមាណនៃភស្តុតាងដែលត្រូវបានបង្ហាញ និងពិចារណាក្នុងអំឡុងពេលជំនុំជម្រះ គឺជាការចាំបាច់ណាស់ដើម្បីធានាថាបុគ្គលណាមួយថាមានពិរុទ្ធភាព ត្រូវមានភស្តុតាងឱ្យហួសពីវិមតិសង្ស័យ។ បន្ថែមពីលើភស្តុតាងឯកសារ ចៅក្រម និងព្រះរាជអាជ្ញា គួរតែស្វែងរក និងពិនិត្យលើប្រភេទភស្តុតាងផ្សេងទៀតដែលពាក់ព័ន្ធ ដូចជា សាក្សីផ្ទាល់ ភស្តុតាងវេជ្ជសាស្ត្រ និងភស្តុតាងកោសល្យវិច្ច័យជាដើម។ ទោះជាយ៉ាងនេះក្តី គួរកត់សម្គាល់ថា ព្រះរាជអាជ្ញាបានបង្ហាញភស្តុតាងជាកោសល្យវិច្ច័យក្នុងសវនាការដែលបានសង្កេតនៅឆ្នាំ២០២៣ តែ ០១ សំណុំរឿងប៉ុណ្ណោះ ដែលស្មើនឹង ០,១៣% នៃចំនួនសំណុំរឿងសរុប។ ជាមួយគ្នានេះដែរ ភស្តុតាងបែបវិជ្ជសាស្ត្រមិនធ្លាប់ត្រូវបង្ហាញដោយព្រះរាជអាជ្ញាឡើយ ហើយមានសំណុំរឿងត្រឹមតែ ៧,៤% ប៉ុណ្ណោះដែលសាក្សីត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម (៥៧ ក្នុងចំណោម ៧៧២ សំណុំរឿង)។ ភាពកម្របង្ហាញភស្តុតាងក្នុងទម្រង់ផ្សេងៗគ្នា មិនត្រឹមប៉ះពាល់ដល់ភាពរឹងមាំនៃដំណើរនីតិវិធីរបស់តុលាការនោះទេ តែថែមទាំងអាចប៉ះពាល់ដល់ការទទួលបានយុត្តិធម៌ និងភាពត្រឹមត្រូវនៃការសម្រេចសេចក្តីផងដែរ។

ខណៈពេលដែលចម្លើយសារភាពត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃភស្តុតាង នោះក៏អាចនឹងទទួលរងនូវឥទ្ធិពលដោយកត្តាផ្សេងៗ ដូចជា ការបង្ខិតបង្ខំ ការប្រើហិង្សា ឬការយល់ច្រឡំ។ កត្តាទាំងនេះ អាចនាំឱ្យមានភាពមិនត្រឹមត្រូវនៅក្នុងការបង្ហាញភស្តុតាងផ្សេងៗ និងអាចប៉ះពាល់ដល់ភាពដែលអាចទុកចិត្តបាននៃការសម្រេចសេចក្តីរបស់តុលាការ។ ហេតុដូចនេះហើយ ជាការចាំបាច់ណាស់ដែលការសម្រេចត្រូវមានការប្រុងប្រយ័ត្នខ្ពស់ និងធានាថាសេចក្តីសម្រេចរបស់តុលាការត្រូវតែផ្អែកលើភស្តុតាងជាច្រើនដែលមានទម្រង់ផ្សេងគ្នា។ នៅឆ្នាំ២០២៣ ចម្លើយសារភាពត្រូវបានយកធ្វើជាភស្តុតាងនៅក្នុងសវនាការចំនួន ៨៧ នៃសវនាការដែលបានសង្កេត ជាសវនាការដែលបានប្រកាសសាលដីកាប្រួចហើយ។ តុលាការបានយកចម្លើយសារភាពទាំងនោះជាភស្តុតាងសំអាងមានចំនួន ២១ សំណុំរឿងដែលស្មើនឹង ២៥,៩% នៃចំនួនសំណុំរឿងសរុប។ តួលេខនេះមានភាពប្រសើរគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២២ ដែលតួលេខមានចំនួន ៦៣%។ គួរឱ្យសាទរចំពោះសាលាឧទ្ធរណ៍**ភ្នំពេញ** បានយកចម្លើយសារភាពជាសំអាងក្នុងសំណុំរឿងពាក់ព័ន្ធមានចំនួនមួយភាគបីក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ(៣ ក្នុងចំណោម ៩ សំណុំរឿង) មានការថយបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ ៧៨,៣%។ នៅសាលាឧទ្ធរណ៍**បាត់ដំបង** តួលេខនេះក៏មានការថយចុះដែរគឺមានចំនួន ១១,១% (៧ ក្នុងចំណោម ៦៣)បើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ ២១,៤%។ ដោយឡែកនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** បានបន្តយកការសារភាពជាមូលដ្ឋានសំអាងក្នុងការសម្រេចសេចក្តីរបស់ខ្លួនមានចំនួន

៧៣,៣% (១១ ក្នុងចំណោម ១៥ សំណុំរឿង) គឺមានការធ្លាក់ចុះបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់១០០%។ រីឯសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**វិញ មិនបានយកចម្លើយសារភាពជាសំអាងសម្រាប់ការសម្រេចសេចក្ដីនោះទេ។

ទី២ ច្បាប់កម្ពុជាកំណត់ថាអ្នកជំនាញ និងសាក្សីដែលតុលាការកោះហៅ ត្រូវរង់ចាំនៅក្នុងបន្ទប់ដែលបានរៀបចំជាស្រេចសម្រាប់ពួកគេ ហើយពួកគេមិនត្រូវបានអនុញ្ញាតឱ្យមើល ឬស្ដាប់នូវអ្វីដែលកំពុងកើតឡើងនៅក្នុងបន្ទប់សវនាការមុនពេលធ្វើសក្ខីកម្មនោះទេ។[172] ចំណែកឯសាក្សីដែលមិនត្រូវបានកោះហៅជាផ្លូវការ អាចចូលក្នុងបន្ទប់សវនាការតាំងពីដំបូងបាន តែពួកគេនឹងត្រូវណែនាំឱ្យនៅក្នុងបន្ទប់រង់ចាំ ប្រសិនបើ ប្រធានសវនាការសម្រេចថានឹងស្ដាប់ចម្លើយរបស់ពួកគេ នៅពេលដែលមានការស្នើសុំពីភាគីណាមួយប៉ុណ្ណោះ។[173] ទោះបីជាយ៉ាងណាក៏ដោយ ក្នុងសំណុំរឿងចំនួន ៣៦,៨% ដែលមានការកោះហៅសាក្សី (២១ ក្នុងចំណោម ៥៧ សំណុំរឿង) សាក្សីទាំងនោះមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលពួកគេត្រូវបានសាកសួរ។ ទោះបីជាចំនួននេះ បង្ហាញពីភាពប្រសើរបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ទៅ ៤១,៩% ក៏ដោយ តែការអនុញ្ញាតឱ្យសាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការមានចំនួនជាងមួយភាគបី ដែលការអនុវត្តបែបនេះ អាចនាំឱ្យសក្ខីកម្មរបស់សាក្សីទទួលឥទ្ធិពលពីសក្ខីកម្មរបស់សាក្សីផ្សេងទៀត។ ទោះបីជា មានភាពខុសគ្នាពីតុលាការមួយទៅតុលាការមួយក៏ដោយ គ្មានតុលាការណាមួយក្នុងចំណោមតុលាការទាំងបី បានអនុវត្តប្រសើរនៅឡើយពាក់ព័ន្ធនឹងការមិនមានវត្តមានរបស់សាក្សីក្នុងបន្ទប់សវនាការ។

ទាក់ទិននឹងបញ្ហានេះ ទាំងសាលាឧទ្ធរណ៍**បាត់ដំបង** និង**ត្បូងឃ្មុំ** ឃើញមានការកើនឡើងដូចគ្នាពីមួយឆ្នាំទៅមួយឆ្នាំ គិតជាភាគរយនៃសំណុំរឿងពាក់ព័ន្ធ ដែលសាក្សីត្រូវបានអនុញ្ញាតឱ្យនៅក្នុងបន្ទប់សវនាការមុនពេលផ្ដល់សក្ខីកម្មពី ៣៨,៩% ទៅ ៦៤,៣% (៩ ក្នុងចំណោម ១៤ សំណុំរឿង) និងពី ៣៨,៥% ទៅ ៦២,៥% (១០ ក្នុងចំណោម ១៦ សំណុំរឿង) នៅក្នុងសាលាឧទ្ធរណ៍នីមួយៗ។ កាលពីខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍**បាត់ដំបង** មានប្រសាសន៍ថា ក្នុងករណីមួយចំនួន សាក្សីមានវត្តមាន នៅក្នុងបន្ទប់សវនាការ ដោយសារតែភាគីបានអញ្ជើញសាក្សីដោយមិនបានជូនដំណឹងដល់តុលាការ។[174] នៅក្នុងខែសីហា ឆ្នាំ២០២៣ តំណាងរបស់តុលាការនេះបានលើកឡើងថា តុលាការអនុញ្ញាតឱ្យសាក្សីរង់ចាំនៅក្នុងបន្ទប់សវនាការ ប្រសិនបើជនជាប់ចោទបានសារភាពរួចហើយ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះសាក្សីថ្មី និងសាក្សីក្នុងសំណុំរឿងជួញដូរគ្រឿងញៀន មិនត្រូវបានអនុញ្ញាតនៅក្នុងបន្ទប់សវនាការមុនពេលពួកគេផ្ដល់សក្ខីកម្មនោះទេ។[175] កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** មានប្រសាសន៍ថា នៅពេលដែលសាក្សី គឺជាមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីនោះត្រូវបានអនុញ្ញាតឱ្យនៅក្នុងបន្ទប់សវនាការ ដោយសារពួកគេជាមន្ត្រីជំនាញ។[176]

---

172 ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២២។

173 ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៤។

174 នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

175 នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

176 នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

មានតែមួយសំណុំរឿងដែលត្រូវបានសង្កេតនៅសាលាឧទ្ធរណ៍**ភ្នំពេញ**ក្នុងឆ្នាំ២០២៣ មានសាក្សីចូលរួមផ្ដល់សក្ខីកម្ម តែសាក្សីនោះគ្មានវត្តមានក្នុងបន្ទប់សវនាការទេ ហើយបើធៀបនឹងឆ្នាំ២០២២ សាក្សីដែលមានវត្តមានក្នុងបន្ទប់សវនាការមានចំនួន ៥០% (៣ ក្នុងចំណោម ៦ សំណុំរឿង)។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យក្នុងអំឡុងពេលធ្វើរបាយការណ៍នេះនៅមានកម្រិត ដូច្នោះមិនអាចធ្វើការសេចក្ដីសន្និដ្ឋានណាមួយលើករណីនេះបានទេ។ សាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា ក្នុងពេលសវនាការសាលាឧទ្ធរណ៍អាចដំណើរការបានដោយគ្មានសាក្សី លើកលែងតែករណីចាំបាច់ប៉ុណ្ណោះ។[177] មួយវិញទៀតនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** ភាគរយនៃសំណុំរឿងដែលសាក្សីត្រូវបានអនុញ្ញាតឱ្យនៅក្នុងបន្ទប់សវនាការមុនពេលផ្ដល់សក្ខីកម្មបានថយចុះពី ៥០% ក្នុងឆ្នាំ២០២២ មកដល់ ៤០% នៅឆ្នាំ២០២៣ (២ នាក់ក្នុងចំណោម ៥ សំណុំរឿង) ។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្ដមប្រធានសាលាឧទ្ធរណ៍នេះមានប្រសាសន៍ថា ជួនកាលក្រឡាបញ្ជីមានការធ្វេសក្នុងការផ្ទៀងផ្ទាត់ ឬពិនិត្យមើលពីវត្តមានរបស់ភាគី និងអ្នកពាក់ព័ន្ធថាតើអ្នកទាំងនោះមានវត្តមានដែរឬទេ ហេតុដូច្នេះហើយមិនដឹងថា តើសាក្សីសំខាន់ស្ថិតនៅក្នុងបន្ទប់សវនាការមុនពេលផ្ដល់សក្ខីកម្ម។[178] ហេតុដូច្នេះ គួរមានវិធានការសមស្របដើម្បីដោះស្រាយបញ្ហានេះ។

ជាចុងក្រោយ កង្វះមេធាវីសម្រាប់ជនជាប់ចោទជាច្រើននាក់ក្នុងសំណុំរឿងដែលបានសង្កេត នាំឱ្យមានចម្ងល់អំពីសមត្ថភាពរបស់ជនជាប់ចោទដែលមិនបានទទួលប្រយោជន៍ពាក់ព័ន្ធនឹងការយល់ដឹង ព្រមទាំងជំនាញផ្នែកច្បាប់ពីមេធាវីរបស់ខ្លួនក្នុងការអនុវត្តសិទ្ធិប្រកបដោយប្រសិទ្ធភាព រួមមានការហៅសាក្សី និងសាកសួរសាក្សីរបស់ភាគីម្ខាងទៀត ហេតុដូច្នេះហើយ វាជាបញ្ហាចោទចំពោះការគោរពតាមគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់។ មូលហេតុមួយទៀតដែលជាការកត់សម្គាល់ គឺលទ្ធភាពរបស់ជនជាប់ចោទដែលមិនមានមេធាវីការពារ គឺមិនអាចទទួលសំណុំរឿងរបស់ខ្លួនមកពិនិត្យ។ ទោះបីជា គ្មានសំណុំរឿងណាមួយដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានបង្ហាញថាមិនមានមេធាវីការពារបានលើកឡើងពីបញ្ហាទាក់ទងនឹងពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំការពារក្ដីក៏ដោយ យោងតាមបទប្បញ្ញត្តិរបស់ក្រមនីតិវិធីព្រហ្មទណ្ឌ[179] ដែលអនុញ្ញាតឱ្យមេធាវីការពារក្ដីពិនិត្យមើលសំណុំរឿង និងថតចម្លងឯកសារសំណុំរឿង តែមិនបានផ្ដល់សិទ្ធិដូចគ្នាដល់ជនជាប់ចោទដែលមិនមានមេធាវីការពារនោះឡើយ។ ប្រការនេះអាចបង្កជាឧបសគ្គដល់ជនជាប់ចោទ ក្នុងការទទួលបានសិទ្ធិពិនិត្យមើលសំណុំរឿង និងភស្តុតាងទាំងឡាយដែលប្រឆាំងនឹងខ្លួន ព្រមទាំងមិនអាចរៀបចំការការពារដោយខ្លួនឯងបានត្រឹមត្រូវ និងគ្រប់គ្រាន់នោះទេ។

## ៥.៤. សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ

| ច្បាប់កម្ពុជា |
| --- |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ** |

[177] លិខិតលេខ៧០៦ របឧ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[178] នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[179] មាត្រា ១៤៥, ២៥៤, ៣០៤, ៣១៩, ៣៩១ និង ៤២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មាត្រា ៣៥៧ និង ៤០៣

សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ[180] មានន័យថា សេចក្ដីសម្រេចព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលណាម្នាក់ត្រូវតែមានការពន្យល់ពីមូលហេតុ និងមូលដ្ឋានឈានដល់ការចេញនូវសេចក្ដីសម្រេច និងមូលហេតុដែលបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធ ឬគ្មានទោស។ ដើម្បីធ្វើដូច្នេះបាន ទាំងអង្គហេតុ (ឧ. កាលបរិច្ឆេទ ទីកន្លែង និងព្រឹត្តិការណ៍ជាក់ស្តែង) ភស្តុតាងដែលចៅក្រមយកជាសំអាងដើម្បីឈានដល់ការចេញសាលដីកា និងការពន្យល់អំពីសំអាងហេតុរបស់ខ្លួន និងច្បាប់ (បទល្មើស និងរបៀបនៃការទទួលខុសត្រូវះ ចារី អ្នកសមគំនិត ។ល។) សេចក្ដីសម្រេច ត្រូវតែមានការពន្យល់បកស្រាយ។ សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ គឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងរួមបញ្ចូលទាំងសិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈ។ សិទ្ធិទទួលបានសេចក្ដីសេចក្ដីសម្រេចមានសំអាងហេតុ មិនត្រឹមតែការពារជនជាប់ចោទប្រឆាំងនឹងសេចក្ដីសម្រេចតាមអំពើចិត្តនោះទេ[181] ប៉ុន្តែថែមទៀតការពារសិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងការប្តឹងឧទ្ធរណ៍ផងដែរ។ ច្បាប់អន្តរជាតិចែងថា ដើម្បីអនុវត្តសិទ្ធិប្រកបដោយប្រសិទ្ធភាព ពិរុទ្ធជនមានសិទ្ធិទទួលបាននូវការពិនិត្យឡើងវិញលើការផ្តន្ទាទោស និងការកាត់ទោសដោយសាលាជម្រះក្តីជាន់ខ្ពស់ ហើយពិរុទ្ធជនមានសិទ្ធិទទួលបាននូវសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុត្រឹមត្រូវ នៅក្នុងពេលវេលាសមរម្យមួយសម្រាប់បណ្ដឹងឧទ្ធរណ៍ទាំងអស់។[182] នៅក្នុងបរិបទកម្ពុជា ទាំងភាគីជនជាប់ចោទ និងភាគីតំណាងអយ្យការមានសិទ្ធិប្ដឹងសាទុក្ខលើសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូលដើម្បីឱ្យត្រួតពិនិត្យឡើងវិញ។

## *តួលេខទី៣២៖ ភាគរយនៃសវនាការដែលបានសង្កេត ហើយចៅក្រមបានផ្ដល់សំអាងហេតុពេលប្រកាសសាលដីកា*[183]

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មាន ៧៩,៩% នៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេត និងបានស្ដាប់សាលដីកា (១៧៩ ក្នុងចំណោម ២២៤ សំណុំរឿង) ចៅក្រមខកខានអានសំអាងហេតុនៅពេលប្រកាសសាលដីកាដោយគ្រាន់តែប្រកាសពីសេចក្តីសម្រេចប៉ុណ្ណោះ។ តួលេខនេះ មិនទាន់មានភាពប្រសើរនៅឡើយ ដោយរាប់ទាំងការអនុវត្តនៅឆ្នាំ២០២២ ផងដែរ ដែលមានចំនួន ៨០,៩%។ នេះបង្ហាញថា តុលាការគោលដៅមិនទាន់បានលើកកម្ពស់សិទ្ធិនេះពេញលេញនៅឡើយ។

---

180 សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក «សិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈ និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ» (ខែកញ្ញា ឆ្នាំ២០២២)

181 អង្គការលើកលែងទោសអន្តរជាតិ «សៀវភៅណែនាំស្ដីពីសិទ្ធីទទួលបានការជំនុំជម្រះដោយយុត្តិធម៌» (ឆ្នាំ២០១៤) ទំព័រ ១៧៣ ផ្នែក ២៤.២។

182 គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៩។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ៣២០/១៩៨៨, *V. Francis ទល់នឹងប្រទេសចាម៉ៃកា* (ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣) *GAOR* A/៤៨/៤០ (លេខ II ) វាក្យខណ្ឌ ១២.២ https://tinyurl.com/275fa3sr

183 ទិន្នន័យនេះគឺផ្អែកលើសំណុំរឿងចំនួន ៧៧២ ដែលបានសង្កេតនៅឆ្នាំ២០២៣។ (មិនដឹង) មានន័យថា អ្នកសង្កេតសវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។




នៅសាលាឧទ្ធរណ៍ភ្នំពេញ បានខកខានអានសំអាងហេតុ មានចំនួន ៧០,៤% (៥៧ ក្នុងចំណោម ៨១ សំណុំរឿង)គឺបានថយចុះបើធៀបនឹងឆ្នាំ២០២២ មានចំនួន៨១,២៥%។ ទោះបីជាមានការថយចុះគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយក៏សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ នៅតែមិនទាន់បានគោរពពេញលេញនៅក្នុងអំឡុងពេលធ្វើរបាយការណ៍ទាំងអស់។ ទោះបីជាមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់នៅក្នុងឆ្នាំ២០១៨/២០១៩ ដែលតួលេខមានត្រឹមតែ ៤៧,៥% នៃសំណុំរឿងទាំងអស់ (បើធៀបនឹងឆ្នាំ២០១៧/២០១៨ មាន ចំនួនដល់ ៨៧,៤% ហើយធៀបនឹងឆ្នាំ២០១៤/២០១៥ មាន ចំនួន ៨៤,៦%) ភាពល្អប្រសើរនេះបានកើតមានត្រឹមតែក្នុង រយៈពេលខ្លី ពីព្រោះនៅក្នុងឆ្នាំ២០១៩/២០២០ មានតួលេខឡើងដល់ចំនួន ៦៦,៥% និងនៅឆ្នាំ២០២១ បានឡើងដល់ ចំនួន ៩០%។

នៅខែតុលា ឆ្នាំ២០២១ សាលាឧទ្ធរណ៍ភ្នំពេញបានលើកឡើងថា ចៅក្រមគ្រាន់តែអានសំអាងហេតុពេលប្រកាសសាលដីកា នៅពេលដែលមានវត្តមានភាគីប៉ុណ្ណោះ និងបានបង្ហាញថា ការធ្វើបែបនេះមិនផ្ទុយនឹងបញ្ញត្តិច្បាប់ណាមួយឡើយ។[184] ទោះជាយ៉ាងណាក៏ដោយ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការបានលើកឡើងថា ចៅក្រមនឹងប្រកាសសាលដីកាដោយមានសង្ខេបពីសំអាងហេតុដើម្បីឱ្យជនជាប់ចោទបានទទួលព័ត៌មានកាន់តែច្បាស់ពីសំណុំរឿងរបស់ពួកគេ។ [185] ម.ស.ម.ក សាទររាល់ការប្តេជ្ញាចិត្តទាំងនេះ ហើយថាតើការអនុវត្តក្នុងការលើកកម្ពស់សិទ្ធិនេះនឹងមកភាពល្អប្រសើរឡើងនៅឆ្នាំ២០២៤ ឬយ៉ាងណា។ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានបញ្ជាក់ថានឹងពិនិត្យកែសម្រួល អំពីនីតិវិធីប្រកាសសាលដីកា ដោយមានការសង្ខេបសំអាងហេតុ នៅពេលប្រកាសសាលដីកា។ លើកលែងតែករណី អវត្តមានគូភាគី ពេលវេលា និងស្ថានភាពនៃរឿងក្តីខ្លះ ដែលមិនមានភាពចាំបាច់ក្នុងការប្រកាសអំពីសំអាងហេតុ (ឧទាហរណ៍ សំណុំរឿងផុតបណ្តឹងឧទ្ធរណ៍ជាដើម)។[186]

[184] លិខិតលេខ ៤៣១/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ដោយសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍ឆ្នាំ ២០១៩/២០២០ របស់ ម.ស.ម.ក។

[185] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[186] លិខិតលេខ៧០៦ រប២/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

អ្វីដែលគួរឱ្យកត់សម្គាល់គឺតួលេខរបស់សាលាឧទ្ធរណ៍**បាត់ដំបង** និង**ព្រះសីហនុ** ដែលចៅក្រមបានខកខានអានសំអាងហេតុ មានចំនួន ៨៧,២% (១០២ លើ ១១៧ សំណុំរឿង) និងមានចំនួន ៨៧% (២០ លើ ២៣ សំណុំរឿង) នៃតុលាការនីមួយៗនៅឆ្នាំ២០២៣។ តួលេខនេះ បង្ហាញពីភាពមិនប្រសើរបើធៀបនឹងឆ្នាំ ២០២២ (ចំនួន ៨២,២% និងចំនួន ៧៨,៦% នៃតុលាការនីមួយៗ )។ ជាចាំបាច់ចៅក្រមត្រូវផ្តល់នូវសំអាងហេតុ ពេលប្រកាសសាលដីកា ព្រមទាំងបង្ហាញពីចំណុចសំខាន់ៗដើម្បីលើកកម្ពស់សិទ្ធិនេះឱ្យបានពេញលេញ។ កាលពីខែមីនា ឆ្នាំ២០២៣ ឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍**បាត់ដំបង** បានថ្លែងថាចៅក្រមនឹងមិនអានសំអាងហេតុនោះទេ ប្រសិនជនជាប់ចោទអវត្តមានក្នុងសវនាការ។ ទោះជាយ៉ាងនេះក្តី ឯកឧត្តមបានលើកឡើងថា សេចក្តីចម្លងពេញលេញនៃសាលដីកាគឺត្រូវបានផ្ញើទៅឱ្យគូភាគីទាំងអស់។[187] នៅខែកក្កដា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍បាត់ដំបងបានលើកឡើងថា ប្រសិនបើចៅក្រមអានសំអាងហេតុទាំងអស់ និងសេចក្តីសម្រេចនោះអាចចំណាយពេលវេលាយូរ ហើយករណីខ្លះជនជាប់ចោទអវត្តមានពេលប្រកាសសាលដីកា ដូច្នោះចៅក្រមមិនសូវបានអានលម្អិតនោះទេ ពីព្រោះមានសំណុំរឿងច្រើនទៀតត្រូវធ្វើការជំនុំជម្រះ តែយ៉ាងណាតុលាការនឹងប្រគល់សាលដីកាដល់ជនជាប់ចោទនៅពេលក្រោយ ព្រមទាំងបានបន្ថែមថាការដែលចៅក្រមអានតែសេចក្តីសម្រេចនោះ មិនមែនជារឿងខុសច្បាប់ទេ គឺបានអនុលោមតាមច្បាប់ជាតិហើយ។[188]

ម.ស.ម.ក កត់សម្គាល់ថា ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មានចំនួន ៩០,២% នៃជនជាប់ចោទថាមានពិរុទ្ធក្នុងសំណុំរឿងដែលបានស្តាប់សាលដីកា (២៧៦ ក្នុងចំណោម ៣០៦ សំណុំរឿង)។ នៅសាលាឧទ្ធរណ៍**ភ្នំពេញ** តួលេខនេះមាន ៩៣,៦% (១០២ ក្នុងចំណោម ១០៩ សំណុំរឿង) មានភាពនិន្នាការប្រហែលគ្នា បើធៀបនឹងឆ្នាំ ២០២២ មានចំនួន ៩៣%។ ចាប់តាំងពីរបាយការណ៍ឆ្នាំ២០១៦/២០១៧ មក និន្នាការនៃការផ្តន្ទាទោសលើជនជាប់ចោទមានអត្រាខ្ពស់ស្រដៀងគ្នា។ ដូចគ្នានេះដែរ នៅសាលាឧទ្ធរណ៍**បាត់ដំបង** ភាគរយនេះបានកើនឡើងពី ៨៣,៣% ដល់ ៩១,៧% (១៤៣ ក្នុងចំណោម ១៥៦ សំណុំរឿង) និង នៅសាលាឧទ្ធរណ៍**ព្រះសីហនុ** មានចំនួនពី ៨៥% ទៅ ៨៦,១% (៣១ ក្នុងចំណោម ៣៦ សំណុំរឿង)។ តួលេខខ្ពស់នៃការខកខានអានសំអាងហេតុនេះ នាំឱ្យមានការលើកឡើងថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានគោរពដែរឬទេ ដូចនេះ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ នៅមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយនៅតុលាការគោលដៅទាំង៣ ក្នុងរយៈពេល ២ ឆ្នាំជាប់ៗគ្នា។ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រះសីហនុ បានសួរបញ្ជាក់ថា តើឱ្យចៅក្រមប្រាប់ទៅអ្នកណាបើជនជាប់ចោទអវត្តមានក្នុងសវនាការ តែបើមេធាវីការពារសិទ្ធិរបស់

[187] នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[188] នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

ជនជាប់ចោទមានវត្តមាន ចៅក្រមតែងតែអានប្រាប់សំអាងហេតុជានិច្ច ម្យ៉ាងវិញទៀត បាន បន្ថែមថា របាយការណ៍នេះ ហាក់ឆ្លុះបញ្ចាំងភាគច្រើនលើនីតិវិធីនៅសាលាដំបូង។[189]

គួរកត់សម្គាល់ថា ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ម.ស.ម.ក បានស្តាប់សាលដីកាតែ ០៣ សំណុំរឿង ប៉ុណ្ណោះនៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**។ ចៅក្រមបានអានប្រាប់ពីសំអាងហេតុ ពេលប្រកាសសាលដីកាទាំងនេះ ដោយសារទិន្នន័យមានចំនួនតិចតួច ដូច្នេះ មិនអាចវាយតម្លៃ និងសន្និដ្ឋាន ថាតើតុលាការបានគោរពសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុបានពេញលេញឬយ៉ាងណានោះទេនៅឆ្នាំ២០២៣នេះ។ ករណីមានស្រដៀងគ្នានៅឆ្នាំ២០២២ គឺមានសាលដីកាចំនួន ០១ ដែលបានស្តាប់។ នៅខែកញ្ញា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍នេះមានប្រសាសន៍ថា សាលដីកាមួយចំនួនមិនត្រូវបានប្រកាសនៅថ្ងៃបើកសវនាការទេ ដោយសារអវត្តមានរបស់ភាគី។[190] គ្មានជនជាប់ចោទណាម្នាក់ ក្នុងចំណោមជនជាប់ចោទ ៣ នាក់ ត្រូវបានតុលាការរកឃើញថា មានពិរុទ្ធភាពនោះទេ។

## ៥.៥. ការប្រតិបត្តិរបស់ចៅក្រម

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | |
|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា | ក្រមសីលធម៌ចៅក្រម |
| មាត្រា ១៤(១) និង ១៤(៥) | មាត្រា ១២៨ និង ១៣២ | មាត្រា ៨ ៥០ និង ៧៧ | មាត្រា ២ និង ៨ |

មាត្រា ១៤(១) នៃ ក.អ.ស.ព.ន ធានាសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច និងមិនលម្អៀង គឺជាសរសៃស្នូលនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[191] ប្រសិនបើគ្មានការគោរពសិទ្ធិនេះទេ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្សេងទៀតទាំងអស់លែងមានប្រយោជន៍ហើយ។ ជាការពិត សាលាជម្រះក្តីដែលមិនមានសមត្ថកិច្ច និងលម្អៀង មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងការគ្រប់គ្រងយុត្តិធម៌ឱ្យបានត្រឹមត្រូវនោះទេ។ ដូច្នេះ ចៅក្រមត្រូវតែប្រកាន់វិជ្ជាជីវៈគ្រប់ពេលដើម្បីបង្ហាញថាមានសមត្ថកិច្ច និងមិនលម្អៀង។ នៅកម្ពុជា ការប្រតិបត្តិរបស់ចៅក្រមគឺមាន ចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងក្រមសីលធម៌ចៅក្រមដែលតម្រូវឱ្យចៅក្រមមិនរងសម្ពាធពីគ្រប់ទម្រង់នៃឥទ្ធិពលណាមួយពីសំណាក់គូភាគី ឬបុគ្គល ក្រុម ឬស្ថាប័នណាមួយ និងធ្វើសេចក្តីសម្រេចលើសំណុំរឿងដោយមនសិការ ការគោរព ការអត់ធ្មត់ សុជីវធម៌ និងសីលធម៌បំផុត ដើម្បីធានានូវយុត្តិធម៌។ ហេតុដូច្នេះហើយ តុលាការត្រូវចំណាយពេល

[189] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ពីការសង្កេតសវនាការរបស់ខ្លួន។

[190] នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[191] សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលការជំនុំជម្រះដោយតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-be-tried-by-a-competent-independent-and-impartial-tribunal

វេលាគ្រប់គ្រាន់ ដើម្បីសិក្សាសំណុំរឿងឱ្យបានហ្មត់ចត់ ក្នុងគោលបំណងធានាថាសំណុំរឿងត្រូវបានវិនិច្ឆ័យយ៉ាងត្រឹមត្រូវ និងច្បាស់លាស់ ហើយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពយ៉ាងពេញលេញ។

នៅអំឡុងពេលធ្វើរបាយការណ៍នេះ និងសម្រាប់រយៈពេលពីឆ្នាំជាប់ៗគ្នា គ្មានចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់បានរើសអើងចំពោះភាគីណាមួយឡើយ រួមទាំងជនជាប់ចោទផងដែរ។ ទោះយ៉ាងណាក៏ដោយ កត់សម្គាល់ឃើញថាមាន ៨ ករណី ដែលចៅក្រមបានប្រើពាក្យមិនសមរម្យក្នុងអំឡុងពេលសវនាការ មាន ៧ ករណី នៅសាលាឧទ្ធរណ៍**ភ្នំពេញ** និងមានចំនួន ១ ករណីនៅសាលាឧទ្ធរណ៍**បាត់ដំបង** និងមានចំនួន ២ ករណីដែលព្រះរាជអាជ្ញាបានប្រព្រឹត្តិដូចគ្នានេះគឺមានចំនួន ១ ករណី នៅសាលាឧទ្ធរណ៍**ភ្នំពេញ** និងមួយករណីទៀតនៅសាលាឧទ្ធណ៍**បាត់ដំបង។** ទោះបីជាតួលេខទាំងនេះ មានចំនួនតិចតួចត្រឹមតែ ១% និង០,៣% នៃចំនួនសំណុំរឿងសរុបដែលត្រូវបានសង្កេតក្នុងឆ្នាំ ២០២៣ នៃតុលាការទាំងពីរនេះក៏ដោយ គួរតែមានការយកចិត្តទុកដាក់ជាពិសេសដើម្បីជៀសវាងការប្រតិបត្តិយ៉ាងដូច្នេះដែរ។ នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍**ភ្នំពេញ** និងមហាអយ្យការអមសាលាឧទ្ធរណ៍នេះ បានទទួលស្គាល់ថា ការប្រើពាក្យសម្តីមិនសមរម្យក្នុងពេលសវនាការ អាចជះឥទ្ធិពលដែលធ្វើឱ្យខូចប្រយោជន៍ដល់ការស្វែងរកយុត្តិធម៌ ហើយថានឹងពិភាក្សាពីបញ្ហានេះតាមរយៈកិច្ចប្រជុំផ្ទៃក្នុង។[192] សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញថានឹងពិនិត្យកែសម្រួល និងណែនាំដល់ចៅក្រម និងព្រះរាជអាជ្ញាដែលបានប្រើពាក្យមិនសមរម្យក្នុងអំឡុងពេលសវនាការ។[193]

គួរឱ្យសាទរ ចំពោះទិន្នន័យដែលបង្ហាញថា ចៅក្រមគ្រាន់តែទទួលទូរស័ព្ទរបស់ខ្លួនក្នុងអំឡុងពេលសវនាការចំនួន ៤ ករណីស្មើនឹង ០,៥% នៃចំនួនសរុបសវនាការ គឺមានការថយបើធៀបនឹងឆ្នាំ២០២២ មានចំនួន ១%។ មានចំនួន ២ ករណី នៅសាលាឧទ្ធរណ៍**ភ្នំពេញ** និង២ ករណីទៀតមាននៅសាលាឧទ្ធរណ៍**បាត់ដំបង** និង**ព្រះសីហនុ**។ ក្នុងករណីទាំងបួននេះ ចៅក្រមបាននិយាយតាមទូរស័ព្ទយ៉ាងខ្លី ហើយក៏បញ្ចប់ការសន្ទនាទៅវិញ។ នៅខែសីហា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍**បាត់ដំបង**បានឆ្លើយតបថាតុលាការកំពុងមានវិធានការដើម្បីទប់ស្កាត់ការប្រើប្រាស់ទូរស័ព្ទក្នុងសវនាការ។[194] នៅខែវិច្ឆិកា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍ និងតំណាងមហាអយ្យការបានអះអាងជាថ្មីម្តងទៀតថា ការសន្ទនាតាមទូរស័ព្ទអំឡុងពេលសវនាការមិនអាចទទួលយកបានទេ ហើយតុលាការនឹងលើកអំពីបញ្ហានេះជាមួយចៅក្រម និងព្រះរាជអាជ្ញាផងដែរ។[195]

ទោះបីជាមានលទ្ធផលវិជ្ជមានដូចបានបង្ហាញខាងលើក៏ដោយ សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច និងមិនលម្អៀង គួរត្រូវយកចិត្តទុកដាក់បន្ថែមទៀត ដោយសារសវនាការដែលបានសង្កេត

---

[192] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[193] លិខិតលេខ៧០៦ របឧ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[194] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[195] នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

ភាគច្រើនបានចំណាយពេលសវនាការរយៈពេលខ្លី ដែលចៅក្រមគួរពិនិត្យសំណុំរឿងឱ្យបានហ្មត់ចត់ពេលជំនុំជម្រះ ពិសេសពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរ។ យោងតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការសិទ្ធិមនុស្ស សិទ្ធិទទួលបានការពិនិត្យលើការផ្តន្ទាទោសរបស់បុគ្គលណាម្នាក់ឡើងវិញដោយសាលាជម្រះក្តីជាន់ខ្ពស់ កំណត់ឱ្យរដ្ឋភាគីមានកាតព្វកិច្ចពិនិត្យមើលការផ្តន្ទាទោស និងការកាត់ទោស*យ៉ាងយកចិត្តទុកដាក់* ដោយផ្អែកលើមូលដ្ឋាន ភស្តុតាងគ្រប់គ្រាន់ទាំងអង្គហេតុ និងច្បាប់ នីតិវិធីនេះអនុញ្ញាតឱ្យមាន*ការពិចារណាយ៉ាងហ្មត់ចត់ត្រឹមត្រូវ* អំពីលក្ខណៈនៃសំណុំរឿង។ មុននឹងសម្រេចថាតើមានភស្តុតាងចោទប្រកាន់គ្រប់គ្រាន់ដើម្បីកំណត់ថាមានពិរុទ្ធភាពឬយ៉ាងណា តុលាការជាន់ខ្ពស់ត្រូវពិនិត្យមើលការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ*ឱ្យបានលម្អិត* ហើយពិចារណាលើភស្តុតាងដែលមានក្នុងសំណុំរឿងពេលជំនុំជម្រះ និងភស្តុតាងដែលបានយកមកបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍។[196]

អំឡុងពេលធ្វើរបាយការណ៍នេះ មានចំនួន ៧០,៦% នៃសវនាការដែលបានសង្កេត ចៅក្រមបានចំណាយពេលត្រឹមតែ ៣០ នាទី ឬតិចជាងនេះ (៥៤៥ ក្នុងចំណោម ៧៧២ សំណុំរឿង) តួលេខនេះបានកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានចំនួន ៦៨,៥%។ សវនាការភាគច្រើនដែលប្រើរយៈពេលខ្លី ត្រូវបានកត់សម្គាល់ឃើញថា ដោយសារជនជាប់ចោទអវត្តមាន ឬ/និងគ្មានមេធាវីការពារ លើសពីនេះទៅទៀត គ្មានសាក្សីមកផ្តល់សក្ខីកម្ម។ ទោះបីជាមិនមានបទដ្ឋានកំណត់ទាក់ទងនឹងរយៈពេលជនុំជម្រះក៏ដោយ សវនាការដែលមានរយៈពេលតិចជាង ៣០ នាទី ជាពិសេស នៅពេលដែលទាក់ទងនឹងបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ស្ទើរតែមិនអាចផ្តល់បរិយាកាសអំណោយផល សម្រាប់ភាគីក្នុងការមានលទ្ធភាពការពាររបស់ខ្លួន ឱ្យបានពេញលេញ និងសម្រាប់ចៅក្រមមានលទ្ធភាពអាចពិនិត្យលើសំណុំរឿងឱ្យបានហ្មត់ចត់។ ចំណុចនេះ គឺមានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយ។

នៅសាលាឧទ្ធរណ៍**ភ្នំពេញ** សវនាការដែលបានចំណាយពេល ៣០ នាទី ឬតិចជាងនេះ មានចំនួន ៨១,៥% នៃសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៣ (២៧៤ ក្នុងចំណោម ៣៣៦ សំណុំរឿង)។ តួលេខនេះបង្ហាញថាស្ទើរតែគ្មានការប្រែប្រួលបើធៀបនឹងឆ្នាំ២០២២ ដែលតួលេខមានចំនួន ៨១,៣%។ សវនាការពាក់ព័ន្ធនឹងបទឧក្រិដ្ឋចំនួន ៣៣,២% ដែលចំណាយពេល ១៥ នាទី ឬតិចជាងនេះ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការបានលើកឡើងថា សវនាការមានរយៈពេលខ្លី អាចក្នុងករណីមានជនជាប់ចោទតែម្នាក់ ឬនៅពេលដែលជនជាប់ចោទអវត្តមាន ឬបានសារភាពចំពោះ បទល្មើសនោះរួចហើយ និងមានភស្តុតាងស៊ីសង្វាក់គ្រប់គ្រាន់

ដើម្បីឈានទៅដល់ការចេញសេចក្តីសម្រេច។[197] សាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា ករណីសវនាការមានរយៈពេល ១៥ នាទី ឬតិចជាងនេះ ដោយផ្អែកលើស្ថានភាពនៃសំណុំរឿង ដូចជា ករណីបណ្តឹងដែលធ្វើឡើងខុសលក្ខខណ្ឌច្បាប់ ករណីដកបណ្តឹងឧទ្ធរណ៍ ករណីគ្មានគូភាគីចូលរួម ឬរឿងមជ្ឈិមជាដើម។[198] ដូចគ្នានេះដែរ នៅសាលាឧទ្ធរណ៍**បាត់ដំបង** សវនាការដែលបានសង្កេតចំនួន ៧៨% ដែលចៅក្រមបានចំណាយពេល៣០ នាទី ឬតិចជាងនេះ មានការ

[196] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

[197] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ ម.ស.ម.ក។

[198] លិខិតលេខ៧០៦ របឧ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

កើនឡើងបើធៀបនឹងឆ្នាំ២០២២ មានចំនួន ៧២%។ អំឡុងពេលធ្វើរបាយការណ៍នេះ សវនាការដែលចៅក្រមបានចំណាយពេលចំនួន ១៥ នាទី ឬតិចជាងនេះ មានចំនួន ជាងមួយភាគប្រាំ ដែលជាសវនាការពាក់ព័ន្ធនឹងបទឧក្រិដ្ឋ (២៥ ក្នុង ចំណោម ១១៨ សំណុំរឿង)។ នៅខែសីហា ឆ្នាំ២០២៣ តំណាងតុលាការនេះបានលើកឡើងថា សវនាការខ្លះមានរយៈពេលខ្លី ដោយសារជនជាប់ចោទបានសារភាពអំពីបទល្មើសរបស់ខ្លួនរួចហើយ ឬជនជាប់ចោទអវត្តមាន។[199]

ទោះបីជាតុលាការគោលដៅពីរផ្សេងទៀតបានអនុវត្តប្រសើរឡើងច្រើន ក៏គួរតែបន្ថែមការយកចិត្តទុកលើចំណុចមួយចំនួនដែរ។ ទីមួយ នៅសាលាឧទ្ធរណ៍**ព្រះសីហនុ** ភាគរយនៃសវនាការដែលបានសង្កេត ហើយចៅក្រមបានចំណាយពេល ៣០ នាទី ឬតិចជាងនេះ បានកើនឡើងពីចំនួន ៤៤,១% នៅឆ្នាំ២០២២ ដល់ ៥៤,៧% នៅឆ្នាំ២០២៣ (៤១ ក្នុងចំណោម ៧៥ សំណុំរឿង) សវនាការដែលចៅក្រមចំណាយពេល ១៥ នាទី ឬតិចជាងនេះ មានចំនួន ៣១,៦% ពាក់ព័ន្ធនឹងបទឧក្រិដ្ឋ (៦ ក្នុងចំណោម ១៩ សំណុំរឿង)។ នៅខែសីហា ឆ្នាំ២០២៤ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានបញ្ជាក់ថា សំណុំរឿងមួយចំនួនដែលចំណាយពេលសវនាការខ្លីនោះ អាចបណ្តាលមកពីជនជាប់ចោទបានសារភាពអស់ហើយ ករណីខ្លះទៀតជនជាប់ចោទប្តឹងមកសាលាឧទ្ធរណ៍សុំឱ្យបន្ធូរបន្ថយទោសតែប៉ុណ្ណោះ ដូចនេះគ្មានអ្វីដែលត្រូវចំណាយពេលសួរដេញដោលច្រើននោះទេ។[200] ទីពីរ នៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**សវនាការដែលចៅក្រមបានចំណាយពេលចំនួន ៣០ នាទី ឬតិចជាងនេះ មានចំនួន៣៥% នៅឆ្នាំ២០២៣ (៤២ ក្នុងចំណោម ១២០ សំណុំរឿង) តួលេខនេះបង្ហាញពីការកើនឡើងបន្តិចបើធៀបនឹង ឆ្នាំ២០២២ មានចំនួន ៣៣,៩%។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា មានតែ ១ សវនាការប៉ុណ្ណោះពាក់ព័ន្ធបទឧក្រិដ្ឋដែលចៅក្រមបានចំណាយពេល ១៥ នាទី ឬតិចជាងនេះ ស្មើនឹង ១៦,៧% នៃចំនួនសវនាការសរុប។ នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានលើកឡើងថា សវនាការខ្លះមានរយៈពេលខ្លី ដោយសារភាគីមួយចំនួនមិនមានវត្តមាននៅក្នុងបន្ទប់សវនាការ ហើយសវនាការអាចមានរយៈយូរជាងនេះ នៅពេលដែលគូភាគីមានវត្តមាន ហើយសាក្សីត្រូវបានហៅមកផ្តល់សក្ខីកម្ម។[201]

## *តួលេខទី៣៣៖ រយៈពេលនៃសវនាការដែលបានសង្កេត នៅតាមតុលាការគោលដៅ*[202]

### ទិន្នន័យជារួម

| រយៈពេលសវនាការ | ១៥ នាទី ឬ តិចជាងនេះ | ១៦-៣០ នាទី | ៣១នាទី-១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|

[199] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[200] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងាររបស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហុន ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[201] នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[202] ទិន្នន័យនេះផ្អែកលើរយៈពេលនៃសវនាការដែលបានកត់ត្រាសម្រាប់សំណុំរឿងចំនួន ៧៧២ ដែលបានសង្កេតក្នុងឆ្នាំ២០២៣។

| | | | | | |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ៩៣ | ៩២ | ៧០ | ៣៨ | ២៩៣ |
| បទមជ្ឈិម | ២២៩ | ១២១ | ៨៥ | ៣២ | ៤៦៧ |
| បទលហុ | ៥ | ៥ | ១ | ១ | ១២ |
| សរុប | ៣២៧ | ២១៨ | ១៥៦ | ៧១ | ៧៧២ |
| សរុបជា % | ៤៣% | ២៨% | ២០% | ៩% | ១០០% |

សាលាឧទ្ធរណ៍ភ្នំពេញ

| រយៈពេលសវនាការ | ១៥ នាទី ឬ តិចជាងនេះ | ១៦-៣០ នាទី | ៣១នាទី-១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ៦១ | ៥១ | ២១ | ១២ | ១៤៥ |
| បទមជ្ឈិម | ១២០ | ៣៧ | ២២ | ៧ | ១៨៦ |
| បទលហុ | ៣ | ២ | ០ | ០ | ៥ |
| សរុប | ១៨៤ | ៩០ | ៤៣ | ១៩ | ៣៣៦ |
| សរុបជា % | ៥៤% | ២៧% | ១៣% | ៦% | ១០០% |

សាលាឧទ្ធរណ៍បាត់ដំបង

| រយៈពេលសវនាការ | ១៥ នាទី ឬ តិចជាងនេះ | ១៦-៣០ នាទី | ៣១នាទី-១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ២៥ | ២៨ | ២២ | ៥ | ៨០ |
| បទមជ្ឈិម | ៩១ | ៤១ | ២០ | ៥ | ១៥៧ |
| បទលហុ | ២ | ១ | ១ | ០ | ៤ |
| សរុប | ១១៨ | ៧០ | ៤៣ | ១០ | ២៤១ |
| សរុបជា % | ៤៩% | ២៩% | ១៨% | ៤% | ១០០% |

សាលាឧទ្ធរណ៍ព្រះសីហនុ

| រយៈពេលសវនាការ | ១៥ នាទី ឬ តិចជាងនេះ | ១៦-៣០ នាទី | ៣១នាទី-១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ៦ | ៥ | ៨ | ១៣ | ៣២ |
| បទមជ្ឈិម | ១៣ | ១៦ | ៧ | ៦ | ៤២ |
| បទលហុ | ០ | ១ | ០ | ០ | ១ |
| សរុប | ១៩ | ២២ | ១៥ | ១៩ | ៧៥ |
| សរុបជា % | ២៥% | ៣០% | ២០% | ២៥% | ១០០% |

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

| រយៈពេលសវនាការ | ១៥ នាទី ឬ តិចជាងនេះ | ១៦-៣០ នាទី | ៣១នាទី-១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ១ | ៨ | ១៩ | ៨ | ៣៦ |
| បទមជ្ឈិម | ៥ | ២៧ | ៣៦ | ១៤ | ៨២ |
| បទលហុ | ០ | ១ | ០ | ១ | ២ |
| សរុប | ៦ | ៣៦ | ៥៥ | ២៣ | ១២០ |
| សរុបជា % | ៥% | ៣០% | ៤៦% | ១៩% | ១០០% |

## ៩.៦. សិទ្ធិកុមារទំនាស់នឹងច្បាប់

| ច្បាប់អន្តរជាតិ | | ច្បាប់កម្ពុជា | | | |
|---|---|---|---|---|---|
| ក.អ.ស.ព.ន | អ.ស.ក | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤ (១) | មាត្រា ៣៧ និង ៤០ | មាត្រា ៣១ និង ៤៨ | មាត្រា ១០០ និង ២១២ | មាត្រា ៣៩ និង ៤០ | មាត្រា ៥, ៦, ៣៩, ៤៧, ៤៨, ៤៩, ៥៤, ៥៧ និង ៨២ |

ច្បាប់អន្តរជាតិធានាចំពោះសិទ្ធិរបស់កុមារ - ជនដែលមានអាយុក្រោម ១៨ ឆ្នាំ[203] ដែលបានរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌនូវរាល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវអនុវត្តដូចគ្នានឹងមនុស្សពេញវ័យដែរ ប៉ុន្តែកុមារត្រូវទទួលបាននូវកិច្ចការពារពិសេសផងដែរ ដោយផ្អែកលើអាយុ ភាពដឹងក្តី និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី។[204]

ក.អ.ស.ព.ន និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក.") ដែលបានចូលជាធរមាននៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ ចែងពីបទប្បញ្ញត្តិជាក់លាក់សម្រាប់ការប្រព្រឹត្តលើកុមារក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ [205] ដែលគាំពារដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍ណែនាំអន្តរជាតិជាច្រើន។[206] ច្បាប់សិទ្ធិមនុស្សអន្តរជាតិទាំងនោះ បង្ហាញពីភាពចាំបាច់សម្រាប់រដ្ឋភាគីក្នុងការង្កើតច្បាប់ នីតិវិធីផ្សេងៗ អាជ្ញាធរ និងស្ថាប័ន ដែលអនុវត្តជាពិសេសចំពោះកុមារទំនាស់នឹងច្បាប់ ទទួលស្គាល់ថាបានបំពានលើច្បាប់ព្រហ្មទណ្ឌ។ ជាពិសេស រដ្ឋត្រូវកំណត់អាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលកុមារ ត្រូវសន្មតថាមិនមានសមត្ថភាពក្នុងការយល់ដឹងពីច្បាប់ព្រហ្មទណ្ឌ។[207]

---

[203] អ.ស.ក. មាត្រា ១

[204] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក «សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់» (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-rights-of-children-conflict-with-the-law

[205] អ.ស.ក មាត្រា ៤០(២) គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៣៨-៧១ ក.អ.ស.ព.ន មាត្រា ១៤ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤២។

[206] ឧទាហរណ៍ វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង) ឬវិធានច្បាប់របស់អង្គការសហប្រជាជាតិស្តីពីការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ក្នុងចំណោមវិធានច្បាប់ផ្សេងៗ។

[207] អ.ស.ក មាត្រា ៤០(៣)។

កុមារដែលមានអាយុអប្បបរមា ឬលើសពីអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែក្រោមអាយុ ១៨ ឆ្នាំអាចត្រូវបានចោទប្រកាន់ជាផ្លូវការ និងទទួលបាននីតិវិធីយុត្តិធម៌កុមារស្របតាម អ.ស.ក។[208] ទោះបីជាយ៉ាងនេះក្ដី រដ្ឋភាគីត្រូវបានតម្រូវឱ្យលើកកម្ពស់វិធានការដោះស្រាយជាមួយកុមារដែលមានទំនាស់នឹងច្បាប់ដោយមិនឈានទៅរកដំណើរការនីតិវិធីតុលាការ«នៅពេលដែលសមស្រប»។[209] លើសពីនេះ ការសម្រេចមួយចំនួនគួរត្រូវបានធ្វើដូចជា ការថែទាំ ការណែនាំ និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ការផ្ដល់ប្រឹក្សា ការព្យួរទោសសាកល្បង ការថែទាំជំនួស វិធានការអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជម្រើសផ្សេងទៀតតាមរយៈការថែទាំដោយស្ថាប័នដែលមាននីតិសម្បទា ដើម្បីធានាថាកុមារត្រូវបានដោះស្រាយដោយសមស្របទៅនឹងសុខុមាលភាពរបស់ពួកគេ ហើយថែមទាំងស្របទៅតាមកាលៈទេសៈ និងបទល្មើសរបស់ពួកគេ។[210] ច្បាប់កម្ពុជាបានបញ្ញត្តិបន្ថែមពីការប្រព្រឹត្តលើកុមារទំនាស់នឹងច្បាប់ខុសៗគ្នានៅក្នុងផ្នែកសំខាន់ៗជាច្រើន។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័តក្នុងឆ្នាំ២០១៦ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារទំនាស់នឹងច្បាប់។

*ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ*

ជាអន្តរជាតិ អាយុអប្បបរមាទូទៅគឺអាយុ ១៤ ឆ្នាំ។[211] ច្បាប់កម្ពុជាបានកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅអាយុដូចគ្នា[212] មានន័យថា គ្មានកុមារក្រោមអាយុដែលបានកំណត់នេះ នៅពេលមានបទល្មើសកើតឡើងត្រូវបានតុលាការជំនុំជម្រះនោះទេ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វែងរកភស្តុតាងដើម្បីកំណត់អាយុរបស់កុមារដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើសឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន រួមទាំង ស្វែងរកសំបុត្រកំណើត ឬឯកសារបញ្ជាក់កំណើត ឬប្រើប្រាស់មធ្យោបាយដែលអាចទុកចិត្តបានផ្សេងទៀត ដែលតុលាការអាចទទួលយកបានដើម្បីកំណត់អាយុរបស់ពួកគេ ក្នុងករណីដែលគ្មានឯកសារបញ្ជាក់កំណើត។ ការសង្ស័យណាមួយទាក់ទងនឹងអាយុរបស់កុមារត្រូវតែត្រូវបានដោះស្រាយឱ្យបានត្រឹមត្រូវដោយគិតពីប្រយោជន៍របស់កុមារ។[213]

ដូចគ្នានេះដែរ តុលាការត្រូវតែផ្ទៀងផ្ទាត់អាយុរបស់កុមារទំនាស់នឹងច្បាប់ពាក់ព័ន្ធនឹងសំណុំរឿងដែលខ្លួនទទួលបន្ទុកក្នុងការជំនុំជម្រះ។ ប្រសិនបើអាចកំណត់បានថា កុមាររងការចោទប្រកាន់មានអាយុក្រោម ១៤ ឆ្នាំនៅពេលបទល្មើសកើតឡើង ឬប្រសិនបើមានការសង្ស័យអំពីអាយុរបស់ពួកគេនៅពេលបទល្មើសកើតឡើង នោះចៅក្រមត្រូវឱ្យពួកគេរួចផុតពីបទចោទភ្លាមៗ។

208 គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

209 អ.ស.ក មាត្រា ៤០ (៣) គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៣។

210 អ.ស.ក មាត្រា ៤០ (៤)។

211 គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

212 ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៨ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

213 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

***តួលេខទី៣៤ ៖ អាយុរបស់កុមារដែលការវែងការចោទប្រកាន់នៅពេលមានបទល្មើសកើតឡើង***[214]




ក្នុងឆ្នាំ២០២៣ ក្នុងចំណោមជនជាប់ចោទ ១,១១៨ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលត្រូវបានសង្កេត មានជនជាប់ចោទចំនួន ២៦ នាក់ គឺជាកុមារនៅពេលមានបទល្មើសកើតឡើង ហើយពួកគេទាំងអស់ជាក្មេងប្រុស។ សម្រាប់រយៈពេលពីរឆ្នាំជាប់ៗគ្នា គ្មានកុមារណាម្នាក់មានអាយុក្រោមច្បាប់កំណត់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ មានកុមារចំនួន ៥នាក់ មានអាយុពី ១៤ ដល់ ១៥ ឆ្នាំ (១៩,២%) និង២១ នាក់មានអាយុពី ១៦ ដល់ ១៧ ឆ្នាំ (៨០,៨%)។ មានកុមារដែលទំនាស់នឹងច្បាប់ចំនួន ៧នាក់ បានបង្ហាញខ្លួននៅចំពោះមុខសាលាឧទ្ធរណ៍**ភ្នំពេញ** រួមទាំងកុមារចំនួន ១ នាក់ ផងដែរដែលមានអាយុ ១៤-១៥ ឆ្នាំ។ កុមារដែលទំនាស់នឹងច្បាប់ចំនួន ១៧ នាក់ត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍**បាត់ដំបង** រួមមាន ៣ នាក់ដែលមានអាយុពី ១៤ ដល់ ១៥ ឆ្នាំ។ ហើយកុមារចំនួន ២ នាក់ផ្សេងទៀត ដែលមានចំនួន ១ នាក់មានអាយុ ១៤ -១៥ ឆ្នាំ ត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍**ព្រះសីហនុ**។

***សិទ្ធិមានសេរីភាព និងការសន្មតទុកជាមុនថាគ្មានទោស***

វិធានការឃុំខ្លួនបណ្ដោះអាសន្ន មិនគួរត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់នោះទេ លើកលែងតែសំណុំរឿងធ្ងន់ធ្ងរបំផុត ហើយការដាក់ឱ្យកុមារចូលទៅក្នុងសហគមន៍ គួរត្រូវបានពិចារណាដោយយកចិត្តទុកដាក់។ [215] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជនចែងយ៉ាងច្បាស់ថា ការឃុំខ្លួនបណ្ដោះអាសន្នលើកុមារទំនាស់នឹងច្បាប់ គឺជាវិធានការ*ចុងក្រោយបំផុត*[216] និងចែងថាសាលាឧទ្ធរណ៍ត្រូវពិចារណាដោះលែងកុមារដែលជាប់ឃុំបណ្ដោះអាសន្នឱ្យមានសេរីភាពដើម្បីការពារឧត្តមប្រយោជន៍របស់ពួកគេ។ [217] ទោះបីជាមានបទប្បញ្ញត្តិទាំងនេះក៏ដោយ ការសង្កេតសវនាការរបស់ ម.ស.ម.ក បង្ហាញពីការប្រើប្រាស់វិធានការឃុំខ្លួនបណ្ដោះអាសន្នស្ទើរតែជាទម្លាប់ក្នុងករណីដែលពាក់ព័ន្ធនឹងកុមារដែលមានទំនាស់នឹងច្បាប់។ នៅឆ្នាំ២០២៣ កុមារទំនាស់នឹងច្បាប់ ចំនួន ៨០,៨% ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេត (២១ នាក់ក្នុងចំណោម ២៦ នាក់) ត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្នដែលបង្ហាញថានិន្នាការនេះមានភាពស្រដៀងគ្នានឹងឆ្នាំ២០២២ ដែលតួលេខនេះមានចំនួន ៨៨,៥% (២៣ នាក់ក្នុងចំណោម ២៦ នាក់)។ លើសពីនេះ នៅឆ្នាំ២០២៣ មានកុមារទំនាស់នឹងច្បាប់ចំនួន ៩១,៧% ដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ហើយបានដឹងពីកាលបរិច្ឆេទនៃការចាប់ខ្លួនរបស់គេ (១១ នាក់ក្នុងចំណោម ១២ នាក់)ត្រូវបានឃុំខ្លួនពី ១ ឆ្នាំ ទៅដល់ ២ ឆ្នាំនៅក្នុងពន្ធនាគារ គិតមកទល់នឹងថ្ងៃសវនាការនៃបណ្ដឹងឧទ្ធរណ៍របស់ពួក ។

[214] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុប ២៦ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៧៧២ ដែលបានសង្កេតក្នុងឆ្នាំ២០២៣។

[215] គណៈកម្មាធិការនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ សេចក្ដីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៨៦។

[216] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន មាត្រា ៣៩។

[217] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន មាត្រា ៥៧។

*តួលេខទី៣៥ ៖ ចំនួនភាគរយនៃកុមារទំនាស់នឹងច្បាប់ ដែលត្រូវបានឃុំខ្លួនក្នុងឆ្នាំ២០២៣*[218]







គួរកត់សម្គាល់ថា ការលើកកម្ពស់សិទ្ធិមានសេរីភាពរបស់កុមារទំនាស់នឹងច្បាប់មិនអនុវត្តពេញលេញចាប់តាំងពីឆ្នាំ២០១៤/២០១៥ ដែលនៅពេលមានចំនួន ៦២% នៃសំណុំរឿង ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅសាលាឧទ្ធរណ៍ភ្នំពេញ។ នេះបង្ហាញថាការចូលជាធរមាននៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជនក្នុងឆ្នាំ២០១៦ មិនទាន់បាននាំមកនូវភាពប្រសើរឡើងក្នុងការគាំពារសិទ្ធិនេះនៅឡើយ ហើយសាលាឧទ្ធរណ៍កម្រប្រើវិធានការដោះលែងកុមារកំពុងជាប់ឃុំខ្លួនបណ្ដោះអាសន្នឱ្យបាននៅក្រៅឃុំនោះទេ។ មួយវិញទៀត ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ នៅពេលដែលកុមារទំនាស់នឹងច្បាប់ត្រូវបានសម្រេចឱ្យរួចផុតពីបទចោទដោយសាលាដំបូង តែត្រូវរក្សាការឃុំខ្លួនដដែលបន្ទាប់ពីតំណាងអយ្យការបានប្ដឹងឧទ្ធរណ៍ទៅលើសេចក្ដីសម្រេចនេះ គឺមានចំនួន ៦ នាក់ក្នុងចំណោម ៦ នាក់)។

សម្រាប់រយៈពេលពីរឆ្នាំជាប់គ្នា កុមារទំនាស់នឹងច្បាប់ទាំងអស់ដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន បានចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ពួកគេ (១៤ នាក់ក្នុងចំណោម ១៤ នាក់) ដោយមានសំលៀកបំពាក់ជាឯកសណ្ឋានពន្ធនាគារ។ គួរឱ្យសោកស្ដាយ គ្មានកុមារទំនាស់នឹងច្បាប់ណាម្នាក់បង្ហាញខ្លួនក្នុងឯកសណ្ឋានពណ៌ខៀវសម្រាប់ទណ្ឌិតនោះទេ។ នេះគឺការប្រសើរគួរកត់សម្គាល់លើបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ ២៨,៦% ហើយនេះជាការវិវឌ្ឍមួយនៃការគោរពតាមសិទ្ធិសន្មតទុកជាមុនថាគ្មានទោស ឱ្យកាន់តែប្រសើរឡើង។ ដូច្នេះហើយ គួរតែមានការយកចិត្តទុកដាក់ជាពិសេសដើម្បីធានាថាវឌ្ឍនភាពនេះនៅរក្សាបន្តទៀត។ គួរទទួលស្គាល់ថាការបង្ហាញខ្លួនរបស់កុមារក្នុងដំណើរការជំនុំជម្រះដោយតម្រូវឱ្យកុមារស្លៀកសំលៀកបំពាក់ឯកសណ្ឋានពន្ធនាគារ អាចជាបទពិសោធដែលមានការប៉ះទង្គិចដល់កុមារ និងគួរយកចិត្តទុកដាក់ការពារឧត្តមប្រយោជន៍របស់កុមារទំនាស់នឹងច្បាប់ឱ្យបានពេញលេញគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី។ ម.ស.ម.ក ក៏សូមស្នើឱ្យតុលាការ និងអគ្គនាយកដ្ឋានពន្ធនាគារខិតខំបន្ថែមទៀត ព្រមទាំងអនុញ្ញាតឱ្យកុមារទំនាស់នឹងច្បាប់អាចចូលរួមសវនាការដោយស្លៀកពាក់ឯកសណ្ឋានស៊ីវិល។

*តួលេខទី៣៦៖ ភាគរយនៃជនជាប់ចោទជាកុមារដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២១) និងតុលាការគោលដៅចំនួនបួន (ពីឆ្នាំ២០២២)*[219]

---

[218] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុប (២៦ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៧៧២ ដែលបានសង្កេតក្នុងឆ្នាំ ២០២៣។

[219] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នីមួយៗ។ ដោយហេតុថាសាលាឧទ្ធរណ៍ភ្នំពេញមានយុត្តាធិការគ្របដណ្ដប់ទូទាំងប្រទេស មុនពេលដែលសាលាឧទ្ធរណ៍ទាំងបីចាប់ផ្ដើមដំណើរការក្នុងខែមេសា ឆ្នាំ២០២០ ដូច្នេះតួលេខចុងក្រោយក្នុងអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ អាចត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីនិន្នាការថ្នាក់




មានចំនួន ៨៥,៧% នៃកុមារទំនាស់នឹងច្បាប់ក្នុងសំណុំរឿងដែលបានសង្កេតនៅសាលាឧទ្ធរណ៍**ភ្នំពេញ** ក្នុងឆ្នាំ ២០២៣ (៦ នាក់ ក្នុងចំណោម ៧នាក់) ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន គឺកើនឡើងបើធៀបនឹងឆ្នាំ២០២២ មានចំនួនតែ ៨៣,៣% (៥ នាក់ ក្នុងចំណោម ៦ នាក់) ហើយមានចំនួន ៧៥% នៅឆ្នាំ២០២១។ និន្នាការស្រដៀងគ្នានេះដែរនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** មានចំនួន ១០០% នៅឆ្នាំ២០២៣ (២ នាក់ក្នុងចំណោម ២ នាក់)មានការកើនឡើងបើធៀបនឹងឆ្នាំ២០២២ មាន៨០% (៤ នាក់ក្នុងចំណោម ៥ នាក់)។ សាលាឧទ្ធរណ៍**បាត់ដំបង** ហាក់មានភាពប្រសើរជាងសាលាឧទ្ធរណ៍ទាំងពីរខាងលើមានចំនួន ៧៦,៥% នៅឆ្នាំ២០២៣ (១៣ នាក់ក្នុងចំណោម ១៧ នាក់) មានការថយចុះបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ទៅ ៩៣,៣% (១៤ នាក់ក្នុងចំណោម ១៥ នាក់)។

គួរកត់សម្គាល់ថាចំនួនសវនាការ ដែលបានសង្កេតពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់នៅមានកម្រិតនៅឡើយនៅឆ្នាំ២០២២ និង២០២៣ ដូច្នោះមិនអាចធ្វើសេចក្ដីសន្និដ្ឋានច្បាស់លាស់អំពីនិន្នាការនេះបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យដែលប្រមូលជារួមបង្ហាញយ៉ាងច្បាស់ថា ការឃុំខ្លួនបណ្ដោះអាសន្នគឺជាវិធានដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ ជាជាងករណីលើកលែងនៅក្នុងសំណុំរឿងទាំងនោះ។ ការឃុំខ្លួនកុមារទំនាស់នឹងច្បាប់គឺជាវិធានការចុងក្រោយមិនត្រូវបានអនុវត្តត្រឹមត្រូវនោះទេ ដែលនាំឱ្យមានការបំពានទាំងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែពិចារណាជាចម្បងនៅពេលធ្វើសេចក្ដីសម្រេច ឬដាក់ទោសលើកុមារដែលបានរកឃើញថាបានបំពានច្បាប់ព្រហ្មទណ្ឌ។[220] ការដកហូតសិទ្ធិសេរីភាពរបស់កុមារចាប់ពីពេលឃាត់ខ្លួន, នៅពេលដំណើរការនីតិវិធីទាំងមូល និងការផ្ដន្ទាទោស គឺត្រូវចាត់ទុកជាវិធានការចុងក្រោយ ហើយសម្រាប់តែក្នុងករណីពិសេសប៉ុណ្ណោះ និងមានរយៈពេលខ្លីបំផុត។[221] ច្បាប់ជាតិគួរចែងពីវិធានការមិនឃុំខ្លួនផ្សេងៗ និងកំណត់យ៉ាងច្បាស់ពី

---

ជាតិ។ តួលេខចាប់ពីឆ្នាំ២០២២ ទៅមុខគឺ ម.ស.ម.ក បានចាប់ផ្ដើមការសង្កេតសវនាការរបស់ខ្លួននៅតុលាការទាំងបីបន្ថែមទៀត។ តួលេខក្នុងឆ្នាំ ២០២១ ត្រូវបានបង្ហាញផងដែរដើម្បីបញ្ចៀសគម្លាតនៃទិន្នន័យ ហើយឆ្លុះបញ្ចាំងតែអំពីស្ថានភាពនៅក្នុងដែលស្ថិតក្រោមយុត្តាធិការរបស់សាលាឧទ្ធរណ៍ភ្នំពេញប៉ុណ្ណោះ។

[220] អ.ស.ក មាត្រា ៣(១) *សូមមើល*គណៈកម្មាធិការនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ សេចក្ដីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧៦។

[221] អ.ស.ក មាត្រា ៣៧(ខ) *សូមមើល* គណៈកម្មាធិការនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ សេចក្ដីពន្យល់ទូទៅលេខ២៤ វាក្យខណ្ឌ៧៣ ៨២ ដល់ ៩៥។

អាទិភាពនៃការប្រើប្រាស់វិធានការទាំងនេះ [222] ហើយច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានបង្កើតនូវវិធានការបង្វែរសម្រាប់កុមារទំនាស់នឹងច្បាប់ដែលជាជម្រើសផ្សេងពីការដាក់ពន្ធនាគារ។ [223] អំឡុងពេលធ្វើរបាយការណ៍នេះ ចៅក្រមបានពិចារណាលើការសម្រេចមិនផ្តន្ទាទោសដាក់ពន្ធនាគារសម្រាប់កុមារទំនាស់នឹងច្បាប់មានចំនួនតែ ២៧,៣% ប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេត (៣ នាក់ក្នុងចំណោម ១១ នាក់) គឺបានកើនឡើងបើធៀបនឹងឆ្នាំ ២០២២ មានចំនួនត្រឹមតែ ៨,៣% (១ នាក់ក្នុងចំណោម ១២ នាក់)។

គួរកត់សម្គាល់ជាវិជ្ជមានថា ក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នា ការអនុវត្តមិនផ្តន្ទាទោសរបស់សាលាឧទ្ធរណ៍ **បាត់ដំបង** មានភាពប្រសើរ ដោយសារតួលេខនៅឆ្នាំ២០២២ មានចំនួន ១០% (១ នាក់ក្នុងចំណោម ១០ នាក់) បានកើនឡើងដល់ចំនួន៤២,៩% ក្នុងឆ្នាំ២០២៣ (៣ នាក់ក្នុងចំណោម ៧ នាក់)។ ទោះបីជា របកគំហើញទាំងនេះបង្ហាញថាតុលាការគោលដៅទាំងអស់ កំពុងបានប្រើប្រាស់ជម្រើសផ្សេងៗដោយមិនដាក់ពន្ធនាគារក៏ដោយ តែរបកគំហើញទាំងនេះនៅមានកម្រិតនៅឡើយ ដូចនេះមិនអាចធ្វើការសេចក្តីសន្និដ្ឋានណាមួយនោះទេ។ កាលពីឆ្នាំ២០១៩ សាលាឧទ្ធរណ៍**ភ្នំពេញ** បានលើកឡើងថា ការអនុវត្តវិធានការបង្វែរសម្រាប់កុមារទំនាស់នឹងច្បាប់មិនអាចធ្វើទៅរួចនោះទេ ដោយសារតែខ្វះយន្តការដើម្បីគាំទ្រវិធានការបង្វែរនេះ។ [224] ការដែលចៅក្រមនៅសាលាឧទ្ធរណ៍**ភ្នំពេញ** និង **ព្រះសីហនុ** មិនបានពិចារណាលើសេចក្តីសម្រេចផ្តន្ទាទោស មិនដាក់ពន្ធនាគារក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់នោះ នៅឆ្នាំ២០២២ និង២០២៣ បង្ហាញថាយន្តការបែបនេះមិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។

## សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា សាលាឧទ្ធរណ៍ត្រូវតែផ្តល់*អាទិភាពខ្ពស់បំផុត* ចំពោះសំណុំរឿងដែលពាក់ព័ន្ធនឹងកុមារដែលមានទំនាស់នឹងច្បាប់ ជាពិសេសករណីដែលកុមារត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ បណ្តឹងឧទ្ធរណ៍គួរតែត្រូវបានជំនុំជម្រះក្នុងអំឡុងពេល ៣ ខែ យ៉ាងយូរគិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសន្យានុម័តមិនអាចជម្នះបាន។ [225] គោលបំណងចម្បងនៃបទប្បញ្ញត្តិទាំងនេះ គឺដើម្បីធានានូវការទទួលបានភាពយុត្តិធម៌ឆាប់រហ័សសម្រាប់កុមារទំនាស់នឹងច្បាប់ក្នុងដំណើរការនីតិវិធី ដូចជាតាមរយៈ ការផ្តល់អាទិភាពលើសំណុំរឿងកុមារទំនាស់នឹងច្បាប់នេះ ព្រមទាំងបង្កើតផែនការសម្រាប់សវនាការលើបណ្តឹងឧទ្ធរណ៍ ដើម្បីទប់ស្កាត់ការពន្យារពេលសវនាការមិនចាំបាច់ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់សិទ្ធិ និងសុខុមាលភាពរបស់កុមារទំនាស់នឹងច្បាប់ ជាពិសេសកុមារដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

គោលបំណងដើម្បីធ្វើការវិភាគនេះ ម.ស.ម.ក នឹងអនុវត្តតាមគោលការណ៍ណែនាំដែលកំណត់ដោយច្បាប់ និងពិចារណាថាសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានគោរព ប្រសិនបើសវនាការបានធ្វើឡើង

---

[222] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧៣។

[223] ក្រមព្រហ្មទណ្ឌ មាត្រា ៤០ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជំពូក ១០។

[224] នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ម.ស.ម.ក បានជួបប្រជុំជាមួយឯកឧត្តមប្រធាន ឯកឧត្តមអនុប្រធានទាំងអស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញា ចៅក្រមមួយរូប និងឯកឧត្តមអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០១៧/២០១៨ របស់ខ្លួនស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[225] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥៧។

ក្នុងអំឡុងពេលបីខែ បន្ទាប់ពីបណ្តឹងឧទ្ធរណ៍ត្រូវបានទទួលដោយសាលាឧទ្ធរណ៍។ គួរឱ្យកត់សម្គាល់ដែរថា នៅឆ្នាំ ២០២៣ បទដ្ឋាននេះបានបំពេញដល់កុមារទំនាស់នឹងច្បាប់មានចំនួន ៨០% (១៦ នាក់ក្នុងចំណោម ២០ នាក់)។

ទោះជាយ៉ាងណាក៏ដោយ គួរឱ្យកត់សម្គាល់ថា នៅសាលាឧទ្ធរណ៍**ភ្នំពេញ** បានបង្ហាញពីការអនុវត្តថយចុះដល់ ៥៧,១% (៤ នាក់ក្នុងចំណោម ៧ នាក់) ដែលជាចំនួនទាបជាងគេក្នុងចំណោមតុលាការគោលដៅផ្សេងទៀត។ មានសំណុំរឿងចំនួន ២ ដែលបានសង្កេត កុមារទំនាស់នឹងច្បាប់បានចំណាយពេលរង់ចាំដល់ថ្ងៃសវនាការមានរយៈពេលយូរហួសពីច្បាប់កំណត់ រាប់គិតពីថ្ងៃទទួលបណ្តឹងឧទ្ធរណ៍ រហូតដល់ថ្ងៃជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នោះ។ សំណុំរឿងទី១ មានរយៈពេល ១ ឆ្នាំ ១០ ខែ និង១០ ថ្ងៃ ទោះបីជាកុមារទំនាស់នឹងច្បាប់ក្នុងសំណុំរឿងនេះមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នក៏ដោយ។ សំណុំរឿងទី២ កុមារទំនាស់នឹងច្បាប់បានចំណាយចំនួន ៣ ឆ្នាំ ៨ ខែ និង១២ ថ្ងៃដែលបង្ហាញពីការពន្យារពេលក្នុងការផ្តល់យុត្តិធម៌។

ផ្ទុយទៅវិញ គួរសាទរ តុលាការគោលដៅពីរផ្សេងទៀត បានបង្ហាញពីការប្រកាន់ខ្ជាប់នូវការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។ ទី១ នៅសាលាឧទ្ធរណ៍**បាត់ដំបង** បានធ្វើការជំនុំជម្រះសំណុំរឿងកុមារទំនាស់នឹងច្បាប់នេះដូចបានកំណត់ដោយច្បាប់គឺក្នុងអំឡុងពេល ៣ ខែ មានចំនួន ៩០,៩% នៃសំណុំរឿងដែលបានសង្កេត(១០ នាក់ក្នុងចំណោម ១១ នាក់)។ ទន្ទឹមនឹងនេះដែរ គួរកត់សម្គាល់ថាកុមារទំនាស់នឹងច្បាប់ដែលមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ហើយរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេទេ មិនបានអនុវត្តដូចករណីកុមារដែលត្រូវបានឃុំខ្លួននោះទេ។ ទី២ នៅសាលាឧទ្ធរណ៍**ព្រះសីហនុ** បានប្រកាន់យ៉ាងខ្ជាប់ខ្ជួនតាមការកំណត់របស់ច្បាប់ស្តីពីយុត្តិធម៌អនីតិជនគឺថារាល់សវនាការត្រូវបានធ្វើឡើងអំឡុងពេល ៣ ខែ ដល់កុមារចំនួន ២ នាក់។ ដូចនេះ មិនអាចធ្វើសេចក្តីសន្និដ្ឋានជាក់លាក់ណាមួយបានទេ ដោយសារទិន្នន័យដែលបង្ហាញនេះនៅមានកម្រិតនៅឡើយ ទោះជាយ៉ាងណា សាលាឧទ្ធរណ៍**ព្រះសីហនុ** បានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សិទ្ធិនេះ ដើម្បីផ្តល់ យុត្តិធម៌ឆាប់រហ័សដល់កុមារទំនាស់នឹងច្បាប់។

### *ការបែងចែកជនជាប់ឃុំជាកុមារក្នុងពន្ធនាគារ*

បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌កុមារចែងថា កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពត្រូវដាក់ឱ្យដាច់ដោយឡែកពីជនជាប់ឃុំជាមនុស្សពេញវ័យ និងត្រូវនៅក្នុងមណ្ឌលដាច់ដោយឡែកដែលមានបុគ្គលិកបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងប្រតិបត្តិតាមគោលនយោបាយ និងអនុវត្តប្រកបដោយកុមារមេត្រី។ ករណីលើកលែងអាចអនុវត្តបាន តែដើម្បីឧត្តមប្រយោជន៍របស់កុមារដែលត្រូវឃុំខ្លួនប៉ុណ្ណោះ។[226] ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា កុមារដែលត្រូវបានដកហូតសេរីភាពត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីអ្នកជាប់ឃុំពេញវ័យ ហើយត្រូវឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលស្តារយុវនីតិសម្បទា ដែលគ្រប់គ្រងដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវស្តីអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ បទដ្ឋានសិទ្ធិកុមារជាតិ និងអន្តរជាតិ និងការប្រព្រឹត្តចំពោះកុមារជាប់ឃុំ។ ច្បាប់នេះចែងបន្ថែមទៀតថា អនីតិជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីទណ្ឌិតជាកុមារ។[227]

---

[226]គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៩២ និង ៩៣។

[227] ក្រមនីតិវិធីព្រហ្មទណ្ឌ ជំពូក ១៣ និង ១៤។

ជាចំណុចគួរឱ្យសាទរ សម្រាប់រយៈពេលពីរឆ្នាំជាប់ៗគ្នានេះ គ្មានការបង្ហាញថាកុមារទំនាស់នឹងច្បាប់ណាម្នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៣ ត្រូវបានឃុំខ្លួនជាមួយជនជាប់ឃុំពេញវ័យនោះទេ។

*ការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់*

តាមច្បាប់សិទ្ធិមនុស្ស កុមារមានសិទ្ធិទទួលបានការគោរពឯកជនភាពរបស់ពួកគេគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី[228] ប្រការនេះ រាប់បញ្ចូលទាំងដំណាក់កាលដំបូងនៃការអនុវត្តច្បាប់ រហូតដល់សេចក្តីសម្រេចជាស្ថាពរ ឬប្រសិនបើត្រូវបានផ្តន្ទាទោស ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការឃុំឃាំង ឬការដកហូតសេរីភាពមិនគួរអនុវត្ត។ ហេតុផលជាមូលដ្ឋានគឺដើម្បីជៀសវាងការប៉ះពាល់ដែលបណ្តាលមកពីការផ្សព្វផ្សាយជាសាធារណៈ ឬការយល់ ឃើញផ្សេងៗណាមួយ។[229] ដូច្នេះ វិធានច្បាប់សម្រាប់សវនាការយុត្តិធម៌កុមារត្រូវធ្វើឡើងអសាធារណៈ។[230] ក្នុងបរិបទនៃច្បាប់កម្ពុជា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងយ៉ាងច្បាស់ថា ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមនៃរឿងក្តីអនីតិជនត្រូវធ្វើក្នុងសវនាការជាអសាធារណៈ។[231]

ឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ ឬកុមាររងគ្រោះអាចត្រូវបានការពារបន្ថែមទៀតដោយមិនបង្ហាញអត្តសញ្ញាណរបស់ ពួកគេតាមរយៈដាក់បាំងជារនាំង ឬប្រើមធ្យោបាយផ្សេងទៀតក្នុងពេលផ្តល់សក្ខីកម្ម។ ការប្រើប្រាស់ឧបករណ៍នានា មានដូចជាសវនាការតាមប្រព័ន្ធវីដេអូ ឬសវនាការអសាធារណៈ គួរតែត្រូវបានពិចារណា។ ប្រសិនបើសាលដីកា ឬការផ្តន្ទាទោសត្រូវប្រកាសជាសាធារណៈ នោះអត្តសញ្ញាណរបស់កុមារ មិនគួរត្រូវបានបង្ហាញឡើយ។[232] ជាចុងក្រោយ រាល់ឯកសារទាក់ទងនឹងកុមារ គួរតែត្រូវបានរក្សាការសម្ងាត់យ៉ាងតឹងរ៉ឹង និងមិនបើកចំហដល់ភាគីទីបីលើកលែងតែ ចំពោះអ្នកដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការស៊ើបអង្កេត និងការវិនិច្ឆ័យលើសំណុំរឿង។[233] ប្រការនេះត្រូវបានធានា ទោះបីជានៅពេលកុមារឈានដល់អាយុ ១៨ ក៏ដោយ។[234]

---

[228] អ.ស.ក មាត្រា ៤០(២)(vii) *សូមមើល* អ.ស.ក មាត្រា ១៦ និង ៤០(១) គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៦។

[229] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

[230] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[231] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៤៧។

[232] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[233] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[234] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

*តួលេខទី៣៧៖ ភាគរយនៃសំណុំរឿងដែលបានអនុវត្តវិធានការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់[235]*




នៅឆ្នាំ២០២៣ ចៅក្រមបានចាត់វិធានការ (សវនាការអសាធារណៈ) ដើម្បីការពារឯកជនភាពកុមារទំនាស់នឹងច្បាប់មានចំនួន៥២,៩%(៩ នាក់ ក្នុងចំណោម ១៧ នាក់)។ ទិន្នន័យនេះ បានថយចុះ បន្តិចបើធៀបនឹងឆ្នាំ២០២២ មានចំនួន ៥៤,៥% (១២ នាក់ក្នុងចំណោម ២២ នាក់) ដែលបង្ហាញពីចំណាត់ការដោះស្រាយបញ្ហានេះមិនទាន់បានប្រសើរ។ ទោះជាយ៉ាងនេះក្តី មានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយ។

នៅសាលាឧទ្ធរណ៍**ភ្នំពេញ** ចៅក្រមបានបើកសវនាការជាអសាធារណៈមានចំនួន ៣៣,៣% ប៉ុណ្ណោះ (២ នាក់ក្នុងចំណោម ៦ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេត ។ ទោះបីជាយ៉ាងណាក៏ដោយ នេះគឺជាការវិវឌ្ឍមួយបើធៀបនឹងឆ្នាំ២០២២ និងឆ្នាំ២០២១ គឺមិនមានប្រើវិធានការបែបនេះឡើយ។ យោងតាមរកគំហើញខាងលើបង្ហាញថាកុមារទំនាស់នឹងច្បាប់ចំនួន ២ នាក់ក្នុងចំណោម ៣ នាក់ មិនបានទទួលអត្ថប្រយោជន៍ពីសវនាការដែលការពារឯកជនរបស់កុមារឡើយ បញ្ហានេះត្រូវបានពិភាក្សាដោយយកចិត្តទុកដាក់ជាមួយតុលាការនៅខែសីហា ឆ្នាំ ២០១៩ នៅពេលដែលតុលាការបានបដិសេធចំពោះរបកគំហើញអវិជ្ជមានស្រដៀងគ្នានេះ និងបានលើកឡើងពីការដំឡើងប្រព័ន្ធបច្ចេកវិទ្យាសវនាការតាមប្រព័ន្ធវីដេអូដែលជាជំនួយរបស់អង្គការយូនីសេហ្វ ដើម្បីការពារភាពឯកជនរបស់កុមារឱ្យកាន់តែប្រសើរឡើង។ តុលាការក៏បានស្នើឱ្យ ម.ស.ម.ក កត់ត្រា និងរាយការណ៍មកកាន់ប្រធានតុលាការចំពោះចៅក្រមណា ដែលមិនទាន់គោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់។[236]

កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ភ្នំពេញ បាននិយាយថា ជាគោលការណ៍ ចៅក្រមតែងតែបើកសវនាការជាអសាធារណៈក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារមានសំណុំរឿងជាច្រើនដែលចៅក្រមត្រូវដោះស្រាយ ចៅក្រមតែងតែជួបប្រទះការលំបាកក្នុងការពិនិត្យរវាងសំណុំរឿងដែលពាក់ព័ន្ធនឹងមនុស្សពេញវ័យ និងសំណុំរឿងដែលពាក់ព័ន្ធនឹងកុមារ នេះនាំឱ្យសំណុំរឿងពាក់ព័ន្ធនឹងកុមារមួយចំនួនត្រូវបានបើកសវនាការជាសាធារណៈដោយអចេតនា។ តុលាការបានលើកឡើងថាតុលាការនឹងកែសម្រួលបញ្ជីនៃកម្មវិធីសវនាការ ដើម្បីបែងចែកប្រភេទនៃជនជាប់ចោទ (ឧទាហរណ៍ ជាកុមារ និងមនុស្សពេញវ័យ) ក្នុងគោលបំណងជួយសម្រួលដល់ដំណើរការនីតិវិធីដោយរលូន កាត់បន្ថយការភ័ន្តច្រឡំ និងទប់ស្កាត់បញ្ហានេះកើតឡើងនាពេលអនាគត។ តុលាការក៏បានលើកឡើងផងដែរថានឹងធ្វើឱ្យមានភាពប្រសើរឡើងពាក់ព័ន្ធនឹងការគោរពសិទ្ធិកុមារទំនាស់នឹង

---

235 ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុប ២៦ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៧៧២ ដែលបានសង្កេតក្នុងឆ្នាំ២០២៣។

236 នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ម.ស.ម.ក បានជួបប្រជុំជាមួយឯកឧត្តមប្រធាន ឯកឧត្តមអនុប្រធានទាំងអស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញា ចៅក្រមមួយរូប និងឯកឧត្តមអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំ២០១៧/២០១៨ របស់ខ្លួនស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

ច្បាប់ ដោយផ្តោតសំខាន់លើការប្រើប្រាស់សវនាការអសាធារណៈជាប្រចាំ។[237] សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញថានឹងពិនិត្យសម្របសម្រួលដោយធ្វើការណែនាំផ្ទៃក្នុង ដើម្បីបង្កើនប្រសិទ្ធភាពនៃការជំនុំជម្រះលើករណីកុមារទំនាស់នឹងច្បាប់ ស្របតាមច្បាប់។[238] ម.ស.ម.ក សាទរចំពោះការប្តេជ្ញាចិត្តទាំងនេះ ហើយសង្ឃឹមថាការអនុវត្តនឹងមានភាពប្រសើរឡើងនៅឆ្នាំ២០២៤។

នៅសាលាឧទ្ធរណ៍**បាត់ដំបង** មានភាពប្រសើរបើតាមការប្រៀបធៀបៈ តុលាការបានបើកសវនាការអសាធារណៈមានចំនួន ៧៧,៨% នៃសំណុំរឿងដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ (៧ នាក់ក្នុងចំណោម ៩ នាក់) មានការថយចុះ បើធៀបនឹងឆ្នាំ២០២២ មានចំនួន ៨៥,៧% (១២ នាក់ក្នុងចំណោម១៤ នាក់)។ ទោះបីជាមានថយចុះបន្តិចក៏ដោយ គួរមានភាពចាំបាច់នៃការអនុវត្តវិធានការនេះបន្ថែមទៀត ដើម្បីធានាថាសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ត្រូវបានជំនុំជម្រះនៅក្នុងសវនាការជាអសាធារណៈ។ នៅខែមីនា ឆ្នាំ២០២៣ តំណាងរបស់តុលាការបានលើកឡើងថា ជាទូទៅ ចៅក្រមដំណើរការសវនាការជាអសាធារណៈនៅគ្រប់សំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ជាអសាធារណៈ ប៉ុន្តែតុលាការបានបន្ថែមថា មិនមាននាំងគ្រប់គ្រាន់សម្រាប់ការពារនូវឯកជនភាពរបស់កុមារទេ។[239] នៅខែសីហា ឆ្នាំ២០២៣ តុលាការបានអះអាងថា វិធានការកំពុងអនុវត្តដើម្បីពង្រឹងការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់។[240]

ដោយឡែក សាលាឧទ្ធរណ៍**ព្រះសីហនុ**មិនបានបើកសវនាការជាអសាធារណៈទេ មានចំនួន ២ សំណុំរឿង (មានអនីតិជន២នាក់) ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣ ។ ទិន្នន័យនៅមានកម្រិត ដូចនេះ មិនទាន់អាចធ្វើសេចក្តីសន្និដ្ឋានជាក់លាក់ណាមួយនោះទេ។ ទិន្នន័យនេះបញ្ជាក់បន្ថែមលើរបកគំហើញពីឆ្នាំ២០២២ ថាគ្មានចំណាត់ការណាមួយត្រូវបានធ្វើឡើងដើម្បីការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់នៅក្នុងសវនាការចំនួន ៣ ផងដែរ ហេតុនេះវិធានការសមស្របគួរត្រូវ បានធ្វើឡើងដើម្បីឆ្លើយតបនឹងបញ្ហានេះ។ នៅខែធ្នូ ឆ្នាំ២០២២ តំណាងតុលាការនេះបានលើកឡើងថាក្នុងសំណុំរឿងរំលោភសេពសន្ថវៈ ឬប្រទូស្តកេរខ្មាស ជាទូទៅ ចៅក្រមបើកសវនាការជាអសាធារណៈ និងប្រើប្រាស់នាំងដើម្បីការពារឯកជនភាពរបស់កុមាររងគ្រោះ។ ទោះជាយ៉ាងណាក្តី តុលាការបានបន្ថែមថាការធ្វើបែបនេះគឺអាស្រ័យទៅលើការសម្រេចចិត្តរបស់ចៅក្រម ដោយសារប្រការនេះមិនមែនជាលក្ខខណ្ឌតម្រូវដោយច្បាប់

---

[237] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[238] លិខិតលេខ៧០៦ របឧ/២៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[239] នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

[240] នៅថ្ងៃទី២៩ ខែសីហា ឆ្នា២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

ទេ។[241] នៅខែមីនា ឆ្នាំ២០២៣ មន្ត្រីតុលាការបានកត់សម្គាល់ថា តុលាការខ្វះឧបករណ៍ និងបរិក្ខារ ដូចជា វាំងដើម្បីការពារភាពឯកជនរបស់កុមារ ទំនាស់នឹងច្បាប់ក្នុងអំឡុងពេលសវនាការ។[242]

ម.ស.ម.ក សាទរ ចំពោះសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** ដោយថាក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នានេះ តុលាការបានបើកសវនាការជាអសាធារណៈគ្រប់សំណុំរឿងទាំងអស់ពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់នៅឆ្នាំ២០២៣។ នេះបង្ហាញឱ្យឃើញថាតុលាការមានយន្តការរឹងមាំក្នុងការការពារជាប្រចាំនូវសិទ្ធិជាឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់។ ម.ស.ម.ក មិនមានព័ត៌មាននៃការអនុវត្តជាក់លាក់លើសិទ្ធិទាំងនេះក្នុងសវនាការបានទេ ហេតុនេះ មិនអាចធ្វើការសន្និដ្ឋានណាមួយថា សិទ្ធិផ្សេងទៀតរបស់កុមានទំនាស់នឹងច្បាប់ត្រូវបានគោរពតាមខ្ជាប់ខ្ជួន ឬយ៉ាងណានោះទេ។

## សេចក្តីសន្និដ្ឋាន

ខណៈដែលវិធាននានាត្រូវបានអនុវត្តដើម្បីលើកកម្ពស់សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ ទន្ទឹមនឹងនេះ ក៏មានបញ្ហាប្រឈមមួយចំនួនផងដែរដែលនាំឱ្យសិទ្ធិទាំងនេះមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ។ ជាពិសេសគឺវិធាននៃការឃុំខ្លួនបណ្តោះអាសន្នក្នុងសំណុំរឿងកុមារទំនាស់នឹងច្បាប់ត្រូវបានធ្វើឡើយជាញឹកញាប់ ការការពារឯកជនភាព និងការទទួលបានយុត្តិធម៌ដោយគ្មានការពន្យារពេល មិនទាន់ត្រូវបានគោរពលេញលេញនៅឡើយនៅសាលាឧទ្ធរណ៍ភ្នំពេញ។ ដូច្នោះវិធានការសមស្របគួរត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហានេះ និងធានាថាកុមារទំនាស់នឹងច្បាប់ទទួលបានយុត្តិធម៌ និងសមធម៌ពេញលេញក្នុងដំណើរការនីតិវិធីតុលាការ។

---

241 នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

242 នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើបេកគំហើញនៃសកម្មភាពសង្កេតសវនាការរបស់ខ្លួន។

# ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ទោះបីជារបកគំហើញបានបង្ហាញពីវឌ្ឍភាពពីមួយឆ្នាំទៅមួយឆ្នាំនូវសិទ្ធិមួយចំនួនក៏ដោយ ក៏ ម.ស.ម.ក កត់សម្គាល់ថា តុលាការទាំងបួនមិនទាន់បានលើកកម្ពស់ពេញលេញនូវសិទ្ធិមួយចំនួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែរ ដូចបានរៀបរាប់ក្នុងរបាយការណ៍នេះ។ ជាពិសេស វិធាននៃការឃុំខ្លួនបណ្តោះអាសន្នជាញឹកញាប់ត្រូវបានអនុវត្ត រួមទាំងសំណុំរឿងកុមារទំនាស់នឹងច្បាប់ មានការលើកឡើងអំពីការធ្វើទារុណកម្មនៅដំណាក់កាលស៊ើបអង្កេតដោយនគរបាលយុត្តិធម៌ និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមិនទាន់បានអនុវត្តពេញលេញនៅឡើយដែរ។

ជារួមមក បញ្ហាភាគច្រើនដែលត្រូវបានរំលេចនៅក្នុងរបាយការណ៍នេះ អាចត្រូវបានដោះស្រាយតាមរយៈវិធីងាយៗ អាចចំណាយធនធានតិច និងអាចអនុវត្តបាន។ ចំណុចផ្សេងទៀតអាចផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម និងមេធាវីអំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សាលាឧទ្ធរណ៍ក៏អាចជាគំរូដល់តុលាការជាន់ដំបូង និងមានឥទ្ធិពលជាវិជ្ជមានដល់គុណភាពនៃការគ្រប់គ្រងយុត្តិធម៌នៅកម្ពុជា ព្រមទាំងរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងនីតិរដ្ឋផងដែរ។

## ៦.១.អនុសាសន៍រួម

៦.១.១ ក្រសួងយុត្តិធម៌គួររៀបចំកិច្ចប្រជុំជាទៀងទាត់ ស្តីពីការអនុវត្តជាក់ស្តែងនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមួយចៅក្រមសាលាឧទ្ធរណ៍ ដើម្បីលើកកម្ពស់ការគោរពគោលគំនិតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្អែកលើមូលដ្ឋាននៃបទដ្ឋានជាតិ និងអន្តរជាតិ។

៦.១.២ ក្រសួងយុត្តិធម៌គួរបង្កើតទម្រង់បទដ្ឋានសម្រាប់សេចក្តីសម្រេច និងបញ្ជូនទៅគ្រប់តុលាការទាំងអស់ ដើម្បីអនុវត្ត។ ទម្រង់នេះគួរមានព័ត៌មានដូចខាងក្រោម ដើម្បីធានាថារបាយការណ៍សង្ខេបដែលចៅក្រមប្រធានក្រុមប្រឹក្សាអាន គឺមានភាពពេញលេញ៖ (១). បទល្មើសដែលបានចោទប្រកាន់លើជនជាប់ចោទ និងច្បាប់ពាក់ព័ន្ធ (២). កាលបរិច្ឆេទពេលវេលា ទីកន្លែងដែលបទល្មើសកើតឡើង និងភាគីពាក់ព័ន្ធ (៣). សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជនជាប់ចោទមានសិទ្ធិទទួលបាន។ ជាពិសេសទម្រង់បទដ្ឋាននៃសេចក្តីសម្រេច គួររំឭកចៅក្រមអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការសន្មតទុកជាមុនថាគ្មានទោសរហូតដល់មានសេចក្តីសម្រេចជាស្ថាពរ និងអាជ្ញាអស់ជំនុំ ព្រមទាំងប្រាប់ថាបន្ទុកនៃភស្តុតាងជារបស់ព្រះរាជអាជ្ញា។

៦.១.៣ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ថាតើពួកគេយល់ដឹងអំពីបទចោទប្រកាន់ និងសិទ្ធិរបស់ពួកគេដែរឬទេ។ ការខកខានក្នុងការអានព័ត៌មានខាងលើនៅពេលចាប់ផ្តើមការជំនុំជម្រះ គួរបង្កើតបានជាហេតុផលនៃការប្តឹងឧទ្ធរណ៍ចំពោះការផ្តន្ទាទោស។

## ៦.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

៦.២.១ ចៅក្រមគួរលើកកម្ពស់ការប្រើប្រាស់ទោសជំនួសជាជាងការឃុំខ្លួន រួមទាំងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[243] ដោយអនុលោមតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ចំណុច ១៦.៣.២ ដើម្បីធានាបាននូវការលើកលែងការឃុំខ្លួន និងសិទ្ធិមានសេរីភាពតាមច្បាប់។

៦.២.២ តុលាការត្រូវធានាថា ជនជាប់ចោទ ជាពិសេសជនជាប់ឃុំត្រូវបាននាំយកមកជំនុំជម្រះភ្លាមៗ តាមដែលអាចធ្វើទៅបាន និងការពន្យារពេលដោយគ្មានហេតុផល ធ្វើឱ្យប៉ះពាល់ដល់ការផ្តល់យុត្តិធម៌ឆាប់រហ័ស។

## ៦.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព

៦.៣.១ តុលាការត្រូវតែស៊ើបអង្កេតភ្លាមៗ និងដោយហ្មត់ចត់លើការលើកឡើងរបស់ជនជាប់ចោទអំពីការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្មដើម្បីទទួលបានចម្លើយសារភាពពីពិរុទ្ធភាពមុននឹងចេញសេចក្តីសម្រេច។

៦.៣.២ តុលាការត្រូវធានាថា ប្រសិនបើមានការលើកឡើងអំពីការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្មណាមួយ បន្ទាប់ពីធ្វើការស៊ើបអង្កេតរាល់ភស្តុតាង ឬចម្លើយសារភាពដែលទទួលបានតាមវិធីនេះ គឺមិនអាចទទួលយកបានឡើយ ហើយត្រូវធ្វើការជំនុំជម្រះឡើងវិញលើករណីដែលពាក់ព័ន្ធ ហើយធានាឱ្យមានការជួសជុលសំណងសមរម្យដល់ជនរងគ្រោះ។

## ៦.៤. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

៦.៤.១ តុលាការ និងក្រសួងយុត្តិធម៌គួរធានាថា គ្រប់កាលវិភាគសវនាការប្រចាំថ្ងៃត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធអនឡាញ និងបិទផ្សាយនៅលើក្តារខៀនព័ត៌មាននៅខាងក្រៅបន្ទប់សវនាការយ៉ាងហោចណាស់ ២៤ ម៉ោងមុនពេលសវនាការ និងបន្តធានាថា សាធារណជនអាចចូលទៅកាន់បន្ទប់សវនាការនៅគ្រប់សំណុំរឿងទាំងអស់ លើកលែងតែករណីពិសេស ដែលរាប់បញ្ចូលទាំងសំណុំរឿងកុមារផងដែរ។ នៅពេលដែលព័ត៌មានទាំងនេះត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធអនឡាញ និងបិទនៅលើក្តារខៀនព័ត៌មាន ឈ្មោះរបស់កុមារមិនគួរបង្ហាញនោះទេ ផ្ទុយមកវិញអាចដាក់ឈ្មោះជាអក្សរកាត់ ដើម្បីការពារភាពឯកជនរបស់កុមារ។

## ៦.៥. អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

៦.៥.១ ចៅក្រមគួរអានប្រាប់ជនជាប់ចោទអំពីការចោទប្រកាន់លើពួកគេ និងផ្តល់ព័ត៌មានពាក់ព័ន្ធនានាដូចជាកាលបរិច្ឆេទ ទីកន្លែង ភាគីពាក់ព័ន្ធ និងច្បាប់ជាធរមាន។ ប្រការនេះមានសារៈសំខាន់ជាពិសេស ក្នុងករណីដែលបទចោទប្រកាន់អាចត្រូវបានប្តូរ ឬកែចាប់តាំងពីពេលចាប់ខ្លួន/ចោទប្រកាន់ដំបូង។ ចៅក្រមគួរយកចិត្តទុកដាក់ជាពិសេស ដោយធានាថាបានចែករំលែកព័ត៌មានអំពីច្បាប់ពាក់ព័ន្ធ និងទីកន្លែងនៃបទល្មើស។

---

[243] SRSHRC សេចក្តីថ្លែងការណ៍ស្តីពីការបញ្ចប់បេសកកម្ម (ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨) ទំព័រ ៤។

៦.៥.២ ចៅក្រមគួរផ្តល់ការពន្យល់ឱ្យបានគ្រប់ជ្រុងជ្រោយអំពីសិទ្ធិទទួលបានជំនុំជម្រះរបស់ជនជាប់ចោទ។

៦.៥.៣ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ថា តើពួកគេយល់ដឹងអំពីបទចោទប្រកាន់មកលើពួកគេ និងសិទ្ធិរបស់ពួកគេដែរ ឬទេ។

## ៦.៦. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិមានមេធាវី

៦.៦.១ តុលាការ និងអគ្គនាយកដ្ឋានពន្ធនាគារ គួរពិគ្រោះយោបល់ និងសម្របសម្រួលគ្នា ដើម្បីដោះស្រាយបញ្ហាភស្តុភារ និងទំនាក់ទំនងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានទាក់ទងនឹងទីតាំងរបស់ជនជាប់ចោទ។

៦.៦.២ អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាថា ព័ត៌មានអំពីការផ្ទេរជនជាប់ឃុំ គឺត្រូវបានបញ្ជូនជាទៀងទាត់ទៅកាន់មហាអយ្យការ ដើម្បីធានាថាតុលាការនឹងផ្តល់ព័ត៌មានទាក់ទងនឹងកាលបរិច្ឆេទ និងពេលវេលានៃសវនាការលើបណ្តឹងឧទ្ធរណ៍ទៅដល់មណ្ឌលអប់រំកែប្រែដែលឃុំខ្លួនជនជាប់ចោទឱ្យបានត្រឹមត្រូវ។

៦.៦.៣ ចៅក្រមគួរពន្យារពេលសវនាការណាមួយ ប្រសិនបើជនជាប់ចោទមិនមានវត្តមាន ទោះបីជាពួកគេមានមេធាវីការពារក៏ដោយ លុះត្រាតែពួកគេបានលះបង់សិទ្ធិមានវត្តមានជាផ្លូវការ និងច្បាស់លាស់។

៦.៦.៤ តុលាការគួរធានាថា មិនមានទំនាស់ផលប្រយោជន៍ដែលមិនសមស្របនោះទេ ក្នុងករណីដែលមេធាវីការពារឱ្យជនជាប់ចោទច្រើននាក់នៅពេលសវនាការ។

៦.៦.៥ ចៅក្រមគួរប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីរបស់ពួកគេ ប្រសិនបើពួកគេមិនមានមេធាវីការពារ។

៦.៦.៦ ក្រសួងយុត្តិធម៌គួរជូនដំណឹងដល់សាធារណជន អំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ដែលរដ្ឋជាអ្នករ៉ាប់រង រួមទាំងតាមរយៈការផ្សព្វផ្សាយនៅតាមការិយាល័យនគរបាល ពន្ធនាគារ និងអគារតុលាការផងដែរ។

## ៦.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

៦.៧.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទឱ្យបានច្បាស់ អំពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ រហូតទាល់តែមានសេចក្តីសម្រេចជាស្ថាពរ និងអំពីបន្ទុកនៃភស្តុតាងដែលជាភារកិច្ចរបស់ព្រះរាជអាជ្ញា ហើយជនជាប់ចោទមានសិទ្ធិនៅស្ងៀម តែចៅក្រមមិនអាចប្រើប្រាស់ភាពនៅស្ងៀមនេះប្រឆាំងនឹងជនជាប់ចោទឡើយ។

៦.៧.២ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃគួរផ្សព្វផ្សាយអំពីគោលការណ៍ណែនាំច្បាស់លាស់ដែលបញ្ជាក់ថាជនជាប់ចោទដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬជនដែលទើបត្រូវបានជំនុំជម្រះដំបូង ប៉ុន្តែពុំទាន់មានសេចក្តីសម្រេចស្ថាពរ ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការដោយស្លៀកពាក់សម្លៀកបំពាក់ស៊ីវិលធម្មតា។

៦.៧.៣ ចៅក្រមគួរអនុញ្ញាតឱ្យជនជាប់ចោទដែលត្រូវបាននាំមកតុលាការក្នុងឯកសណ្ឋានទណ្ឌិត ស្លៀកពាក់ឯកសណ្ឋានស៊ីវិលរបស់ខ្លួនជំនួសវិញមុនពេលសវនាការ។

## ៦.៨. អនុសាសន៍ទាក់ទងនឹងការប្រតិបត្តិរបស់ចៅក្រម

៦.៨.១ ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរធ្វើការរួមគ្នាដើម្បីពិនិត្យឡើងវិញលើក្រមសីលធម៌ចៅក្រម និងធ្វើការកែសម្រួលតាមការចាំបាច់។ ការកែសម្រួលគួររាប់បញ្ចូលទាំងការហាមឃាត់ដាច់ខាតលើការប្រើប្រាស់ទូរស័ព្ទចល័ត និងគួរអនុញ្ញាតឱ្យមានការសម្រាករយៈពេលខ្លី ដើម្បីអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងមេធាវីចាកចេញពីបន្ទប់សវនាការ ឬទទួលទូរស័ព្ទរបស់ខ្លួន។ ចៅក្រមក៏គួរធានាដែរថា ចៅក្រមបានបែងចែកពេលវេលាគ្រប់គ្រាន់ក្នុងការស្តាប់សវនាការរបស់ខ្លួន ដើម្បីធានាថាសំណុំរឿងរបស់ខ្លួនត្រូវបានជំនុំជម្រះបានត្រឹមត្រូវ និងដោយហ្មត់ចត់។

## ៦.៩. អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង

៦.៩.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិបង្ហាញភស្តុតាងរបស់ពួកគេ ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងការបង្ហាញភស្តុតាងប្រឆាំងនឹងពួកគេដែរ។

៦.៩.២ ចៅក្រមគួរបង្គាប់ឱ្យសាក្សីឱ្យចាកចេញពីបន្ទប់សវនាការរហូតទាល់តែពួកគេ ត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម ទើបអាចត្រឡប់មកវិញបាន ដែលនេះជាមធ្យោបាយមួយដើម្បីធានាថា សាក្សីមិនរងឥទ្ធិពលពីភស្តុតាង និងសក្ខីកម្មផ្សេងទៀតដែលបានបង្ហាញនៅពេលសវនាការ។

៦.៩.៣ ចៅក្រមត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្ន ថាតើភស្តុតាងដែលបានបង្ហាញមានលក្ខណៈហួសពីវិមតិសង្ស័យដែលថាជនជាប់ចោទមានពិរុទ្ធភាពដែរឬទេ។ ប្រសិនបើមានការបកស្រាយភស្តុតាងដែលស៊ីសង្វាក់គ្នានឹងភាពគ្មានទោសរបស់ជនជាប់ចោទ ដូច្នោះជនជាប់ចោទត្រូវតែបានផុតពីបទចោទ។

៦.៩.៤ ក្រសួងយុត្តិធម៌គួររៀបចំបង្កើតគោលការណ៍ណែនាំច្បាស់លាស់ទាក់ទងនឹងការបង្ហាញ និងការវាយតម្លៃភស្តុតាង ដោយផ្អែកលើការអនុវត្តរបស់ អ.វ.ត.ក [244] និងធានាថា ចៅក្រមទាំងអស់ទទួលបានការបណ្តុះបណ្តាលសមស្រប។

## ៦.១០. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

៦.១០.១ ធានាថាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយសរសេរអក្សរកាត់ក្នុងករណីចាំបាច់ ដើម្បីការពារអត្តសញ្ញាណរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសាក្សី ឬសម្រាប់ហេតុផលណាមួយផ្សេងទៀត។

[244] ការអនុវត្តរបស់ អ.វ.ត.ក អាចជាការណែនាំដ៏មានប្រយោជន៍ ជាពិសេសវិធានផ្ទៃក្នុងរបស់ខ្លួន ដូចជាវាក្យខណ្ឌ២០៤ ដល់ ២០៩ នៃសំណុំរឿងលេខ ០០២/០១ សាលដីកាសាលាឧទ្ធរណ៍ សូមមើល "សាលដីកាសាលាឧទ្ធរណ៍"; អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះតុលាការកំពូល (ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦) សំណុំរឿង/សំណុំរឿងកលេខ ០០២/១៩-០៩- ២០០៧-ECCC/SC, https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/F36_KH.pdf

៦.១០.២ ដោយទាញយកការអនុវត្តរបស់ អ.វ.ត.ក [245] គួរបង្កើតក្របខ័ណ្ឌមួយដែលចៅក្រមមានកាតព្វកិច្ចក្នុងការប្រាប់ និងពន្យល់អំពីសំអាងហេតុផ្លូវច្បាប់ និងភស្តុតាងលើមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន ហើយធានាថា សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុត្រូវបានផ្តល់ជូនដល់ជនជាប់ចោទ។

## ៦.១១. អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់

៦.១១.១ ចៅក្រមគួរពន្លឿន និងពង្រឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេសមាត្រា ៤៧ ដែលតម្រូវឱ្យដំណើរការជំនុំជម្រះ និងការប្រកាសសេចក្តីសម្រេចត្រូវធ្វើឡើងជាអសាធារណៈ។

៦.១១.២ ចៅក្រមគួរអនុវត្តតាមការប្រតិបត្តិល្អរបស់ អ.វ.ត.ក និងអនុញ្ញាតឱ្យកុមារទំនាស់នឹងច្បាប់បង្ហាញខ្លួននៅចំពោះមុខតុលាការដោយស្លៀកពាក់សម្លៀកបំពាក់របស់ខ្លួន នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងអស់។

៦.១១.៣ ចៅក្រមគួរកម្រិតការឃុំខ្លួនកុមារទំនាស់នឹងច្បាប់ចំពោះតែករណីពិសេស នៅពេលដែលមិនមានជម្រើសផ្សេងទៀតប៉ុណ្ណោះ ហើយធានាថា ក្នុងករណីបែបនេះ រាល់វិធានការចាំបាច់ទាំងអស់ត្រូវបានអនុវត្តដើម្បីគោរពសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ រួមទាំងការដាក់កុមារទាំងនោះឱ្យនៅដាច់ដោយឡែកពីជនជាប់ឃុំពេញវ័យផងដែរ។

៦.១១.៤ ក្រសួងយុត្តិធម៌គួរធានាថា ចៅក្រម និងព្រះរាជអាជ្ញាទទួលបានការបណ្តុះបណ្តាលជាក់លាក់ទាក់ទងនឹងបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌កុមារ។

៦.១១.៥ ចៅក្រមគួរពិនិត្យ និងប្រើប្រាស់វិធានការមិនឃុំខ្លួនដល់កុមារទំនាស់នឹងច្បាប់ និងអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តន្ទាទោសពាក់ព័ន្ធនឹងកុមារ ដែលត្រូវបានទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌដែលការផ្តោតសំខាន់លើការស្តារនីតិសម្បទាជាជាងការផ្តន្ទាទោសតែម្យ៉ាង និងផ្តោតលើឧត្តមប្រយោជន៍របស់កុមារ។

៦.១១.៦ ក្នុងសំណុំរឿងនានាពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ដែលសវនាការធ្វើជាសាធារណៈ ចៅក្រមត្រូវចាត់វិធានការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ ដូចជា ការប្រើប្រាស់វនាំងការពារឯកជនភាពជាដើម។

៦.១១.៧ ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរអនុវត្តវិធានបង្វែរដែលតាមរយៈវិធាននេះ កុមារទំនាស់នឹងច្បាប់ទទួលបានជំនួយគាំទ្រ និងស្តារនីតិសម្បទាចូលក្នុងសហគមន៍វិញ ដែលជាការបង្វែរមួយជំនួសឱ្យការកាត់ទោសជាផ្លូវការ។ វិធាននេះ ត្រូវអនុវត្តចំពោះគ្រប់កុមារទំនាស់នឹងច្បាប់ទាំងអស់ដែលប្រព្រឹត្តបទល្មើសដំបូង លើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

៦.១១.៨ ក្រសួងយុត្តិធម៌ត្រូវពិនិត្យឡើងវិញលើច្បាប់ដែលមានស្រាប់ រួមទាំងច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅរបស់តុលាការ ដើម្បីធានាបាននូវការអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីប្រព័ន្ធយុត្តិធម៌កុមារ រួមមាន វិធានក្រុង

---

[245] សូមមើល ជាពិសេស "សាលដីកាសាលាឧទ្ធរណ៍, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦, សំណុំរឿង/សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-ECCe/SC, https://www.eccc.gov.kh/sites/default/files/documents/courtdoc/2016-11-23%2011:55/Case%20002_01%20Appeal%20Judgement.pdf។

ប៉េកាំង គោលការណ៍ណែនាំរបស់អង្គការយូនីសេហ្វសម្រាប់កំណែទម្រង់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន [246] សៀវភៅណែនាំការអនុវត្តរបស់អង្គការយូនីសេហ្វសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ និងកំណែទម្រង់ច្បាប់របស់អង្គការយូនីសេហ្វ និងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។[247] និងកំណែទម្រង់ច្បាប់របស់អង្គការយូនីសេហ្វ និងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។[248]

[246] អង្គការយូនីសេហ្វ "គោលការណ៍ណែនាំស្តីពីកំណែទម្រង់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន" https://www.un.org/ruleoflaw/files/Juvenile_justice_16052011_final.pdf ។

[247] អង្គការយូនីសេហ្វ ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ទំព័រ ១០៧, https://www.unicef.org/lac/media/22071/file/Implementation%20Handbook%20for%20the%20CRC.pdf ។

[248] អង្គការយូនីសេហ្វ "កំណែទម្រង់ច្បាប់ និងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ" ទំព័រ ៨៧, http://www.unicef-irc.org/publications/pdf/law_reform_crc_imp.pdf។